ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

អបអរសាទរទិវាជាតិអំណាន លើកទី៨

១១ មីនា ២០២៣

# សិក្សាកថាក្រោមប្រធានបទ

# «គុណតម្លៃមនុស្ស ក្នុងយុគសម័យឌីជីថល»

ដោយ មី សុវណ្ណា

ព.ស. ២៥៦៦ គ.ស. ២០២៣

# ប្រវត្តិរូបសង្ខេបបេក្ខជន

## ព័ត៌មានទូទៅ

- ឈ្មោះ : មី សុវណ្ណ
- ភេទ : ប្រុស
- ថ្ងៃ ខែ ឆ្នាំកំណើត : ១៦ ធ្នូ ១៩៩០
- ទីកន្លែងកំណើត : ភូមិក្រាំងពញ្ញា ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- ទីលំនៅបច្ចុប្បន្ន : ភូមិដំណាក់ស្នាច់ ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- កម្រិតជំនាញ : មធ្យមសិក្សាទុតិយភូមិ
- ថ្ងៃ ខែ ឆ្នាំចូលបម្រើការងារ : ០១-១០-២០១៤

## ការសិក្សា

- ២០០៧-២០០៩ : មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យឧដុង្គ កំពង់ស្ពឺ)
- ២០០៩-២០១៣ : បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១៣-២០១៧ : បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១២-២០១៤ : គរុសិស្សភាសាបារាំង-ខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០១៧-២០១៨ : គរុនិស្សិតកម្រិតឧត្តម អក្សរសាស្ត្រខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០០៩ ជាអតីតជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ ឆ្នាំ២០០៩

## អត្តភាពការងារ

- ឆ្នាំ២០២២- បច្ចុប្បន្ន គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

## ទំនាក់ទំនងបេក្ខជន

- ទូរស័ព្ទទាក់ទង : ០១៧ ៤២៤ ២៦៣
- តេឡេក្រាម : ០១៥ ៤០៤ ៤៨៣
- អ៊ីម៉េល : sovannbandit@gmail.com

# មាតិកា


I- សេចក្តីផ្តើម.....1

II- តួសេចក្តី.....1

II.១- ពន្យល់បច្ចេកសព្ទ.....2

II.១.១- បច្ចេកសព្ទ«គុណតម្លៃ».....2

II.១.២- បច្ចេកសព្ទ«មនុស្ស».....2

II.១.៣- បច្ចេកសព្ទ«យុគសម័យឌីជីថល».....2

II.២- ពន្យល់ប្រធានបទ.....4

II.៣- បកស្រាយប្រធានបទ.....4

II.៣.១- តើមនុស្សមានគុណតម្លៃអ្វីខ្លះនៅក្នុងយុគសម័យឌីជីថល? .....4

II.៣.២- តើមនុស្សត្រូវធ្វើអ្វីខ្លះនៅយុគសម័យឌីជីថល? .....10

II.៣.៣- តើតម្លៃមនុស្សសាកលមានអ្វីខ្លះនាយុគសម័យឌីជីថល? .....18

II.៣.៤- តើលក្ខណសម្បត្តិរបស់មនុស្សនាយុគសម័យឌីជីថលមានអ្វីខ្លះ? .....23

II.៣.៥- តើតម្លៃមនុស្សដែលប្រកបដោយមនសិការវិជ្ជាជីវៈមានអ្វីខ្លះ? .....25

II.៣.៦-តើមនុស្សនាយុគសម័យឌីជីថលមានគោលការណ៍ប្រចាំជីវិតអ្វីខ្លះ? .....30

II.៤- សរុបខ្លឹមសារសំខាន់ៗ.....40

III-បញ្ចប់សេចក្តី.....43

ឯកសារពិគ្រោះ

ឧបសម្ព័ន្ធ

# ប្រធានបទ៖ «គុណតម្លៃមនុស្ស ក្នុងយុគសម័យឌីជីថល»

## I- សេចក្តីផ្តើម

ជាការពិតណាស់ កើតមកជាមនុស្សនៅក្នុងលោកសន្និវាសនេះរមែងទាមទារនូវគុណសម្បត្តិជាច្រើនដែលតម្រូវឱ្យមនុស្សជាតិត្រូវបំពេញឱ្យបានល្អប្រសើរ។ ក្នុងនោះផងដែរ ការវិវត្តនៃសង្គមមនុស្សនាសម័យកាលបច្ចុប្បន្នគឺលឿនខ្លាំងណាស់។ កាលណាដែលយើងដើរមិនទាន់សម័យវិទ្យាសាស្ត្ររីកចម្រើននោះទេ នោះយើងច្បាស់ជាបាត់បង់ឱកាសជាក់ជាមិនខាន។ ត្រង់ន័យនេះគឺទាមទារឱ្យយើងសិក្សារៀនសូត្រទើបអាចទទួលបាននូវឱកាសមាសឱកាសប្រាក់ដែលជាក្តីសង្ឃឹមសម្រាប់ជីវិត។ ជាពិសេសនៅសម័យឌីជីថលដែលមនុស្សមានការវិវត្តយ៉ាងលឿនខាងផ្នែកបច្ចេកវិទ្យាទាន់សម័យ ហើយតម្រូវឱ្យយើងកែសម្រួលនូវការរស់នៅរត់ឱ្យទាន់សភាពការណ៍ជាក់ស្តែង។ ប្រសិនបើយើងមិនព្រមដើរឱ្យទាន់របត់នៃការរីកចម្រើនផ្នែកបច្ចេកវិទ្យានោះទេ យើងច្បាស់ជាបាត់បង់ឱកាស ឬប្រឈមទៅនឹងការលូតលាស់ក្នុងសង្គមសេដ្ឋកិច្ចឌីជីថលជាក់ជាមិនខាន។ ដូចនេះដើម្បីដើរឱ្យទាន់សង្គមសេដ្ឋកិច្ចឌីជីថល មនុស្សគប្បីសាងនូវគុណតម្លៃដើម្បីឆ្លើយតបទៅនឹងរបត់សង្គមនាសម័យថ្មី។ នៅយុគសម័យឌីជីថលជាសម័យកាលមួយដែលបច្ចេកវិទ្យាជឿនលឿនសម្បើមណាស់ ហើយបច្ចេកវិទ្យាទាំងអស់នោះបានជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃ ការងាររកស៊ី ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការរក្សាទុកទិន្នន័យសំខាន់ៗក្នុងចង្កោមការងារជាដើម។ បច្ចេកវិទ្យាជាជំនួយដល់អ្នកសិក្សាស្រាវជ្រាវជាច្រើនផ្នែកដូចជា ជួយសម្រួលការងារ ចម្លងសំណៅឯកសារ ថតស្តែនឯកសារ វាយឯកសារ រក្សាទុកសំណៅនានា ចងក្រងទិន្នន័យ សម្រួលដល់ការបកប្រែភាសា ហើយចំណេញពេលវេលា ចំណេញថវិកា ផ្តល់នូវសុវត្ថិភាព និងភាពងាយស្រួលដល់មនុស្សគ្រប់ឋានានុក្រម។ អាស្រ័យហេតុនេះ ទើបស្នេរចាប់ផ្តើមសិក្សាស្វែងយល់ចងក្រងសិក្សាកថាស្តីពីគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថល ដើម្បីចូលរួមអបអរសាទរទិវាជាតិអំណានលើកទី៨ ដែលប្រារព្ធធ្វើនាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ចំថ្ងៃប្រសូតរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ។ សិក្សាកថានេះជាការសាកល្បងស្វែងយល់អំពីគុណតម្លៃរបស់មនុស្សក្នុងសង្គមបរិបទនៃការរីកចម្រើនផ្នែកបច្ចេកវិទ្យាទំនើបជឿនលឿននៅយុគសម័យឌីជីថល។

តើគុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថលមានអ្វីខ្លះ? សម្រាប់មនុស្សក្នុងបរិបទសង្គមសេដ្ឋកិច្ចឌីជីថលគប្បីសាងគុណតម្លៃយ៉ាងដូចម្តេច?

## II-តួសេចក្តី

ដើម្បីជាប្រទីបក្នុងការស្រាយបំភ្លឺប្រធានបទប្រកបដោយអត្ថន័យខាងលើនេះ ជាដំបូងយើងគប្បីស្វែងយល់ពាក្យគន្លឹះដែលមាននៅក្នុងប្រធានបទជាមុនសិន។

### II.១- ពន្យល់បច្ចេកសព្ទ

#### II.១.១- បច្ចេកសព្ទ«គុណតម្លៃ»

«គុណតម្លៃ» បានន័យសេចក្តីថា ជាតម្លៃដ៏ថ្លៃថ្លារបស់មនុស្ស ជាកិត្តិយសជាកិត្យានុភាព ជាគុណប្រយោជន៍ដ៏ថ្លៃថ្នូររបស់មនុស្ស ។ គុណតម្លៃ បានដល់លក្ខណសម្បត្តិជាវិជ្ជមានរបស់បុគ្គលម្នាក់ៗដែលជាទីគោរព និងឱ្យតម្លៃរបស់មនុស្សនៅក្នុងសង្គម។

#### II.១.២- បច្ចេកសព្ទ«មនុស្ស»

តាមវចនានុក្រមសម្តេច ព្រះសង្ឃរាជ ជួន ណាត បានពន្យល់ពាក្យ«មនុស្ស»ថាមានថ្នាក់ពាក្យជានាម មានប្រភពមកពីពាក្យបាលី ឬសំស្ក្រឹត ហើយបានសេចក្តីថា ជនអ្នកដឹងការខុសត្រូវ សត្វវិសេសមួយប្រភេទជាពូជវង្សនៃមនុ ឬនរៈ។ មនុស្សជាតិ (មៈ-នុស-សៈ-ជាត) ជាតិជាមនុស្ស ពួកមនុស្ស។ មនុស្សទេព ទេវតារបស់ពួកមនុស្ស (ក្សត្រិយ៍ទ្រង់រាជ្យ)។ មនុស្សធម៌ ធម៌សម្រាប់មនុស្ស ( ច្បាប់សម្រាប់ប្រដៅពួកមនុស្សឱ្យប្រព្រឹត្តសុចរិត; សីល៥ជាដើម។ មនុស្សលោក លោកជាទីនៅនៃពួកមនុស្ស ពោលគឺលោកសម្រាប់ពួកមនុស្ស, ឋានមនុស្ស។ មៈនុស (បា. ឬ សំ.) មនុស្ស មនុស្សជាតិ បានន័យថា ជាសត្វវិសេសមួយប្រភេទដែលចេះគិតពិចារណាក្រៃលែង។ ពោលគឺជាមនុស្សដែលមានការគិតដ៏ខ្ពង់ខ្ពស់ឧដុង្គឧត្តមក្រៃលែង។

#### II.១.៣- បច្ចេកសព្ទ«គុណតម្លៃមនុស្ស»

«គុណតម្លៃមនុស្ស» បានន័យថា តម្លៃដ៏គាប់ប្រសើរ តម្លៃដ៏ប្រសើរថ្លៃថ្លា តម្លៃប្រកបដោយសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងនាមជាមនុស្សជាតិដូចគ្នា។ សិទ្ធិមនុស្ស សិទ្ធិសេរីភាព និងយុត្តិធម៌ ជាគុណតម្លៃដ៏ថ្លៃថ្លាជាទីបំផុតដែលជាទីប្រាថ្នាចង់បានរបស់មនុស្សលើសាកលលោក។ មនុស្សដែលមានតម្លៃទៅបាននៅក្នុងសង្គម លុះត្រាតែមនុស្សនោះមានចំណេះជំនាញច្បាស់លាស់ មានសីលធម៌ គុណធម៌ សុជីវធម៌ចេះរួមរស់នៅក្នុងសង្គមប្រកបដោយសាមគ្គីធម៌ស្របតាមសង្គមសេដ្ឋកិច្ចឌីជីថល។

## II.១.៤- បច្ចេកសព្ទ«យុគសម័យឌីជីថល»

«យុគសម័យឌីជីថល» បានន័យថា ជាសម័យទំនើបវិទ្យាសាស្ត្រ ជាសម័យជឿនលឿន ជាសម័យដែលបច្ចេកវិទ្យាទាន់សម័យខ្លាំងណាស់។ ពោលគឺជាសម័យជឿនលឿនរីកចម្រើនផ្នែកបច្ចេកវិទ្យាទំនើប។ សម័យឌីជីថលជាសម័យកាលមួយជឿនលឿនខ្លាំងដែលពិភពលោកទាំងមូលបានដើរដល់របត់មួយមិនអាចបកក្រោយបាន។ ជាពិសេស សម័យកាលនេះជាសម័យមួយនាសម័យបដិវត្តន៍ឧស្សាហកម្មជឿនលឿន ឬបដិវត្តន៍ឧស្សាហកម្ម ៤.0 ដែលទាមទារនូវការអភិវឌ្ឍលើគ្រប់វិស័យ។ យុគសម័យឌីជីថល ជាសម័យកាលមួយដែលពិភពលោកបាន និងកំពុងរួមគ្នាគិតគូរទៅលើខាងផ្នែកសេដ្ឋកិច្ចជាជាងគិតគូរតែលើមនោគមវិជ្ជា។ ប្រការនេះខុសប្លែកគ្នាយ៉ាងខ្លាំង កាលពីអតីតកាលដែលពិភពលោកទាំងមូលបង្កើតបានជាប្លុកនៃលោកសេរី និងលោកកុម្មុយនីស្តដែលបម្រើមនោគមវិជ្ជានយោបាយរៀងៗខ្លួន។ សម័យកាលនេះ សណ្ដាប់ធ្នាប់ពិភពលោកពិតជាមានការប្រែប្រួលខ្លាំងមែនទែនអាស្រ័យលើបច្ចេកវិទ្យាទំនើបៗតាមបែបសង្គមឌីជីថល។ ហេតុនេះ គុណតម្លៃរបស់មនុស្សគប្បីលើកកម្ពស់ជានិច្ចឱ្យបានទូលំទូលាយស្របទៅនឹងអ្វីដែលគេហៅថា ការរីកចម្រើននៃសង្គមសេដ្ឋកិច្ចតាមបែបឌីជីថល។

## II.២- ពន្យល់ប្រធានបទ

ឆ្លងតាមការពន្យល់ពាក្យគន្លឹះខាងលើនេះ យើងបានឃើញថា ប្រធានទាំងមូលចង់ឱ្យយើងលើកពីគុណតម្លៃដ៏ថ្លៃថ្លារបស់មនុស្សនាសម័យវិទ្យាសាស្ត្រជឿនលឿនក្នុងយុគសម័យទំនើបថ្មីនេះ។ ពោលគឺនៅសតវត្សរ៍ទី២១នេះ ថាតើមនុស្សត្រូវមានលក្ខខណ្ឌយ៉ាងដូចម្ដេចខ្លះក្នុងសម័យជឿនលឿនផ្នែកបច្ចេកវិទ្យានេះ? ជាមួយគ្នានេះ ប្រធានទាំងមូលបានន័យសេចក្ដីថា នៅក្នុងសម័យទំនើបជឿនលឿនរីកចម្រើនផ្នែកបច្ចេកវិទ្យា មនុស្សគប្បីមាននូវលក្ខណសម្បត្តិដ៏ប្រសើរថ្លៃថ្លាមិនអាចកាត់ថ្លៃបានគឺចំណេះដឹង ជំនាញ ចរិយាសម្បត្តិ សេចក្ដីថ្លៃថ្នូរ និងសុខភាពរាងកាយល្អមាំមួនដើម្បីដើរឱ្យទាន់សម័យកាលក្លាយជាមនុស្សពេញលេញនៅយុគសម័យសេដ្ឋកិច្ចឌីជីថល។

ជាការពិតណាស់ ប្រធានទាំងមូលចង់ឱ្យយើងបង្ហាញតម្លៃចាំបាច់របស់មនុស្សនាសម័យបច្ចេកវិទ្យាជឿនលឿនដែលជាសម័យវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដូចយើងបានដឹងស្រាប់ហើយថា វិទ្យាសាស្ត្រចេះតែដើរទៅមុខជឿនលឿនជានិច្ច មានការវិវត្តថ្មីៗជាច្រើន និងឆាប់រហ័សផង។ ដូចនេះមនុស្សគប្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យទាន់សភាពការណ៍ជាក់ស្ដែង ងាយស្រួលបត់បែនស្របតាមបរិបទនៃសម័យកាល

ទំនើបនេះ។ ប្រសិនបើយើងមិនបានស្គាល់ពីកាលៈទេសៈ ឬបរិបទនៃសង្គមនាសម័យកាលទំនើបនោះទេ យើងអាចបាត់បង់ឱកាស ឬខ្វះកាលានុវត្តភាព ហើយដែលអាចនាំខ្សែជីវិតប្រឈមនឹងបញ្ហានានា បាត់បង់នូវសក្តានុពលរបស់ខ្លួន។ ដូចនេះការយល់ដឹងពីសម័យកាលរមែងជួយយឹតយោងបុគ្គលឱ្យចាកឆ្ងាយពីគ្រោះអវិជ្ជា ឬហានិភ័យជីវិតដោយប្រការណាមួយជាយថាហេតុ។ ជាពិសេសនាំឱ្យយើងមានការយល់ដឹងខ្ពស់ ចេះរៀបចំអនាគតឱ្យបានកាន់តែល្អប្រសើរ ចេះយល់ការណ៍រាក់ជ្រៅ ចេះវិភាគ និងស្វែងយល់បានវែងឆ្ងាយ ងាយស្រួលត្រៀមខ្លួនទុកជាមុនដើម្បីដើរឱ្យទាន់របត់សង្គមសេដ្ឋកិច្ចឌីជីថល។

## II.៣-**បកស្រាយប្រធានបទ**

ជាការពិតណាស់ សមស្របដូចប្រធានបានលើកខាងលើនេះមែន។ យើងបានដឹងហើយថា នាយុគសម័យឌីជីថលនេះបាននាំឱ្យមនុស្សមានការផ្លាស់ប្តូរការគិត និងឥរិយាបថជាច្រើន។ អ្វីៗដែលកើតឡើងមកនាសង្គមទំនើបមានការប្រែប្រួលច្រើនណាស់។ នៅពេលខ្លះមនុស្សយើងហាក់បីដូចជាមានអារម្មណ៍ថា ដើរមិនទាន់សង្គមថែមទៀតផង។ យើងសាកសង្កេតមើលថា កាលពីមុនយើងមានត្រឹមតែឧបករណ៍ទាក់ទងធម្មតា។ លុះដល់សម័យកាលឥឡូវនេះ យើងមានបច្ចេកវិទ្យាទំនើបៗជឿនលឿនជាសង្គមសេដ្ឋកិច្ចតាមបែបឌីជីថលដែលអ្វីៗទំនើបទាន់សម័យនិយមក្រៃលែង។ យើងអាចទាក់ទងគ្នា មើលមុខគ្នាតាមប្រព័ន្ធទូរស័ព្ទឆ្លាតវៃថ្មីជឿនលឿន ហើយងាយស្រួលខ្លាំងណាស់ ជួយសម្រួលការងារជាច្រើន មិនថាជាការប្រាស្រ័យទាក់ទងគ្នា និងការសួរសុខទុក្ខគ្នាជាដើម។ សម័យនេះ មនុស្សរវល់ច្រើនណាស់នៅក្នុងប្រព័ន្ធជីវិតរបស់ខ្លួន ដោយសារតែការងារ គ្រួសារ និងសុខភាពផ្ទាល់ខ្លួន។ ថ្វីបើយ៉ាងនេះក្តី គេអាចបង្កើនការយល់ដឹងពីឌីជីថល ហើយបើគេអាចយល់ដឹងបានច្រើនកាលណា ល្អកាលហ្នឹង។ ប្រសិនបើយើងខ្វះការយល់ដឹង នោះប្រាកដជាបាត់បង់ឱកាស ឬដើរមិនទាន់សភាពការណ៍ជាក់ស្តែង ព្រឹត្តិការណ៍ថ្មីៗជាក់ជាមិនខានឡើយ។

### II.៣.១- តើគុណតម្លៃមនុស្សនៅក្នុងយុគសម័យឌីជីថលមានអ្វីខ្លះ ?

នៅសម័យឌីជីថលមនុស្សទាមទារនូវការសិក្សារៀនសូត្រច្រើនណាស់ដើម្បីដើរឱ្យទាន់សភាពការណ៍ជាក់ស្តែង ស្របទៅតាមបរិបទសង្គមវប្បធម៌ និងសេដ្ឋកិច្ចឌីជីថលនៅក្នុងតំបន់ក៏ដូចជានៅលើពិភពលោក។ មនុស្សគប្បីសិក្សារៀនសូត្រ ផ្សព្វផ្សាយ ចែករំលែកចំណេះដឹងតាមរយៈបច្ចេកវិទ្យាដែលខ្លួនបាននិងកំពុងប្រើប្រាស់។ កាលណាដែលមនុស្សមានចំណេះដឹងច្បាស់លាស់ទៅលើការប្រើប្រាស់

បច្ចេកវិទ្យា នោះញ៉ាំងឱ្យគេមានការរីកចម្រើនលើគ្រប់វិស័យ មានការយល់ដឹងខ្ពស់ មានការអភិវឌ្ឍគំនិតបំណិនរបស់ខ្លួនបានយ៉ាងប៉ិនប្រសប់។ ត្រង់ន័យថាកាលណាមានការយល់ដឹងពីបច្ចេកវិទ្យាឌីជីថលសង្គមសេដ្ឋកិច្ចតាមបែបឌីជីថល ត្បិតថាវាបានជួយសម្រួលការងាររបស់មនុស្សបានល្អដែលអាចដឹកនាំអនាគតឆ្ពោះទៅរកភាពជឿនលឿន និងស្រស់បំព្រង។

ជាក់ស្ដែង យើងបានសង្កេតឃើញថាមនុស្សដែលចេះដឹងពីបច្ចេកវិទ្យា គេអាចចាប់យកឱកាសការងារ រកប្រាក់ចំណូលចិញ្ចឹមជីវិតតាមរយៈការងាររបស់គេផ្ទាល់តែម្ដង។ គេអាចស្វែងយល់ពីកម្មវិធីផ្សេងៗនៅក្នុងទូរស័ព្ទដៃ កុំព្យូទ័រ ប្រមូលទិន្នន័យ ចុះការងារ ការសិក្សាស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ នាំឱ្យគេបានយល់ដឹងបានទូលំទូលាយ។ លើសពីនេះផងដែរ យើងអាចទាក់ទាញចំណាប់អារម្មណ៍ បង្កើតកម្មវិធីដើម្បីទាក់ទាញលើគ្រប់វិស័យ ការងាររកស៊ី ជំនួញ និងការងាររដ្ឋបាលជាដើម។ មនុស្សនាសម័យនេះគប្បីរៀនសូត្របន្ថែមទៀតឱ្យមានចំណេះដឹងលើជំនាញរបស់ខ្លួនជាក់ប្រាកដ មានជំនាញច្បាស់លាស់មិនមែនលំៗ ហើយអភិវឌ្ឍសមត្ថភាពជំនាញជាប្រចាំដើម្បីជីវភាពប្រចាំថ្ងៃ។ ការបានរស់រានមានជីវិតមិនមែនជាការងាយស្រួលឡើយ។ ដូចនេះ បំណាច់នឹងមានជីវិតមកហើយគប្បីហ្វឹកហាត់ដុសខាត់ អភិវឌ្ឍសមត្ថភាពជំនាញឱ្យសមជាពលរដ្ឋសាកល ចេះសិក្សារៀនសូត្រឱ្យបានច្រើនដើម្បីជាគំរូឬជាថ្នាក់ដឹកនាំនាំថ្ងៃអនាគត។ នៅសម័យកាលនេះ យើងអាចរៀនសូត្របន្ថែមលើជំនាញវគ្គខ្លីៗដែលសមស្របទៅនឹងតម្រូវការការងារប្រចាំថ្ងៃ ដើម្បីអភិវឌ្ឍលើជំនាញអាជីពរបស់ខ្លួន។ ជាពិសេសប្រជាជនខ្មែរយើងគប្បីស្វែងយល់ពីការប្រើប្រាស់ បច្ចេកវិទ្យាប្រកបដោយការទទួលខុសត្រូវ ទប់ស្កាត់រាល់ព័ត៌មានអសកម្ម ឬប្រឆាំងដាច់ខាតរាល់ព័ត៌មានក្លែងក្លាយគ្រប់រូបភាពដែលបំពុលសង្គម។ ក្រៅពីនោះផងដែរពួកគាត់ត្រូវចេះសិក្សាស្វែងយល់វិភាគឱ្យបានគ្រប់ជ្រុងជ្រោយលើដែនព័ត៌មាន។ សំណួរដែលគេអាចចោទសួរបាននោះគឺថា តើព័ត៌មានណាច្បាស់ការ ហើយព័ត៌មានណាមិនទាន់ច្បាស់ការ? កាលណាគេចេះ ឬក្ដាប់បានការងារទាំងអស់នោះ វាមានការងាយស្រួលក្រៃលែងក្នុងការវិភាគស្ថានការណ៍បានគ្រប់ជ្រុងជ្រោយ។ ប្រជាជនគប្បីចេះក្ដាប់ខ្លឹមសារបានល្អរាល់ព័ត៌មានតាមបណ្ដាញសង្គម ដោយសិក្សាបន្ថែមលើអក្ខរកម្មឌីជីថលដែលបម្រើដល់កន្លែងការងាររបស់ខ្លួនមិនថាជាការងារឯកជន ឬរដ្ឋឡើយ។ ពួកគេគប្បីស្វែងយល់ថា ព័ត៌មានដែលមិនច្បាស់ការ ឬមិនច្បាស់លាស់គឺមិនចែករំលែកជាដាច់ខាត។ មនុស្សនាសម័យឌីជីថលគប្បីរៀនប្រើប្រាស់ប្រព័ន្ធឌីជីថលឱ្យទាន់សម័យនិយម។ កាលណាដែលគេជាមនុស្សមួយដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ នោះងាយស្រួលក្នុងការរៀបចំដំណើរជីវិតរបស់ខ្លួនបានកាន់តែជឿន

លឿនទៅមុខជានិច្ច។ នេះជាគុណតម្លៃមួយដែលមនុស្សនៅយុគសម័យឌីជីថលគប្បីស្វែងយល់។ម្យ៉ាង វិញទៀត មនុស្សដែលមានផែនការច្បាស់លាស់ មានទស្សនវិស័យ មានគោលដៅពុះពារអនុវត្តផែនការឱ្យបានជោគជ័យមួយរយភាគរយដោយស្រឡាញ់ពេញចិត្តរាល់អ្វីដែលខ្លួនមាន។ កាលណាមនុស្សស្រឡាញ់ពេញចិត្តពេញថ្លើមនូវអ្វីដែលយើងមាន នោះយើងមិនងាយនឹងធ្លាក់បាក់ទឹកចិត្តឡើយ។ ហើយមនុស្សគប្បីជម្រុះចោលនូវជំនឿមិនសមហេតុផលទាំងឡាយដែលបង្អាក់ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ។ ជំនឿទាំងឡាយដែលអគតិ ខ្វះភាពប្រាកដនិយមមិនសមហេតុផល យើងគប្បីពិចារណាឱ្យបានល្អិតសុខុម និងស្វែងយល់ឱ្យបានច្រើនជាអតិបរមា។ ជាមួយគ្នានេះ មនុស្សគប្បីស្រវាចាប់យកនូវអ្វីដែលមានលក្ខណៈវិជ្ជមាន ចិញ្ចឹមចិត្តដោយសេចក្តីល្អ ហើយមិនបៀតបៀនអ្នកដទៃ ជាវិការៈប្រពៃជាទីបំផុតដែលជួយជំរុញឱ្យមនុស្សរស់នៅសេចក្តីសុខ។ នាសម័យបច្ចុប្បន្ននេះមានជំងឺកាចសាហាវក្រៃលែងដូចជាកូវីដ១៩ដែលបានសម្លាប់ជីវិតមនុស្សលើសាកលលោកជាច្រើនលាននាក់។ ដូចនេះយើងគប្បីចេះថែរក្សាសុខភាពរបស់ខ្លួនឱ្យបានល្អប្រសើរ។ ពីព្រោះសុខភាពល្អជាគ្រាប់ពេជ្រ។ កាលណាដែលយើងឈឺ ជីវិតយើងគឺពិតជាពិបាកវេទនាក្រៃលែង។ មានសុខភាពល្អទៅបានលុះត្រាតែយើងចេះពីក្បួនអនាម័យ រៀនសូត្រតាមប្រព័ន្ធបច្ចេកវិទ្យា ស្វែងយល់ពីខ្លួនឯង រៀនធ្វើជាគ្រូពេទ្យសម្រាប់ខ្លួនឯង។ ពីព្រោះយើងបានដឹងហើយថាមានជំងឺខ្លះគឺទាមទារឱ្យយើងស្វែងយល់ដឹងដោយខ្លួនឯង។ ជាក់ស្តែងកូវីដ១៩ ដែលបានសម្លាប់មនុស្សរាប់លាននាក់នៅលើសាកលលោកនេះ បានគំរាមកំហែងដល់មនុស្សជាតិ សូម្បីតែកូនកោះតូចមួយក៏ប៉ះពាល់ដែរ។ តើប៉ះពាល់ដល់អ្វី? ប៉ះពាល់ដល់ជីវិត ប៉ះពាល់សេដ្ឋកិច្ចមនុស្សជាតិ។ ដូចនេះការចេះថែរក្សាខ្លួនឯង មើលថែខ្លួនឯងជាចំណុចយ៉ាងសំខាន់ដែលនាំឱ្យមនុស្សមានសុភមង្គល។ ត្រង់ន័យនេះក៏ចង់ប្រាប់ឱ្យយើងដឹងដែរថា ពេលខ្លះយើងមិនអាចពឹងតែលើគ្រូពេទ្យបានទាំងស្រុងឡើយ។ យើងគប្បីចេះជួយខ្លួនឯងជាមុនសិន។ កាលណាចេះជួយខ្លួនឯងបានប៉ុណ្ណឹង រាប់ថាយើងមានស្មារតី មានទំនួលខុសត្រូវ មានក្តីសង្ឃឹម និងមានតម្លៃក្នុងនាមជាមនុស្សពេញលេញនាសតវត្សរ៍ទី២១។

នៅក្នុងសង្គមបច្ចុប្បន្ននេះ ពិភពលោកទាំងមូលដើរលឿនណាស់។ ដូចនេះមនុស្សគប្បីមានស្មារតីពុះពារគ្រប់កាលៈទេសៈមិនត្រូវរាថយឡើយ។ ជាមនុស្សដែលពោរពេញដោយគុណតម្លៃគប្បីមានចិត្តអំណត់ព្យាយាមគ្រប់កាលៈទេសៈ ដុសខាត់ប្រាជ្ញាស្មារតីរបស់ខ្លួន ចេះតាមដានព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ និងចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឱ្យទាន់សម័យកាលប្រកបដោយសុវត្ថិភាព។ កាលពីសម័យបុរាណយើងមិនមានភាពជឿនលឿនដូចកាលសម័យនេះនោះទេ។ ប៉ុន្តែនាសម័យសព្វថ្ងៃនេះខុសពី

សម័យកាលមុនដែលពិភពលោកទាំងមូលទាមទារឱ្យមានការបត់បែនគ្រប់កាលៈទេសៈ មានចំណេះដឹងផ្នែកប្រព័ន្ធឌីជីថលដោយសុវត្ថិភាពជាទីបំផុត។ បន្ថែមពីនេះមនុស្សគប្បីមានចំណេះដឹងហិរញ្ញវត្ថុដោយការគ្រប់គ្រងបញ្ជីចំណូលចំណាយ និងមានភាពត្រឹមត្រូវ។ ត្រង់ន័យនេះយើងបានដឹងថា ជាមនុស្សគប្បីចេះតាមដានព័ត៌ទាន់ហេតុការណ៍ទាំងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ។ ពេលគឺក្តាប់ឱ្យបានត្រឹមត្រូវដោយចេះវិភាគព័ត៌មានបានល្អ និងប្រកបដោយសុចរិតភាព។ ជាមនុស្សក្នុងយុគសម័យឌីជីថលត្រូវមានសេចក្ដីថ្លៃថ្នូរ មុននឹងចែករំលែកព័ត៌មានណាមួយត្រូវស្វែងរកប្រភពព័ត៌មានឱ្យបានច្បាស់លាស់ល្អត្រឹមត្រូវមានប្រភពយោងច្បាស់លាស់សឹមសម្រេចចិត្តក្នុងការចែករំលែក។ ត្រង់នេះជាភាពឈ្លាសវៃរបស់មនុស្សនាសម័យទំនើបសាកលភាវូបនីយកម្មដែលត្រូវមានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន។ មិនត្រឹមតែប៉ុណ្ណោះ គេគប្បីចេះទប់ស្កាត់រាល់ព័ត៌មានទាំងឡាយណាដែលបំពុលសង្គម បង្កបរិយាកាសមិនល្អ បង្កភាពវឹកវរដែលនាំឱ្យសង្គមមានបញ្ហាកើតឡើងជាយថាហេតុដោយប្រការណាមួយ។ ជាក់ស្ដែងគុណតម្លៃមនុស្សនៅយុគសម័យឌីជីថលដែលគួរពិចារណាដូចជា៖

## ក. ចូលរួមលើកកម្ពស់ការអានតាមប្រព័ន្ធអេឡិចត្រូនិក (អ៊ីប៊ុក)

មនុស្សគ្រប់រូបនាសម័យឌីជីថល គប្បីរៀនសូត្រ និងចេះអានតាមប្រព័ន្ធអេឡិចត្រូនិក ឬអ៊ីប៊ុកដែលមានភាពងាយស្រួលក្នុងការតាមដានតាមគ្រប់ព័ត៌មាន និងហេតុការណ៍ទាំងឡាយ។ ពីព្រោះថានាសម័យសព្វថ្ងៃនេះអ្វីៗហាក់បីដូចជាលឿនស្លេវពេកហើយ។ យើងគប្បីរៀនសូត្រពីគ្នាទៅវិញទៅមកដោយមិនត្រូវគិតថា ខ្លួនចេះគ្រប់យ៉ាង ដោយមិនព្រមដាក់ខ្លួនរៀនសូត្រពីមនុស្សដែលនៅជុំវិញទៅតាមជំនាញរបស់ខ្លួន និងឯកទេសរបស់ខ្លួន។ ជំនាញណាក៏ដោយឱ្យតែយើងចេះប្រាកដ យើងអាចស្វែងរកលាភសក្ការៈពីជំនាញនោះ ឬទុកអាជីពនោះជាផ្ទាំងបាយសម្រាប់ជីវិតរបស់ខ្លួន។ សម័យនេះ ការសិក្សាមានច្រើនវិធីណាស់។ គេអាចអានបានតាមបណ្ណាល័យអេឡិចត្រូនិក។ វាមានភាពងាយស្រួល ហើយមានឯកសារជាច្រើនដែលរក្សាទុកនៅក្នុងទិន្នន័យ។ ជាក់ស្ដែងសិស្ស និស្សិត អាចសិក្សារៀនសូត្រ ធ្វើលំហាត់ ធ្វើកិច្ចការស្រាវជ្រាវជាដើមបានយ៉ាងងាយស្រួល និងឆាប់រហ័សបានផលច្រើន។ សម្រាប់អ្នកសិក្សា អ្នកចងក្រងអ្នកនិពន្ធ អ្នកសរសេរសៀវភៅជាដើម គេអាចស្រាវជ្រាវ ដកស្រង់ខ្លឹមសារសំខាន់ៗតាមអ៊ីប៊ុកនេះ។ ន័យត្រង់នេះជាការលើកទឹកចិត្តឱ្យមនុស្សព្យាយាមអានគ្រប់កាលៈទេសៈ។

## ខ. លើកទឹកចិត្តដល់មនុស្សឱ្យស្រឡាញ់ការអានតាមប្រព័ន្ធឌីជីថល

មនុស្សនាយុគសម័យឌីជីថលគប្បីយល់ថា ការអានគឺជាអំណាច។ មានការអាន ទើបធ្វើឱ្យយើងមានការគិតភ្លឺថ្លា និងពោរពេញដោយគំនិតបញ្ញាញាណដោះស្រាយបញ្ហាគ្រប់កាលៈទេសៈ។ នាសម័យនេះការអានពិតជាទាមទារនូវការព្យាយាមខ្ពស់ណាស់។ ដើម្បីដោះស្រាយបញ្ហាជីវិត មនុស្សនាសម័យនេះត្រូវអានឱ្យបានគ្រប់ៗគ្នាតាមរយៈប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ រួមទាំងការសិក្សាតាមអនឡាញជាដើម។

ការជំរុញមនុស្សឱ្យចូលចិត្តអានជាគុណតម្លៃដ៏ថ្លៃថ្លាមិនអាចកាត់ថ្លៃបានឡើយ។ មនុស្សគប្បីអានជាប្រចាំដើម្បីដុសខាត់ប្រាជ្ញាស្មារតីរបស់ខ្លួនឱ្យបានល្អប្រសើរ។ ក្នុងនោះការអានតាមប្រព័ន្ធឌីជីថលពិតជាមានសារៈសំខាន់ពន់ពេកក្រៃ ហើយជួយសម្រួលដល់ការងារមនុស្សគ្រប់បែបយ៉ាង។ ការអានជួយឱ្យយើងអាចយល់ដឹងបានកាន់តែប្រសើរ និងជឿនលឿនជាងមុន។ កាលពីសម័យមុន ដើម្បីអានបាន គេត្រូវទៅបណ្ណាល័យ ហើយត្រូវខ្ចីឯកសារពីទីនោះផង។ លុះដល់សម័យកាលនេះពិតជាមានភាពជឿនលឿនសម្បើមណាស់។ គេអាចទាញយកឯកសារបានកាន់តែងាយស្រួលមកអាចយ៉ាងមានសេចក្ដីសុខ។ ការអានធ្វើឱ្យយើងមានសេចក្ដីសុខខ្លាំងណាស់។ មនុស្សណាដែលនិយមការអានបានកាន់តែច្រើនគឺរមែងមានការសប្បាយចិត្ត ពោរពេញដោយមនសិការ និងមានភាពចាស់ទុំ។ ស្ថិតក្នុងបរិបទនៃសម័យកាលកូវីដ ១៩នេះ ការអានតាមប្រព័ន្ធអនឡាញមានភាពងាយស្រួល ដោយសារមនុស្សអាចសិក្សាគ្រប់ពេលវេលាគ្រប់ទីកន្លែង និងពោរពេញទៅដោយផាសុកភាព។ យើងអាចសិក្សាពីចម្ងាយដែលកាលពីមុន នៅកម្ពុជាមិនទាន់មានភាពទាន់សម័យ និងយល់ដឹងសាយភាពលើការសិក្សាតាមអនឡាញទាំងស្រុងនៅឡើយនោះទេ។ ការអានតាមប្រព័ន្ធឌីជីថលបានជំរុញឱ្យមនុស្សចូលចិត្តអាន មានកម្មវិធីកាន់តែច្រើន ដឹងព័ត៌មានកាន់តែច្រើន និងមានភាពសម្បូរបែបក្រៃលែង។ ត្រង់នេះជាគុណតម្លៃដ៏ថ្លៃថ្លាដែលមនុស្សនាយុគសម័យឌីជីថលគប្បីស្វែងយល់ដឹង។

## គ. ផ្សព្វផ្សាយពីសារៈសំខាន់នៃការអានតាមប្រព័ន្ធឌីជីថល

ជាការពិតណាស់ ការអានរមែងផ្ដល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់មនុស្សជាតិទាំងមូល។ មនុស្សដែលកើតមកហើយគប្បីប្រឹងប្រែងសិក្សារៀនសូត្រធ្វើការ និងយល់ដឹងឱ្យបានច្រើន។ ប្រសិនបើយើងមិនស្វែងយល់នោះទេ យើងនឹងស្ថិតនៅក្នុងគ្រោះថ្នាក់អវិជ្ជាជាក់ជាមិនខានឡើយ។ យ៉ាងណាមិញនាសម័យជឿនលឿននេះ នរណាប្រឹង អ្នកនោះបាន អ្នកណាខិតខំ អ្នកនោះបានជាក់ជាមិនខាន។ ប្រសិនបើយើងមិនបានខិតខំ យើងនឹងបាត់បង់ឱកាសដើម្បីអភិវឌ្ឍខ្លួនជាក់ជាមិនខានឡើយ។ ពីព្រោះ

ការអភិវឌ្ឍខ្លួនទាមទារការអាន ការសិក្សារៀនសូត្របន្តគ្នាពីមួយជំនាន់ទៅមួយជំនាន់។ យ៉ាងណាមិញ មនុស្សនាសម័យឌីជីថលត្រូវការអានឱ្យបានច្រើន និងត្រូវដឹងថា ប្រព័ន្ធឌីជីថលពិតជាមានសារៈសំខាន់ណាស់។ វាមានភាពងាយស្រួល ជួយសម្រួលការងារគ្រប់បែបយ៉ាង ហើយទទួលបានលទ្ធផលល្អជាអតិបរមា។ កាលណា គេព្យាយាមអានលើគ្រប់វិស័យ គេនឹងមានការចេះដឹង ការយល់ដឹងជាច្រើន ហើយទទួលបាននូវអ្វីថ្មីៗបន្ថែមទៀត។ មនុស្សខ្មែរនាសម័យនេះគប្បីដើរឱ្យទាន់បច្ចេកវិទ្យាទំនើប យល់ដឹងពីបច្ចេកវិទ្យាឱ្យបានច្រើន។ តួយ៉ាងកាលណាដែលយើងដឹងបានច្រើន យើងអាចហាត់ពត់លត់ដំចិត្តផង និងសម្រួលដល់ការប្រើប្រាស់ការងារប្រចាំថ្ងៃផង។

## ឃ. អភិវឌ្ឍសមត្ថភាព កម្រិតគុណវុឌ្ឍិ គុណតម្លៃជីវិតឱ្យបានកាន់តែប្រសើរ

មនុស្សនាសម័យនេះខុសពីសម័យបុរាណឆ្ងាយណាស់។ សម័យមុន មនុស្សខ្មែរប្រើប្រាស់តែរទេះគោក្របីជាមធ្យោបាយនៃការធ្វើដំណើរ ហើយទាក់ទងគ្នាដោយប្រើប្រាស់សំបុត្រឆ្លងឆ្លើយគ្នាដោយការសរសេរលិខិតផ្ញើ ឬចារនៅលើស្បែកសត្វ ក្រាំង គម្ពីរសិលាចារឹកជាដើម។ ព្រះរាជសម្ភារដែលជាព្រះមហាក្សត្រខ្មែរនាសម័យឧដុង្គ ព្រះអង្គបានចារកំណាព្យនៅលើចុងត្នោត ដោយការប្រើប្រាស់ចិញ្ចៀន ឬព្រះទម្រង់សម្រាប់ចារ ឬជាកាំបិតចារជាដើម។

ព្រះរាជសម្ភារគ្រាដែលទ្រង់ត្រូវបានទាហានព័រទុយកាល់បាញ់ប្រហារទម្លាក់ពីលើចុងត្នោតនាស្រុកកញ្ជរ ខេត្តក្រចេះ ទ្រង់បានចារជាកំណាព្យថា៖«សាធុសម្ចាយ កុំបីវាយមាយ នឹងក្តីកាមា តែងឱ្យវង្វេង ក្នុងវដ្តសង្សារ ស្លាប់ទៅកាលណា បានសោយតែទុក្ខ។ ហេតុតែក្សត្រី នាំឱ្យអប្រិយ ដូចត្រីក្នុងភក់ បើបុរសផង ចង់ឆ្លងនរក កុំធ្វើវីក់ ដូចអញច្នេះណា»។ កំណាព្យរបស់ព្រះអង្គគឺត្រូវបានចារ ហើយបានបន្សល់ទុកូរហូតមកដល់សព្វថ្ងៃ។ ត្រង់ន័យនេះ យើងចង់បញ្ជាក់ថា កាលពីមុនមិនទាន់មានភាពសម្បូរបែបដូចកាលពីសម័យមុនឡើយ។ ប៉ុន្តែសម័យនេះ អ្វីៗប្រែប្រួលលឿនណាស់។ គេអាចប្រើប្រាស់បច្ចេកទេសថ្មី ឧបករណ៍ថ្មីៗ កុំព្យូទ័រដើម្បីរក្សាទុកឯកសារបានយ៉ាងងាយស្រួល។ គេអាចមានភាពងាយស្រួលនៅពេលដែលគេប្រាថ្នាចង់បានអ្វីមួយនាសម័យសព្វថ្ងៃនេះ។ ត្រង់ន័យថា កាលណាគេចេះអភិវឌ្ឍសមត្ថភាពរបស់ខ្លួន សិក្សារៀនសូត្រ ដើរឱ្យទាន់បច្ចេកវិទ្យា នោះការងារទាំងឡាយមានភាពជឿនលឿនមែនទែន។ ជាក់ស្តែង យុវជនគប្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនតាមរយៈជំនាញរឹង ជំនាញទន់ ជំនាញភាសាបរទេស ជំនាញទំនាក់ទំនង និងជំនាញដោះស្រាយបញ្ហាទាំងឡាយគ្រប់កាលៈទេសៈ។ យុវជនគប្បីមានចិត្តរឹងប៉ឹង ស្មារតីគត់មត់ល្អ ហ៊ានជម្នះគ្រប់ឧបសគ្គទាំងឡាយដែលបានកើតឡើង និងហ៊ាន

ប្រឈមរាលឧបសគ្គទាំងឡាយ។ ត្រង់នេះ យើងក៏បានមើលឃើញផងដែរថា យុវជនក្តី និស្សិតក្តី ពលរដ្ឋក្តី ត្រូវអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យបានល្អប្រសើរដោយត្រូវសិក្សារៀនសូត្រជាប្រចាំ និងមិនមានចិត្តរាថយ។ យុវជនគប្បីព្យាយាមរៀនសូត្រឡើង កុំខ្ជិលច្រអូសដែលជាហេតុនាំឱ្យខ្លួនបរាជ័យនៅក្នុងជីវិត។ ពោលគឺជំរឡើងកម្រិតគុណវុឌ្ឍិរបស់ខ្លួនឱ្យបានល្អប្រសើរ។ ត្រង់ន័យនេះ យើងបានដឹងហើយថា នៅតាមស្ថាប័នរដ្ឋក្តី ឯកជនក្តី កាលណាដែលគេចង់ជ្រើសរើសនាយក ឬអ្នកគ្រប់គ្រងផ្នែកណាមួយ គេគប្បីពិនិត្យលើកម្រិតគុណវឌ្ឍិដែលគេមាន។ ប្រសិនបើសមស្របហើយ គេនឹងលៃលកជ្រើសរើសតែងម្តង។ ដូចនេះគុណតម្លៃជីវិតរបស់មនុស្សក៏កើតឡើងតាមនោះដែរ។

ឆ្លងតាមការស្រាយបំភ្លឺ ធ្វើជាមនុស្សនាសម័យឌីជីថលគប្បីរៀនសូត្រជានិច្ច រៀនហើយ រៀនទៀត ដោយមិនដាក់ធុរៈចុះឡើយ។ ប្រការនេះ ជួយមនុស្សឱ្យយល់ដឹងបានច្រើនជាង ហើយអភិវឌ្ឍខ្លួនជាដរាបឱ្យសមស្របទៅតាមបរិបទសង្គមមនុស្សនាយុគសម័យឌីជីថល។

### ខ. ជួយបំបាត់គ្រោះអវិជ្ជានាសម័យវិទ្យាសាស្ត្រសេដ្ឋកិច្ច

មនុស្សនាសម័យនេះជាសម័យវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលតម្រូវឱ្យមនុស្សធ្វើការយល់ដឹងច្រើនណាស់នាពេលសព្វថ្ងៃនេះ។ ប្រសិនបើយើងមិនបានយកចិត្តទុកដាក់នោះទេ យើងប្រៀបបានជាជនរងគ្រោះ ឬដូចពិការដៃម្ខាងដោយសារខ្វះការយល់ដឹងអំពីបច្ចេកវិទ្យាជាក់ជាមិនខានឡើយ។ ត្រង់នេះចំណុចដែលយើងគប្បីសិក្សាស្វែងយល់បន្ថែមទៀត ឱ្យបានកាន់តែប្រសើរ។ ប្រសិនបើយើងមិនបានស្វែងយល់នោះទេ វាអាចជាកត្តាប្រឈមមិនខានឡើយ។ ត្រង់នេះជាចំណុចដែលយើងអាចយល់ដឹងបានខ្លះៗ ត្បិតថាការស្វែងយល់ដឹងពីចំណុចទាំងអស់នេះអាចជួយយើងច្រើនណាស់។ ជួយក្នុងការងារ ជួយសម្រួលក្នុងការរស់នៅ និងសម្របសម្រួលទៅតាមកាលៈទេសៈសង្គមជាក់ស្តែង។ ត្រង់នេះបានន័យថាការសិក្សាស្វែងយល់បន្ថែមអំពីបច្ចេកវិទ្យាឌីជីថលមានប្រយោជន៍ច្រើនណាស់ ជាប្រទីបមួយជួយយើងឱ្យបានកាន់តែប្រសើរក្នុងការអនុវត្តការងារប្រចាំថ្ងៃ។

## II.៣.២- តើមនុស្សត្រូវធ្វើអ្វីខ្លះនៅយុគសម័យឌីជីថល?

### ក. មនុស្សគ្រប់វ័យ និងគ្រប់ឋានានុក្រមគប្បីស្វែងយល់ពីឌីជីថល

និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ គ្រូពេទ្យ វេជ្ជបណ្ឌិត ប៉ូលិស ទាហាន មន្ត្រីរាជការ និងប្រជាពលរដ្ឋគ្រប់វ័យគ្រប់ស្រទាប់វណ្ណៈគប្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យបានល្អប្រសើរស្តីពីឌីជីថល។ ជា

ពិសេសពួកគេគប្បីចេះក្តាប់យកឱកាសឱ្យបាន និងចេះបង្កើតឱកាសឱ្យខ្លួនឯង។ ពីព្រោះថាសម័យនេះជាសម័យសន្តិភាព និងការអភិវឌ្ឍ កាលណាអ្នកប្រឹងនោះអ្នកនឹងបាន។ ផ្ទុយមកវិញ ប្រសិនបើអ្នកមិនមានចិត្តខ្នះខ្នែងប្រឹងប្រែងនោះទេ អ្នកនឹងបាត់បង់ឱកាសជាក់ជាមិនខានឡើយ។

អាស្រ័យហេតុនេះគ្រប់ស្រទាប់វណ្ណៈមិនថាអ្នកស្ថិតនៅក្នុងវិស័យណានោះឡើយ អ្នកត្រូវតែប្រឹងប្រែងទើបឱកាសហុចឱ្យ។ ប្រការនេះ ស្របដូចពាក្យពេចន៍មួយឃ្លានៅក្នុងច្បាប់ស្រីហិតោបទេសបានពោលថា «គ្មានសត្វម្រឹគឯណាបោលចូលមាត់សីហៈដែលកំពុងដេកលក់ឡើយ»។ បានន័យថាយើងត្រូវតែខ្នះខ្នែងដើម្បីទទួលបាននូវឱកាសសម្បូរបែប។ នៅសម័យឌីជីថល ច្បាស់ណាស់មនុស្សត្រូវរៀនសូត្រពីគ្នាទៅវិញទៅមក ហើយចេះបង្កើតឱកាសដល់ខ្លួនឯង និងសម្លឹងមើលឱ្យឃើញពីកត្តាសង្គមសេដ្ឋកិច្ច និងនយោបាយជាតិ អន្តរជាតិថាតើវាមានស្ថានភាពបែបណា ហើយយើងក្នុងនាមជាពលរដ្ឋគប្បីសម្របខ្លួន និងត្រៀមខ្លួនរបៀបណា? ត្រង់នេះហើយជាអ្វីដែលយើងគប្បីយល់ដឹង។ ដូចនេះបច្ចេកវិទ្យាឌីជីថលពិតជាមានសារៈសំខាន់ក្រៃលែងដែលបានផ្តល់នូវគុណតម្លៃគ្រប់បែបយ៉ាងបម្រើដល់សេចក្តីត្រូវការរបស់មនុស្ស។ កាលណាមនុស្សយល់ដឹងពីឌីជីថលមានភាពងាយស្រួលជួយសម្រួលការងារច្រើនណាស់។ ជាក់ស្តែងសម័យនេះ គេបើកលុយតាមធនាគារដែលងាយស្រួលដល់តម្រូវការជាក់ស្តែងភ្លាមៗមិនបាច់បើកប្រាក់ផ្ទាល់នៅការិយាល័យដូចកាលពីគ្រាមុន។ បើនៅតាមស្ថាប័នរដ្ឋវិញ ការបើកប្រាក់តាមកុងធនាគារជួយកាត់បន្ថយបុគ្គលិកខ្មោចរាប់សិបម៉ឺននាក់នៅកម្ពុជា។ ខ្មោចមិនអាចទៅបើកលុយបានទេ។ មានតែមនុស្សប៉ុណ្ណោះដែលអាចកាន់កាតកុងទៅបើកបាន។ ការបើកលុយតាមធនាគារងាយស្រួលចំណេញពេលវេលាមិនចាំបាច់មកការិយាល័យផ្ទាល់ឡើយ។ ឧបមាថាបើមានភារកិច្ចចុះខេត្ត ដល់មានកាតកុង ហើយមានធនាគារនៅទីនោះ វាងាយស្រួលមែនទែន មិនចាំបាច់ត្រូវមកទីតាំងផ្ទាល់ ឬផ្ញើតាមគេតាមឯង ឱ្យតែមានធនាគារ ឬមានភ្នាក់ងារវេរលុយ គេអាចបើកបានយ៉ាងងាយក្រៃលែង។ នៅក្នុងទូរស័ព្ទដៃស្មាតហ្វូន ឬទូរស័ព្ទឆ្លាតវៃ យើងអាចទាញយកកម្មវិធីធនាគារវេរលុយលឿនណាស់។ ពេលគឺជួយសម្រួលដល់ប្រជាជនឱ្យមានភាពងាយស្រួល ទំនុកចិត្ត និងជឿជាក់ខ្ពស់។ ត្រង់ន័យនេះ យើងចង់និយាយថា កាលណាពលរដ្ឋយល់ដឹងពីឌីជីដល គេអាចទទួលបានសេវាកម្មល្អ ជឿនលឿន ជឿជាក់និងឆាប់រហ័សទាន់សភាពការណ៍ជាក់ស្តែង។ ឌីជីថលជួយសម្រួលជីវភាពប្រជាជនមិនថានៅទីក្រុង ឬជនបទនោះទេឱ្យតែគេឆ្លាតឈ្លាសវៃស្វែងយល់ពីប្រព័ន្ធនេះ នោះងាយស្រួលពន់ពេកក្រៃ។ គេអាចបង់ទឹកភ្លើង បញ្ចូលកាតទូរស័ព្ទ បង់ធនាគារ បង់លុយតុងទីនជាដើម វេរលុយទំនិញសព្វសារពើតាមទូរស័ព្ទដៃ

ពោលគឺប្រព័ន្ធឌីជីថលនេះងាយស្រួលពន់ពេកក្រៃ។ សម័យនេះហើយជាសម័យឱកាសជឿនលឿន ជាសម័យបច្ចេកវិទ្យាជាន់ខ្ពស់ទំនើបដែលបម្រើដល់ការរស់នៅរបស់មនុស្សខ្មែរបានកាន់តែទំនើប។ ជាមួយគ្នានេះ យើងបានឃើញថា តាមប្រព័ន្ធទំនាក់ទំនងកាន់តែមានភាពងាយស្រួលជាងមុន។ ឧទាហរណ៍ គេអាចបញ្ជូនឯកសារបានភ្លាមៗងាយស្រួល មិនខាតពេលវេលា ហើយគេអាចចម្លងឯកសារបានងាយស្រួលខ្លាំងណាស់។ គេគ្រាន់តែចេះប្រើប្រាស់ទូរស័ព្ទស្មាតហ្វូនដែលមានភាពងាយស្រួល ហើយមានបណ្ដាញតភ្ជាប់ នោះគេអាចផ្ញើឯកសារចេញបានភ្លាមៗតែម្ដង។ គេអាចផ្ដិតចម្លងចេញមក ហើយចុះហត្ថលេខាបានយ៉ាងងាយស្រួលជាទីបំផុត។ គេអាចកែឯកសារបានងាយស្រួលតាមរយៈការកែសម្រួលលើខ្លឹមសារដែលមានស្រាប់នៅក្នុងអត្ថបទទាំងមូល។ មែនទែនទៅប្រព័ន្ធឌីជីថល ចំណេះដឹងផ្នែកឌីជីថលពិតជាផ្ដល់ប្រយោជន៍ច្រើនយ៉ាងដល់មនុស្សក្រៃលែង។ ជាក់ស្ដែងមួយទៀត នៅពេលដែលយើងធ្វើដំណើរតាមផ្លូវយើងអាចទាក់ទងហៅមធ្យោបាយនានាមកទទួលយើងបានងាយស្រួលដូចជាហៅកង់បី ហៅកង់បីឥណ្ឌា (ឡាំប្រឺតា) ឡានឈ្នួលបានយ៉ាងឆាប់រហ័ស។ ជាពិសេស គេអាចកក់សំបុត្រឡានក្រុង ឬទៅមើលកុនបានតាមរយៈទូរស័ព្ទឆ្លាតវៃបានយ៉ាងងាយផងដែរ។ យើងអាចទិញម្ហូបអាហារ ស្វែងរកអីវ៉ាន់នានា មើលទំនិញនានាតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបដែលជួយសម្រួលដល់តម្រូវការរបស់យើងក្នុងជីវភាពប្រចាំថ្ងៃ។ នៅលើពិភពលោក ជាពិសេសបណ្ដាប្រទេសជឿនលឿន ផ្នែកឌីជីថលនេះ គេដើរលឿនមុនបាត់ទៅហើយ។ គេអាចទូទាត់តម្លៃទំនិញទៅតាមប្រព័ន្ធឌីជីថលដោយមិនបាច់ឱ្យជាលុយសុទ្ធនោះទេ។ គេទិញទំនិញនានាតាមប្រព័ន្ធអនឡាញ ហើយគេបានដឹកយកមកឱ្យដល់ទីតាំងតែម្ដង។ ត្រង់នេះហើយជាគុណតម្លៃរបស់មនុស្សនាសម័យឌីជីថលមានច្រើនអនេកដែលយើងអាចសិក្សាស្វែងយល់បាន។ សម័យនេះសូម្បីតែនៅលើឡានក្រុងក៏គេអាចប្រើប្រាស់បានងាយស្រួល ការងារក៏រលូនមិនចាំបាច់ទៅដល់ទីតាំងផ្ទាល់ក៏គេអាចឆ្លើយតបសារបានទាន់សភាពការណ៍ជាក់ស្ដែង ហើយចំណេញពេលវេលាផងដែរ។ សិស្សានុសិស្សវិញអាចសិក្សាបានគ្រប់ទីកន្លែងដោយគេមិនចាំបាច់មានសៀវភៅដាក់តាមខ្លួន ក៏គេអាចអានបានតាមរយៈទូរស័ព្ទដៃបានដែរ។ សំខាន់ឱ្យតែមានបណ្ដាញដំណភ្ជាប់ដែលភាសាអង់គ្លេសគេហៅថា វ៉ាយហ្វាយ (Wifi)ជាការស្រេច។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ យើងអាចសន្និដ្ឋានបានថា បច្ចេកវិទ្យាឌីជីថលបានរួមចំណែកដល់ការរីកចម្រើនដល់សង្គមមនុស្សច្រើនណាស់។ ដូចនេះមនុស្សគ្រប់ស្រទាប់វណ្ណៈ បុគ្គលិកមន្ត្រីរាជការប្រជាពលរដ្ឋទូទៅគប្បីស្វែងយល់អំពីអ្វីដែលថ្មីៗតាមបែបឌីជីថលនេះឱ្យបានគ្រប់ៗគ្នា។ ជាពិសេសប្រើ

ប្រាស់វាប្រកបដោយភាពឆ្លាតវៃ និងសុវត្ថិភាពខ្ពស់។ កាលណាដែលយើងអាចប្រើប្រាស់វាប្រកបដោយភាពត្រឹមត្រូវ នោះជួយជំរុញឱ្យជីវិតរបស់យើងកាន់តែមានភាពស្រស់បំព្រងពោរពេញដោយមោទនភាព។

## ខ. រៀនសូត្រពេញមួយជីវិត ដាក់ចិត្តដាក់កាយស្រាវជ្រាវពេញមួយជីវិត

ជាការពិតណាស់ ការសិក្សាធ្វើឱ្យយើងសម្លឹងមើលពិភពលោកកាន់តែប្រសើរ និងល្អៗជាងមុន។ កាលណាមនុស្សគ្រប់រូបដាក់ចិត្តរៀនសូត្រពីគ្នាទៅវិញទៅមក គេអាចទទួលបាននូវផលប្រយោជន៍ជាច្រើនណាស់ ហើយមានវាសនាខ្ពស់ផង។ ការរៀនសូត្រនាសម័យទំនើប យើងអាចសិក្សារៀនសូត្របានគ្រប់ទីកន្លែង និងមិនរើសទីតាំងឡើយ។ មនុស្សនាសម័យថ្មីគប្បីដាក់ចិត្តដាក់កាយសិក្សារៀនសូត្រពេញមួយជីវិតដែលបានផ្តល់នូវគុណតម្លៃដ៏ថ្លៃថ្លាក្នុងការកសាងជីវិតនាយុគសម័យសេដ្ឋកិច្ចឌីជីថល។

ជាក់ស្តែង យើងអាចស្វែងយល់ពីសង្គមសព្វថ្ងៃ ដោយចេះស្វែងរកអ្វីដែលថ្មីដើម្បីអភិវឌ្ឍជីវិតរបស់យើងឱ្យបានស្រស់បំព្រង។ ក្នុងន័យនេះបានន័យសេចក្តីថាយើងត្រូវចេះចាប់យកនូវកាលានុវត្តភាពជាក់ស្តែង ឱកាសជាក់ស្តែង ហើយរំពៃមើលសព្វគ្រប់។ កាលណាដែលមនុស្សគ្រប់គ្នាស្រឡាញ់ការសិក្សាក្រេបជញ្ជក់នូវការសិក្សាធ្វើឱ្យជីវិតរបស់គេស្រស់បំព្រងជានិច្ច នៅក្មេងជានិច្ចដោយពុទ្ធិ។ បានន័យថាក្មេងដោយចំណេះដឹង ពីព្រោះចំណេះដឹងមានជម្រៅមិនចេះរីងស្ងួត។ មនុស្សដែលមានចំណេះដឹងអាចចិញ្ចឹមជីវិតដោយស្រួល មិនលំបាកពេកឡើយ។ ហើយទទួលបាននូវការគោរពស្រឡាញ់ពីសង្គមមនុស្សផងដែរ។ អាស្រ័យហេតុនេះ យើងគប្បីស្វែងយល់ពីគន្លងជីវភាពថ្មីតាមបែបឌីជីថល។

ហេតុអ្វីត្រូវគិតពីការអប់រំពេញមួយជីវិត? ការអប់រំពេញមួយជីវិត ឬការរៀនសូត្រពេញមួយជីវិតជារបៀបសិក្សាថ្មីមួយមិនឱ្យខ្លួនឯងជាប់គាំងនឹងកម្រិតចំណេះដឹងដែលមានពីអតីតកាល។ ការសិក្សាពេញមួយជីវិតគឺជាទម្រង់នៃការអប់រំដែលផ្តួចផ្តើមដោយខ្លួនឯងដោយផ្តោតលើការអភិវឌ្ឍផ្ទាល់ខ្លួន ហើយជាការរៀនសូត្រដែលកើតឡើងនៅខាងក្រៅ និងក្នុងស្ថាប័នអប់រំផ្លូវការដូចជាសាលារៀន សាកលវិទ្យាល័យ ឬការបណ្តុះបណ្តាលអាជីវកម្មជាដើម។ ការរៀនពេញមួយជីវិតមិនចាំបាច់ដាក់កម្រិតខ្លួនឯងចំពោះការសិក្សាក្រៅផ្លូវការនោះទេ។ មធ្យោបាយដើម្បីសម្រេចលទ្ធផលនេះ បុគ្គលអាចទទួលបានការអប់រំក្រៅផ្លូវការ ឬផ្លូវការស្របតាមបរិបទសង្គមសេដ្ឋកិច្ចឌីជីថល ។ ខាងក្រោមនេះជាហេតុផល ៤ចំណុចដែលក្រុមអ្នកជំនាញអប់រំអន្តរជាតិខាងដំណោះស្រាយការសិក្សាតាមបែបវ៉ាឡាមី (Valamis Learning Solution) បង្ហាញពីគុណសម្បត្តិរបស់បុគ្គលទទួលយកការអប់រំពេញមួយជីវិតដូចជា៖

**១. លើកទឹកចិត្តខ្លួនឯងឱ្យទទួលការសិក្សាថ្មី ៖** ហេតុផលវ័យកាន់តែវិវត្តលឿន បច្ចេកវិទ្យាកាន់តែរីកចម្រើន ស្ថានភាពការងារកាន់តែរវល់ខ្លាំង និងជាប់ធុរៈ កិច្ចការផ្ទះ អាចឱ្យមនុស្សជាប់គាំងក្នុងការទទួលយកការអប់រំថ្មីៗ ឬមិនអាចទទួលយកការអប់រំពេញមួយជីវិត។ សម្រាប់ទ្រឹស្តីនៃការអប់រំពេញមួយជីវិត ហេតុផលខាងលើនេះ មិនមែនជាឧបសគ្គសម្រាប់ការសិក្សាឡើយ។ ផ្ទុយទៅវិញបុគ្គលត្រូវលើកទឹកចិត្តខ្លួនឯងឱ្យទទួលបានការងារអប់រំបន្ថែម បើទោះបីការអប់រំក្រៅផ្លូវការ ឬផ្លូវការ។ កម្រិតយល់ដឹងរបស់មនុស្សក៏មិនអាចកំណត់បាននោះទេ ប្រសិនបើមនុស្សសម្រេចបន្តការសិក្សាពេញមួយជីវិត ។

**២. សម្រេចគោលដៅជីវិត ៖** មនុស្សម្នាក់ៗមានគោលដៅជីវិត និងបុព្វហេតុរៀងៗខ្លួន ដើម្បីឱ្យជីវិតមានអត្ថន័យខ្លឹមសារ។ ការអប់រំពេញមួយជីវិតជួយឱ្យបុគ្គលសម្រេចគោលដៅដែលខ្លួនចង់បាន។ អ្នកដែលទទួលយកការអប់រំពេញមួយជីវិតរមែងមិនបង្កើតហេតុផល ឬបង្កើតលេសសម្រាប់គោលដៅជីវិតរបស់ពួកគេឡើយ។ ដំណើរសម្រេចគោលដៅតាមរយៈការអប់រំពេញមួយជីវិត អាចមានលឿនយឺតបន្តិចមែន តែវាមិនខាតពេលនោះទេ ហើយវាកាន់តែប្រសើរសម្រាប់គុណភាពជីវិត និងវិជ្ជាជីវៈ ។

**៣. ការកែលម្អជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ ៖** វេជ្ជបណ្ឌិតជំនាញម្នាក់អាចបង្កើនចំណេះដឹងផ្ទាល់ខ្លួនលើប្រភេទជំងឺថ្មីៗ តាមរយៈការសិក្សាពេញមួយជីវិត។ ប្រសិនបើពឹងផ្អែកលើចំណេះដឹងពីអតីតកាលរបស់គាត់តែមួយមុខ វាប្រៀបដូចជាការបិទវិជ្ជាជីវៈខ្លួនឯងដូច្នេះដែរ។ ដូច្នេះការសិក្សាបន្ថែមលើចំណេះដឹងថ្មីៗនឹងជួយឱ្យវិជ្ជាជីវៈរបស់ខ្លួនកាន់តែប្រសើរ។ ក្រៅពីឧទាហរណ៍នេះ ការអប់រំពេញមួយជីវិតអាចឱ្យមនុស្សមានទំនាក់ទំនងកាន់តែប្រសើរ ហើយស្ថានភាពសុខភាពផ្លូវចិត្តក៏មិនងាយរងសម្ពាធដោយសារការវិវត្តរបស់វ័យ។ ការសិក្សាពេញមួយជីវិត គឺរៀនដើម្បីចំណេះធ្វើ និងរៀនដើម្បីរស់នៅជាមួយគ្នាប្រកបដោយសុខដុមនីយកម្មតាមបែបសង្គមស៊ីវិល័យជឿនលឿន។

**៤. បង្កើនទំនុកចិត្តលើខ្លួនឯង ៖** ក្បោទម្លាប់ទទួលយកការអប់រំពេញមួយជីវិតជួយឱ្យបុគ្គលមានចំណេះដឹង និងជំនាញកាន់តែច្បាស់លាស់ ហើយបង្កើតបានជាទំនុកចិត្តសម្រាប់ខ្លួនឯង។ អ្នកដែលមានចំណេះដឹងទូលំទូលាយ តែងមានទំនុកចិត្តលើការងារដែលខ្លួនកំពុងបំពេញ បើទោះបីកិច្ចការទាំងនោះលំបាកយ៉ាងណាក៏ដោយគឺធ្វើដោយទំនុកចិត្តជានិច្ច។ ទំនុកចិត្តដែលកើតចេញពីការសិក្សាពេញមួយជីវិតជួយឱ្យអ្នកដទៃ ឬមនុស្សជុំវិញខ្លួនទទួលយកផ្លែផ្កាពីគំនិតច្នៃប្រតិដ្ឋថ្មីៗរបស់បុគ្គល ព្រមទាំងចូលរួមអភិវឌ្ឍន៍សង្គមជាឱ្យរីកចម្រើនកាន់តែលឿនរហ័ស។

ខាងលើនេះជាកាសិក្សាស្រាវជ្រាវដែលគេបានរកឃើញថា ការសិក្សាពេញមួយជីវិតបានបណ្ដុះគុណតម្លៃមនុស្សឱ្យមានភាពជឿនលឿន និងប្រកបដោយទំនួលខុសត្រូវស្របតាមបរិបទសង្គមសេដ្ឋកិច្ចឌីជីថល។ ជាពិសេសមនុស្សដែលបានសិក្សារៀនសូត្របន្ថែមនឹងមិនធ្វើឱ្យខ្លួនឯងជាប់គាំងនៅក្នុងវិបត្តិនៃស្ថានការណ៍ជីវិតឡើយ។ ស្របដូចពាក្យមួយឃ្លាបានពោលថា «អ្នកមានចំណេះចិញ្ចឹមជីវិតបានយ៉ាងស្រួល»។ ដូចនេះក្នុងនាមជាពលរដ្ឋ យុវជន សិស្សានុសិស្ស គប្បីបន្តការសិក្សាពេញមួយជីវិតមិនថាតាមវិធីសាស្ត្រអ្វីក៏ដោយ។ ជាពិសេសប្រកាន់ស្មារតីថា «មានការសិក្សាធ្វើឱ្យយើងមានអនាគត មានការសិក្សាធ្វើឱ្យយើងមានក្ដីសង្ឃឹម»។

## គ. សិក្សាស្វែងយល់ពីកត្តាជីវភាព សង្គមសេដ្ឋកិច្ច នយោបាយ ការទូត វប្បធម៌ និងប្រវត្តិសាស្ត្រជាដើម

នៅក្នុងសម័យថ្មីនេះ អ្វីៗដើរលឿនខ្លាំងណាស់។ យើងមិនអាចមើលរំលងបានឡើយនូវកត្តាមួយចំនួនដូចជា កត្តាជីវភាព សេដ្ឋកិច្ច នយោបាយសាកល ពិភពលោកជាក់ស្ដែង។ កាលណាដែលយើងយកចិត្តទុកដាក់លើកត្តាទាំងអស់នេះនាំឱ្យយើងរស់បានសង្គមដោយស្រួលនឹងគេនឹងឯង។ មនុស្សយើងមានកត្តាជាច្រើនដែលត្រូវស្វែងយល់។ កាលណាយើងយល់ដឹងពីប្រការទាំងអស់នោះធ្វើឱ្យយើងអាចយល់ដឹងបានកាន់តែប្រសើរ ចេះត្រៀមខ្លួននឹងកត្តាប្រឈមនានាដែលកើតមាននៅក្នុងបរិការណ៍តំបន់ និងពិភពលោក។

យើងបានដឹងហើយថា នយោបាយសាកលលោកបាននិងកំពុងមានការប្រែប្រួលយ៉ាងខ្លាំង ព្រោះប្រឈមនឹងការប្រែប្រួលនៃអាកាសធាតុ សង្គ្រាមស៊ីវិល សង្គ្រាមភូមិសាស្ត្រនយោបាយក៏ដូចជាការប្រជែងឥទ្ធិពលពិភពលោករបស់មហាអំណាចជាដើម។ ជាក់ស្ដែងសង្គ្រាមរ៉ុស្ស៊ី-អ៊ុយក្រែន បានកំពុងតែបន្តអូសបន្លាយមិនទាន់ស្គាល់ឡើយពន្លឺនៃសន្តិភាព។ យើងពុំដឹងសោះឡើយថា តើសង្គ្រាមនេះនឹងបញ្ចប់នៅពេលណា? ហើយប្រព្រឹត្តទៅយ៉ាងដូចម្ដេច? ហើយបន្សល់ទុកនូវវិបត្តិអ្វីខ្លះសម្រាប់ជាតិ និងអន្តរជាតិ។ កាលពីមុន វិបត្តិជំងឺសាកលកូវីដ១៩ បានរីកសាយភាយពាសពេញពិភពលោក ហើយបានប៉ះពាល់សេដ្ឋកិច្ចពិភពលោកយ៉ាងក្រៃលែង។ ក្នុងនោះប្រទេសកម្ពុជាក៏បានរងផលប៉ះពាល់ដល់វិបត្តិសេដ្ឋកិច្ចយ៉ាងខ្លាំងផងដែរ។ ក្រោយពីការអូសបន្លាយនៃវិបត្តិសេដ្ឋកិច្ចស្រាប់តែមានសង្គ្រាមឈ្លានពានដែលកើតឡើងដោយសារតែប្រទេសរ៉ុស្ស៊ីបានធ្វើសង្គ្រាមជាមួយនឹងប្រទេសអ៊ុយក្រែន។ វិបត្តិនៃសង្គ្រាមបានធ្វើឱ្យពិភពលោកទាំងមូលរងក្ដីក្រៀមក្រំនៃសេដ្ឋកិច្ចកាន់តែយ៉ាប់យ៉ឺនជាងមុនទៅទៀត។ កត្តាសាំងឡើងថ្លៃ

ប្រកពថាមពល ឧស្ម័ន ហ្គាស អគ្គិសនី ពុំនោះសោតវិបត្តិស្បៀងអាហារបាននិងកំពុងកើតឡើងដូចគ្នា។ ដូចនេះយើងបានឃើញថា កាលណាប្រជាជនយើង ពលរដ្ឋយើងចេះស្វែងយល់ពីកត្តាទាំងអស់នេះ វាជាគុណតម្លៃមួយដ៏ថ្លៃថ្លាមិនអាចខ្វះបានសម្រាប់ជីវិតរបស់ខ្លួនផង និងប្រទេសជាតិផងដែរ។ ប្រសិនបើយើងក្រឡេកមកមើលរឿង ស៊ឹមអ្នកបរឡាន ដែលជាស្នាដៃនិពន្ធរបស់លោក អ៊ឹម ថុក បានលាតត្រដាងពីពូស៊ឹមដែលមានស្មារតីជឿនលឿនក្នុងជីវិត។ ថ្វីបើគាត់ជាអ្នកបរឡាន ប៉ុន្តែគាត់បានបណ្តុះស្មារតីឱ្យប្រជាជនទាំងឡាយអានសៀវភៅ អានកាសែត ដើម្បីទទួលបាននូវចំណេះដឹងថ្មីៗបន្ថែមទៀត។ លើសពីនេះផងដែរ គាត់មានគំនិតជឿនលឿនដោយមិនបណ្តោយឱ្យថៅកែប្រើគាត់តាមតែអំពើចិត្តឡើយ។ ពេលម៉ោងការងារត្រូវតែច្បាស់លាស់ ហើយប្រាកដនិយមផង។ ថៅហ្វាយនាយមិនអាចប្រើតែកុងឡានតាមតែអំពើចិត្តរបស់ខ្លួនឡើយ។ ពីព្រោះមនុស្សម្នាក់ៗមានសិទ្ធិគ្រប់គ្រាន់ក្នុងការសម្រាក និងឯកជនភាពផ្ទាល់។

ជាការពិតណាស់ នាសម័យឌីជីថលអ្វីៗដើរលឿនណាស់។ លុះត្រាតែយើងចេះសម្របសម្រួលខ្លួនគ្រប់បែបយ៉ាងដើម្បីឱ្យចូលចុះនៅក្នុងសង្គម។ ក្នុងន័យនេះ យើងបានដឹងហើយថា សម័យឌីជីថលមនុស្សត្រូវចេះស្គាល់ពីតម្រូវការនៃទីផ្សារជាក់ស្តែង ស្គាល់ពីកត្តាសង្គមជាក់ស្តែង។ ដូចអ្វីដែលយើងបានដឹងហើយថា សង្គមឥឡូវនេះដើរលឿនខ្លាំងណាស់។ កាលណាយើងអាចសម្របបាននោះវាសនាជីវិតរបស់យើងកាន់តែមានភាពជោគជ័យយ៉ាងត្រចះត្រចង់។

## ខ. ប្រភាន់ខ្ជាប់«អំណានគឺជាអំណាច»

ការអប់រំពេញមួយជីវិតជួយឱ្យគុណភាពជីវិតរីកចម្រើនស្របតាមបេត់សង្គមឌីជីថល។ យើងបានដឹងហើយថា ការអាននាំឱ្យយើងស្គាល់ពិភពលោកបានកាន់តែវែងឆ្ងាយ។ ពាក្យខ្មែរបានពោលថា អានច្រើន ចេះច្រើន ស្តាប់ច្រើន ដឹងច្រើន សរសេរច្រើន ធ្វើឱ្យយើងចេះប្រាកដ។ ត្រង់ន័យនេះ យើងឃើញថា កាលណាដែលយើងមានភាពរឹងមាំក្នុងចំណេះដឹង មានចំណេះពិតប្រាកដ ចេះពិតប្រាកដ យើងច្បាស់ជាមានជោគវាសនាល្អជាក់ជាមិនខានឡើយ។ ជាពិសេសក្នុងចំណោមមជ្ឈដ្ឋាននៃអ្នកស្រាវជ្រាវគប្បីមានការសិក្សា ការអានឱ្យបានច្រើនកាលណាល្អកាលហ្នឹង។

នៅពេលអាន គប្បីចេះកត់ត្រាទុកត្រង់ខ្លឹមសារសំខាន់ៗ។ ប្រការនេះ គេអាចបង្ហាញប្រភពឯកសារយោង ប្រភពពិតនៃព័ត៌មានដែលធ្វើឱ្យយើងមានភាពរឹងមាំសម្រាប់កិច្ចការស្រាវជ្រាវរបស់ខ្លួន។ ការអាន យើងអាចធ្វើនៅគ្រប់ទីកន្លែងដូចជាតាមបណ្ណាល័យ ហាងកាហ្វេ សាលារៀន នៅផ្ទះ ឬនៅតាមទី

កន្លែងណាដែលយើងគិតថា មានភាពសុខស្រួល ហើយផ្តល់ឱកាសឱ្យយើងក្រេបជញ្ជក់នូវពុទ្ធិទាំងឡាយនោះហើយជាអំណាចរបស់យើង។ ជាក់ស្តែង យើងបានឃើញថា អ្នកសិក្សាចូលចិត្តអានខ្លាំងណាស់។ កាលណាគេអានហើយ គេចេះកត់ត្រាទុករាល់ខ្លឹមសារសំខាន់ៗដែលមាននៅក្នុងឯកសារនោះ។ កាលណាមនុស្សនិយាយពីអ្វីមួយត្រូវមានឯកសារយោងជាក់លាក់ នោះជួយសម្រួលដល់ការវែកញែកឱ្យបានគត់មត់ និងច្បាស់លាស់ស្របតាមសង្គមសេដ្ឋកិច្ចតាមបែបឌីជីថល គេអាចអានតាមអ៊ីប៊ុក (E-book) ឬតាមរយៈបណ្ណាល័យអេឡិចត្រូនិក។ ជាក់ស្តែងតាមការសិក្សាប្រវត្តិសាស្ត្រខ្មែរ យើងឃើញថា អ្នកដែលបានលាតត្រដាងប្រាសាទអង្គរវត្តឱ្យពិភពលោកបានស្គាល់នោះ គឺជនជាតិបារាំង លោក ហង់រី មូហូតបានលាតត្រដាងឱ្យពិភពលោកស្គាល់សំណង់ស្ថាបត្យកម្មខ្មែរដ៏អស្ចារ្យគឺប្រាសាទអង្គរវត្តថាល្អអនេកអស្ចារ្យណាស់មិនចាញ់បណ្តាប្រទេសដែលមានអរិយធម៌ចំណាស់កាលពីបុរាណឡើយ។ លោកជាអ្នកប្រាជ្ញឆ្នើមដែលបានជួយផ្សព្វផ្សាយឱ្យអន្តរជាតិបានស្គាល់ប្រទេសកម្ពុជា។ នេះបានន័យថាដោយសារតែយើងបានអាន ទើបយើងបានស្គាល់អ្នកប្រាជ្ញជនជាតិបារាំងដែលបានរួមចំណែកកសាងស្នាដៃ ពោលគឺបន្សល់ទុកនូវឯកសារដ៏មានតម្លៃសម្រាប់ការសិក្សាស្រាវជ្រាវរបស់មនុស្សខ្មែរជំនាន់នេះបានដឹង និងសិក្សាស្វែងយល់បានយ៉ាងប្រសើរ។ ការអានធ្វើឱ្យយើងមើលឃើញពិភពលោកនេះបានកាន់តែវែងឆ្ងាយហើយចេះបត់បែនស្របតាមស្ថានការណ៍ជីវិតជាក់ស្តែង។ ស្របដូចពាក្យថា «អានខ្ញុំ ស្គាល់ពីពិភពលោកបានកាន់តែវែងឆ្ងាយ»។ ពុំនោះសោតយើងអាចនិយាយបានថា «អានខ្ញុំ ស្គាល់ពីជីវិត» ជាដើម។ ដូចនេះយើងគប្បីអានដើម្បីទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានការត្រៀមខ្លួនរៀបចំឱ្យបានកាន់តែប្រសើរនៅក្នុងជីវភាពប្រចាំថ្ងៃ និងរស់នៅសមស្របជាមនុស្សនាសតវត្សរ៍ទី២១។ ការអានបានបណ្តុះប្រាជ្ញាស្មារតី ខួរក្បាលមនុស្សឱ្យកាន់តែឆ្លាត និងរួមដោះស្រាយបញ្ហាប្រកបដោយភាពភ្លឺស្វាង។

ឆ្លងតាមសេចក្តីខាងលើនេះ ការអានបានជួយមនុស្សច្រើនណាស់។ ទីមួយកាលណាអាននាំឱ្យយើងមានការរីកចម្រើនផ្នែកប្រាជ្ញាស្មារតី។ ទីពីរជួយឱ្យយើងស្គាល់អ្វីដែលថ្មី និងចេះស្រង់យកបទពិសោធជីវិតថ្មីៗដើម្បីអភិវឌ្ឍជីវិតរបស់យើងឱ្យកាន់តែមានភាពលូតលាស់។ ទីបីជួយជំរុញបំណិនប៉ិនប្រសប់គ្រប់បែបយ៉ាងដែលនាំឱ្យមនុស្សមានការចេះដឹងសព្វគ្រប់សារពើ។ ដូចនេះពលរដ្ឋសាកលគប្បីអានដើម្បីតាមដានព័ត៌មាន យល់ដឹងពីព្រឹត្តិការណ៍ជាតិ អន្តរជាតិនៅលើសាកលលោក ហើយមធ្យោបាយងាយស្រួលគឺអានតាមរយៈអ៊ីប៊ុកដែលមានភាពងាយស្រួលមែនទែននាយុគសម័យឌីជីថលនេះ។

### II.៣.៣- តើតម្លៃមនុស្សសាកលមានអ្វីខ្លះនាយុគសម័យឌីជីថល?

## ក. បន្តការសិក្សាពេញមួយជីវិត នាយុគសម័យឌីជីថល

នៅសម័យទំនើបនេះ មនុស្សគ្រប់រូបគប្បីបន្តការសិក្សាពេញមួយជីវិត។ ពីព្រោះដូចយើងបានដឹងហើយថា ការសិក្សាពេញមួយជីវិតជាការសិក្សានាសតវត្សរ៍ទី២១។ សម័យនេះវិទ្យាសាស្ត្រដើរលឿនណាស់លឿនក្រៃលែង។ ប្រសិនបើយើងមិនដើរឱ្យទាន់សង្គមជាក់ស្តែងនោះទេ យើងច្បាស់ជាពិបាកជាក់ជាមិនខានឡើយ។ ការដើរឱ្យទាន់សង្គមបានន័យថា យើងជាមនុស្សសាកល ជាមនុស្សដែលស្របតាមពេលវេលា ពោលគឺស្គាល់កាលៈទេសៈជាក់ស្តែងជាក់ជាមិនខានឡើយ។

យើងប្រឹង យើងនឹងបានផលដូចអ្វីដែលស្នេរបានលើកឡើងពីខាងលើមកហើយ។ ការសិក្សាពេញមួយជីវិតគប្បីបន្តជានិច្ចមិនថាតាមវិធីសាស្ត្រអ្វីក៏ដោយ។ ពីព្រោះមានការសិក្សាធ្វើឱ្យយើងមានអនាគត មានការសិក្សាធ្វើឱ្យយើងមានក្តីសង្ឃឹម។ ត្រង់ន័យនេះយើងអាចនិយាយបានថា ការសិក្សាផ្តល់គុណតម្លៃធំធេងណាស់សម្រាប់ជីវិតមនុស្សគ្រប់រូប។ ការសិក្សាប្រៀបបានជាប្រទីបមួយជួយបំភ្លឺផ្លូវមនុស្សយើងឱ្យដើរចេញពីភាពខ្វាក់ងងឹតអាប់ឥតរស្មី។ ប្រសិនបើយើងមិនបានសិក្សានោះទេ តើយើងអាចធ្វើអ្វីបាន? ដូចនេះការសិក្សាបានជួយជំរុញឱ្យយើងមានស្នាមញញឹម មានពន្លឺនៅក្នុងឆាកជីវិត ហើយទទួលបាននូវការកោតសរសើរផងដែរ។ នៅក្នុងបរិបទនៃប្រទេសកម្ពុជាបច្ចុប្បន្នដែលបានផ្តល់តម្លៃដល់យុវជនកសាងឱកាស និងសមត្ថភាពសម្រាប់ការសិក្សា និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនលើគ្រប់វិស័យ។ នៅតាមក្រសួងស្ថាប័នរដ្ឋ និងឯកជន កម្លាំងយុវជនពិតជាមានសារៈសំខាន់ខ្លាំងណាស់ ជាកម្លាំងស្នូលជួយសង្គមយើងឱ្យបានឈានឡើងនូវការរីកចម្រើន និងឆាប់រហ័សទៀតផង។ យុវជនដើរបានលឿន រីឯចាស់ៗស្គាល់ផ្លូវ។ ត្រង់នេះជាប្រការមួយដែលយុវជនគប្បីដឹងថា យើងប្រឹងក្រេបជញ្ជក់ចំណេះដឹង ហើយស្រង់យកបទពិសោធល្អៗពីមនុស្សចាស់ជំនាន់មុន។ ក្នុងនាមយុវជនក្តី ប្រជាពលរដ្ឋទូទៅក្តីគប្បីសិក្សាពេញមួយជីវិតដើម្បីទទួលបាននូវអ្វីដែលថ្មីសម្រាប់កសាងជាតិ និងសង្គមជាតិយើងនាថ្ងៃអនាគតតរៀងទៅ។

យោងតាមន័យខាងលើនេះ យុវជនគប្បីដាក់ចិត្តដាក់ការសិក្សារៀនសូត្រដោយមិនបង្អង់ដោយលៃយ៉ាងណាស្រវាស្រទេញរៀនសូត្រគ្រប់កាលៈទេសៈ។ ដោយឡែកសម្រាប់ពលរដ្ឋវិញក៏ដូចគ្នាដែរ យើងអាចរៀនសូត្រផ្លាស់ប្តូរបទពិសោធទៅតាមជំនាញវិជ្ជាជីវៈរបស់យើង។ កាលណាដែលយើងអាចធ្វើបាន នោះនាំឱ្យយើងមានការលូតលាស់ទាំងផ្នែកប្រាជ្ញា និងស្មារតីគ្រប់ពេលវេលា។

## ខ. អភិវឌ្ឍវិជ្ជាជីវៈនាយុគសម័យឌីជីថល

នាយុគសម័យឌីជីថល បំណិនវិជ្ជាជីវៈជាអ្វីដែលយើងត្រូវការជាចាំបាច់។ ជាក់ស្តែងមនុស្សម្នាក់ៗមានសក្តានុពលរៀងៗខ្លួន។ ប្រសិនបើគេដឹងថា គេជាមនុស្សដែលមានសក្តានុពល គេគប្បីប្រឹងប្រែងធ្វើការសិក្សា ដោយការអភិវឌ្ឍជំនាញរបស់ខ្លួនបន្ថែមទៀត។ ការអភិវឌ្ឍជំនាញរបស់ខ្លួនបានផ្តល់នូវគុណតម្លៃដ៏ថ្លៃថ្លាសម្រាប់មនុស្ស ហើយឱ្យយើងមានឱកាសគ្រប់គ្រាន់ក្នុងការសិក្សារៀនសូត្របន្ថែមទៀត។ គ្រប់ជំនាញ គ្រប់បំណិន គ្រប់ឥរិយាបថទាមទារការអភិវឌ្ឍទាំងអស់។ ប្រសិនបើមិនបានអភិវឌ្ឍឱ្យបានជឿនលឿននោះទេ នោះមិនសូវរីកចម្រើនឡើយ។

អាស្រ័យហេតុនេះហើយ គេត្រូវរៀនសូត្របន្ថែមទៀតទើបមានអ្វីដែលថ្មីសម្រាប់ជីវិត និងការរស់នៅប្រកបដោយសុខដុមរមនា។ នាសម័យឌីជីថល នរណាដែលមិនបានអភិវឌ្ឍខ្លួន នោះច្បាស់ជាគាំង ឬទាល់ច្រកដោយប្រការណាមួយជាក់ជាមិនខានឡើយ។ ការរៀនសូត្របន្ថែមបានផ្តល់នូវគុណតម្លៃដ៏ថ្លៃថ្លាសម្រាប់មនុស្សនាសម័យទំនើប។ សម្រាប់ប្រទេសកម្ពុជា យើងត្រូវការធនធានមនុស្សដែលប្រកបដោយសក្តានុពល និងការអប់រំតាមបែបឌីជីថលដើម្បីសម្រេចបាននូវសេដ្ឋកិច្ចឌីជីថល។ កម្ពុជាត្រូវការធនធានមនុស្ស និងការអប់រំបែបឌីជីថលដើម្បីអនុវត្តគោលដៅសេដ្ឋកិច្ចឌីជីថលដែលជាតម្លៃមួយដ៏ថ្លៃថ្លា។ ជាការពិតណាស់ ឈានមួយជំហានពីយុគសម័យឧស្សាហកម្ម មកយុគសម័យបច្ចេកវិទ្យា និងឌីជីថល ប្រទេសទាំងអស់សុទ្ធតែបានមើលឃើញពីសារៈសំខាន់នៃការអនុវត្តសេដ្ឋកិច្ចឌីជីថលដែលជាផ្នែកយ៉ាងសំខាន់ក្នុងការជំរុញប្រទេសឱ្យអភិវឌ្ឍបានលឿនស្របទៅនឹងរបត់នៃបដិវត្តន៍ឧស្សាហកម្មជំនាន់ថ្មី។

សម្រាប់កម្ពុជាវិញ រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ក្នុងការជំរុញឱ្យមានគោលនយោបាយសេដ្ឋកិច្ចឌីជីថល ដើម្បីជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យស្របទៅនឹងបម្រែបម្រួលនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ និងទាញយកផលប្រយោជន៍កាន់តែច្រើនសម្រាប់ប្រជាជននៅទូទាំងប្រទេស។ តែទោះជាយ៉ាងនេះក្តី ដើម្បីអនុវត្តគោលដៅជាវិជ្ជមានទាំងអស់នេះបានល្អប្រសើរ កម្ពុជាត្រូវការធនធានមនុស្សជាច្រើនដើម្បីអនុវត្តសកម្មភាពនៅគ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍ។ ស្របទៅនឹងចំណុចទាំងអស់នេះហើយ ទើបក្រសួងអប់រំ និងស្ថាប័នពាក់ព័ន្ធក្តីបានលើកឡើងត្រង់ប្រការនេះដោយពោលថា «ដើម្បីឱ្យមានសេដ្ឋកិច្ចបែបឌីជីថល លុះត្រាតែយើងមានការអប់រំបែបឌីជីថល»។ ត្រង់ន័យនេះបានន័យថា ការអប់រំបែបឌីជីថល ឬអក្ខរកម្មឌីជីថលក្នុងបរិបទកម្ពុជានាសម័យឧស្សាហកម្ម ៤.០ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការកែ

ប្រែខ្លួនឱ្យក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចបែបឌីជីថល និងរដ្ឋាភិបាលឌីជីថល ព្រោះផ្នែកទាំងអស់នេះត្រូវការអ្នកជំនាញជាច្រើនដើម្បីបំពេញការងារនិងគ្រប់គ្រងប្រព័ន្ធឆ្លាតវៃទាំងអស់នោះ។

ឆ្លងតាមបំណកស្រាយខាងលើនេះ មនុស្សនាយុគសម័យឌីជីថលគប្បីសិក្សារៀនសូត្រ អភិវឌ្ឍជំនាញរបស់ខ្លួនតាមបែបបរិយាបន្ន ពោលគឺការអប់រំបញ្ចូលគ្នា ស្វែងយល់ពីអ្វីដែលថ្មី និងមានប្រយោជន៍សម្រាប់កសាងសង្គមជាតិនាថ្ងៃអនាគត។ ជាពិសេសក្នុងបរិបទកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់រាជរដ្ឋាភិបាលកម្ពុជាបានកសាងប្រទេសឱ្យជួបតែវិបុលសុខ សន្តិភាព និងការអភិវឌ្ឍក្រោមដំបូលនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយប្រជាជនកម្ពុជាពិតជាមានឱកាសខ្ពស់ណាស់។ ដូចអ្វីដែលយើងបាននិយាយដដែលជាដដែលថា សម័យនេះជាឱកាសមាសឱកាសប្រាក់ នរណាប្រឹងអ្នកនោះបានមិនថាការសិក្សា ឬការងារឡើយ។ ដូចនេះយើងគប្បីចេះចាប់យកឱកាស បង្កើតឱកាស និងឆក់យកឱកាសប្រៀបបានដូចជាត្រីងៀតឆ្លៀតពងក្នុងបរិបទសង្គមសេដ្ឋកិច្ចនាសម័យឌីជីថល។

## គ. បង្កើនកម្រិតគុណវុឌ្ឍិរបស់ខ្លួននាយុគសម័យឌីជីថល

ជាការពិតណាស់ សម័យនេះជាសម័យទំនើប ជាយុគសម័យឌីជីថលដែលវិទ្យាសាស្ត្រដើរលឿនសម្បើមណាស់។ បច្ចេកវិទ្យាកំពូលៗនៅលើពិភពលោកបានរីកលូតលាស់ដូចផ្សិត ហើយមានការអភិវឌ្ឍថ្មីៗបន្ថែមទៀតមិនអាចបដិសេធបានឡើយ។ យ៉ាងណាមិញ យើងបានឃើញថា បទពិសោធការងារមានហើយ អាចធ្វើបានហើយ ប៉ុន្តែយើងនៅទាមទារឱ្យមានការអភិវឌ្ឍកម្រិតនៃការយល់ដឹងបន្ថែមទៀតដើម្បីឱ្យទាន់សភាពការណ៍ជាក់ស្តែងក្នុងបរិបទជាតិ និងអន្តរជាតិ។

ជាក់ស្តែងប្រសិនបើយើងជាគ្រូបង្រៀន យើងគប្បីព្យាយាមអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យបានល្អប្រសើរតាមរយៈការបន្តការសិក្សាយកម្រិតសញ្ញាបត្រខ្ពស់ និងបច្ចេកវិទ្យាឱ្យបានល្អ។ យើងអាចប្រើប្រាស់ទូរស័ព្ទបានល្អដោយចេះប្រើប្រាស់នូវប្រព័ន្ធទាក់ទងបានល្អ ចេះបញ្ជូនឯកសារបានរហ័សជឿនលឿនតាមប្រព័ន្ធតេឡេក្រាម ឬបណ្តាញដទៃទៀតឱ្យបានឆាប់រហ័សទាន់សភាពការណ៍ជាក់ស្តែង។ ប្រសិនបើយើងមិនចេះ នោះយើងច្បាស់ជាពិបាកជាក់ជាមិនខាន។ នៅតាមស្ថាប័នការងារ យើងអាចប្រើប្រាស់កុំព្យូទ័របានងាយស្រួល បានរលូន ហើយប្រកបដោយភាពឆ្លាតវាងវៃផង។ ប្រសិនបើយើងមិនចេះប្រើប្រាស់ឱ្យបានស្រួលរលូននោះទេ យើងហាក់បីដូចជាពិការដៃម្ខាង ឬជួបភាពអវិជ្ជាលើប្រព័ន្ធបច្ចេកវិទ្យាជាក់ជាមិនខានឡើយ។ សម័យនេះ នរណាប្រឹង អ្នកហ្នឹងបាន។ ដូចនេះក្នុងនាមជាយុវជនក្តី និងជាពលរដ្ឋសាកល

គប្បីបង្កើនកម្រិតគុណវុឌ្ឍិរបស់ខ្លួនឱ្យបានល្អប្រសើរដើម្បីដើរឱ្យទាន់សភាពការណ៍ជាក់ស្តែងនាសម័យបច្ចុប្បន្ន។

ជាពិសេសយើងបានសង្កេតឃើញផងដែរថា ដើម្បីឆ្លើយតបជាមួយនឹងតម្រូវការធនធានមនុស្សផ្នែកឌីជីថល ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឱ្យមានសាលាជំនាន់ថ្មីដែលបញ្ចូលនូវកម្មវិធីសិក្សាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) និងការបណ្តុះបណ្តាលការសរសេរកូដ រួមទាំងកម្មវិធីសិក្សាដែលជាជំនាញទន់ជាច្រើនទៀតដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងសតវត្សទី២១។ លើសពីនេះទៅទៀត ក្រសួងក៏បានរៀបចំអប់រំចំណេះដឹងជាមូលដ្ឋានគ្រឹះសម្រាប់ការអប់រំដោយឆ្លើយតបជាមួយយុគសម័យបច្ចេកវិទ្យា តាមរយៈការធ្វើកំណែទម្រង់សាលារៀន និងកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ ដោយធ្វើយ៉ាងណាឱ្យភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់ផ្នែកបច្ចេកវិទ្យាមុននឹងចែករំលែកបន្តទៅដល់សិស្សានុសិស្សដែលជាធនធានមនុស្សជំនាន់ថ្មីរបស់យើង។ នាពេលបច្ចុប្បន្ននេះស្ថាប័នអប់រំនានានៅកម្ពុជាទាំងកម្រិតមធ្យមសិក្សា និងឧត្តមសិក្សាបានបញ្ចូលនូវរបៀបអប់រំ និងបច្ចេកវិទ្យាជាច្រើន ដើម្បីធ្វើការឆ្លើយតបបន្តិចម្តងៗទៅនឹងបរិបទនៃការអប់រំ ៤.0 ដោយរំពឹងទុកជាក់រយៈពេលពី៥ ទៅ ១០ឆ្នាំទៀត យើងអាចមានធនធានកាន់តែច្រើនដែលចេះប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការធ្វើការងារ ឬចូលរួមក្នុងការប្រកួតប្រជែងក្នុងទីផ្សារការងារសកល។ ឆ្លើយតបជាមួយនឹងបញ្ហានេះសិស្សានុសិស្ស ឬនិស្សិតដែលជាយុវជនក៏មានឱកាសច្រើនផងដែរក្នុងការសិក្សាឱ្យបានទូលំទូលាយពីបច្ចេកវិទ្យា ព្រោះយើងសុទ្ធតែមានធនធានគ្រប់គ្រាន់ផ្នែកបច្ចេកវិទ្យា ដោយស្ទើរតែគ្រប់គ្នាមានទូរស័ព្ទដៃស្មាតហ្វូនទំនើបៗ ព្រមទាំងមានប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅគ្រប់ទីកន្លែង។ លក្ខខណ្ឌនេះជាឱកាសក្នុងការទាញយកចំណេះដឹងដែលមានជុំវិញពិភពលោកដើម្បីអភិវឌ្ឍសមត្ថភាពខ្លួនឯង។ ហេតុនេះសិស្សនិស្សិតគួរចេះបង្វែរពេលវេលាពីការប្រើប្រាស់បណ្តាញសង្គមដ៏ច្រើនហួសហេតុមកស្វែងរកប្រភពចំណេះដឹងជាមូលដ្ឋានសម្រាប់បន្តអភិវឌ្ឍសមត្ថភាពក្នុងយុគសម័យឌីជីថលវិញទើបរាប់ថាជាការត្រៀមខ្លួនដ៏ល្អ។ ជាមួយគ្នានេះផងដែរ នៅក្នុងសង្គមការងារវិញ កម្ពុជាពិតជាត្រូវការធនធានមនុស្សដែលចេះប្រើប្រាស់បច្ចេកវិទ្យា ពោលគឺឌីជីថលដែលមានភាពទំនើបជឿនលឿនស្របទៅនឹងបរិការណ៍តំបន់ជាតិ និងអន្តរជាតិ។ កម្ពុជាត្រូវការធនធានមនុស្សជាច្រើនផ្នែកជំនាញបច្ចេកទេស និងបច្ចេកវិទ្យាដើម្បីចូលរួមចំណែកអភិវឌ្ឍលើកគ្រប់ផ្នែកទាំងអស់ក្នុងសង្គមនាពេលបច្ចុប្បន្ននេះ។ ហេតុនេះ ដើម្បីត្រៀមខ្លួនឱ្យបានល្អក្នុងការចូលរួមជាចំណែកយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងសម័យបច្ចេកវិទ្យាឌីជីថលនេះ

សិស្សនិស្សិតគួរងាកចំណាប់អារម្មណ៍មកសិក្សាផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឱ្យបានច្រើន។ ការសិក្សាទៀតសោត ក៏ចាំបាច់ត្រូវខិតខំប្រឹងប្រែងឱ្យបានស៊ីជម្រៅដើម្បីមានសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារការងារទាំងក្នុងប្រទេស និងក្នុងតំបន់ ព្រោះនៅក្នុងសេដ្ឋកិច្ចឌីជីថល ការប្រកួតប្រជែងកាន់តែមានលក្ខណៈទូលាយនៅគ្រប់តំបន់ទាំងអស់លើពិភពលោកស្របតាមសង្គមសេដ្ឋកិច្ចឌីជីថល។

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ មនុស្សខ្មែរគ្រប់ស្រទាប់វណ្ណៈគប្បីយល់ដឹងពីបរិបទសាកលពីប្រព័ន្ធទីផ្សារ ការប្រកួតប្រជែងក្នុងក្របខណ្ឌជាតិ អន្តរជាតិឱ្យបានជាក់លាក់ដែលជាចំណុចយុទ្ធសាស្ត្រស្នូលក្នុងការទាក់ទាញទីផ្សារ។ ជាពិសេសនាសម័យសព្វថ្ងៃផងនោះ ការប្រកួតប្រជែងកាន់តែមានភាពស្រួចស្រាល់ដែលកម្ពុជាជាសមាជិកអាស៊ាន ហើយដែលទាមទារធនធានមនុស្សខ្លាំងសម្រាប់ប្រកួតប្រជែងជាមួយនឹងបណ្តាប្រទេសនានាក្នុងយុគសម័យឌីជីថល។

## ឃ. មានការបណ្តុះបណ្តាលក្រមសីលធម៌វិជ្ជាជីវៈ

ជាការពិត មនុស្សយើងទោះបីជាយើងចេះដឹងយ៉ាងណាក៏ដោយ ប៉ុន្តែប្រសិនបើយើងខ្វះក្រមសីលធម៌វិជ្ជាជីវៈ នោះអ្វីៗស្មើសូន្យ។ ដូចនេះ ការសិក្សាស្វែងយល់បន្ថែមពីប្រការទាំងអស់នេះដែលអាចជួយលើកតម្លៃយើងឱ្យក្លាយជាបុគ្គលឆ្នើម បុគ្គលិកឆ្នើមក្នុងសង្គម និងពោរពេញដោយភាពឆ្លាតវៃ។

នៅតាមស្ថាប័នរដ្ឋ និងឯកជន គេតែងជួលគ្រូបង្គោលដើម្បីមកបណ្តុះបណ្តាលបុគ្គលិករបស់គេដើម្បីឱ្យបានការយល់ដឹងបន្ថែមទៀត។ គេអាចចូលរួមសិក្ខាសាលាឱ្យបានច្រើន ដើម្បីទទួលបានចំណេះដឹងថ្មីៗ ប្រកបដោយវិជ្ជាជីវៈ។ តួយ៉ាងនៅតាមស្ថាប័នសារព័ត៌មានធំៗ គេមានវគ្គសិក្សាបណ្តុះបណ្តាលអ្នកសារព័ត៌មានដើម្បីទទួលបាននូវវគ្គបំប៉នពិសេសដែលអាចជួយពួកគេបានល្អក្នុងពេលដែលពួកគេចេញទៅប្រកបវិជ្ជាជីវៈ។ ស្ថាប័នព័ត៌មានជាប្រភពមួយដែលផ្តល់នូវអំណាចយ៉ាងធំជូនប្រជាពលរដ្ឋ។ ដូចនេះការបណ្តុះបណ្តាលក្រមសីលធម៌វិជ្ជាជីវៈពិតជាមានសារៈសំខាន់ក្រៃលែង។ ការបណ្តុះបណ្តាលក្រមសីលធម៌វិជ្ជាជីវៈពិតជាមានសារៈសំខាន់។ ប្រសិនបើបុគ្គលិកគ្មានក្រមសីលធម៌វិជ្ជាជីវៈហើយ នោះនាំឱ្យអាប់ឱនស្ថាប័ន ប៉ះពាល់ ឬជះឥទ្ធិពលអវិជ្ជមានមកលើស្ថាប័នការងារជាក់ជាមិនខានឡើយ។

ដូចនេះ ការបណ្តុះបណ្តាលក្រមសីលធម៌វិជ្ជាជីៈពិតជាបានរួមចំណែកដល់ការរីកចម្រើនដល់អង្គភាព ស្ថាប័នរដ្ឋ ឬឯកជនជាក់ជាមិនខានឡើយ។ ក្នុងនាមជាពលរដ្ឋ បុគ្គលិកស្ថាប័ន ថ្នាក់ដឹកនាំគ្រប់ឋានានុក្រមគប្បីប្រកាន់យកឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈជាប្រចាំ។

## ខ. មានទឹកចិត្តនៃការចែករំលែក

គុណតម្លៃរបស់មនុស្សមួយទៀតគឺការចេះចែករំលែក។ នៅក្នុងសង្គមនេះ យើងត្រូវចេះជួយគ្នាទៅវិញទៅមក។ យើងមិនអាចរស់នៅម្នាក់ឯង ឬធ្វើខ្លួនជាកោះនោះឡើយ។ យើងគប្បីរៀនសូត្រពីគ្នាទៅវិញទៅមកលើគ្រប់វិស័យ។ កាលណាយើងបានរៀន យើងអាចស្វែងយល់ និងដឹងបាន ក្តាប់បានរាល់អ្វីៗដែលជាសេចក្តីត្រូវការរបស់មនុស្ស។ យើងចេះជួយគ្នាទៅវិញទៅមក។

យើងនៅចងចាំឃ្លាកំណាព្យមួយដែលដកស្រង់ពីច្បាប់ពាក្យចាស់បានពោលថា៖ « អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន។ អ្នកខ្ពស់រក្សាទាប ដោយសុភាពធម៌បុរាណ អ្នកឆ្អែតរក្សាឃ្លាន នាអ្នករុងរក្សាធ្មារ។ រក្សាទៅមុខវឹង ឥតកំដឹងអស់អម្បាល ចំណេរចេរកាន់កាលដូចរបងស្រាស់បន្លា។ កុំឆ្អែតពេកតែឯង ឱ្យគិតក្រែងដល់គ្នីគ្នា គេឃ្លានឃ្លានផ្ទៃផ្សា ឱ្យធីរ៉ាបានឆ្អែតផង»។ តាមរយៈកំណាព្យដកស្រង់ច្បាប់ពាក្យចាស់នេះ បានន័យថា កើតមកជាមនុស្សគប្បីចេះចែករំលែកគ្នាចែកគ្នារស់ ហើយចេះស្រឡាញ់គ្នាផង។ កាលណាយើងចេះជួយគេ គេក៏ជួយយើងវិញដែរ។ តែប្រសិនបើយើង មិនចេះជួយគេ តើឱ្យគេជួយយើងវិញយ៉ាងដូចម្តេចបាន? មនុស្សកើតមកទទេ ទៅវិញក៏ទទេដែរ។ ដូចនេះមានតែស្មារតីចែករំលែកគ្នា ចេះជួយគ្នាទៅវិញទៅមកនាំឱ្យយើងមានសេចក្តីសុខផង និងបានបុណ្យកុសលផង។ អាស្រ័យហេតុនេះហើយ ទើបនៅពេលដែលប្រទេសជាតិមានទុក្ខអាសន្នត្រូវការប្រមូលថវិកាជួយជនរងគ្រោះដោយការរលំបាក់អគារក្តី ទឹកជំនន់ក្តី ដោយជំងឺកូវីដ១៩ក្តី គេបានឃើញថាមានក្រុមអ្នកមានលុយ សប្បុរជនជាច្រើនទាំងក្នុងប្រទេស និងក្រៅប្រទេសតែងផ្តល់លុយដល់រាជរដ្ឋាភិបាលដើម្បីបានទិញសម្ភារៈ ជាធនធានក្តី លុយកាក់ថវិកាក្តី និងគ្រឿងឧបភោគបរិភោគក្តីដល់ជនរងគ្រោះឱ្យបានទាន់ពេលវេលា។ ពីព្រោះគ្រានោះជាគ្រាដ៏ចាំបាច់ជាទីបំផុតដែលការជួយទាំងអស់នេះរាប់ថាជាគុណធម៌ដ៏ថ្លៃថ្លា និងជាកាយវិការសប្បុរសធម៌ជាទីបំផុតដោយមិនត្រូវប្រកាន់លាបព័ណ៌សម្បុរ ឬរើសអើងដល់គ្នា និងគ្នាឡើយ។

## II.៣.៤- តើលក្ខណសម្បត្តិរបស់មនុស្សនាយុគសម័យឌីជីថលមានអ្វីខ្លះ?

## ក. សមត្ថភាព

មនុស្សនាសម័យឌីជីថលត្រូវមានសមត្ថភាពជាចាំបាច់។ សមត្ថភាពទាំងអស់នោះអាចសំដៅលើសមត្ថភាពជំនាញ បច្ចេកទេស ជំនាញវិជ្ជាជីវៈ និងសមត្ថភាពនៃការប្រើប្រាស់ភាសាអន្តរជាតិណាមួយ

ច្បាស់លាស់ជាដើម។ មនុស្សដែលមានសមត្ថភាពអាចចិញ្ចឹមជីវិតបានយ៉ាងងាយស្រួល។ ហើយវាកើតឡើងតាមរយៈការសិក្សារៀនសូត្រគ្រប់កម្រិតទាំងអស់។ អ្វីក៏ដោយទាល់តែយើងរៀនសូត្រទើបធ្វើឱ្យយើងចេះដឹងបាន។ បើយើងមិនរៀនសូត្រនោះទេ យើងមិនអាចសម្រេចបាននូវការចេះដឹងរបស់ខ្លួននោះទេ។ ដូចនេះទាំងអ្នកបច្ចេកទេសក្តី ទាំងអ្នកសិក្សាក្តី ពលរដ្ឋក្តីត្រូវរៀនសូត្រជាប់ជាប្រចាំ។ ជាពិសេសនាសម័យឌីជីថលនេះ ការងារអ្វីក៏ដោយ កិច្ចការអ្វីក៏ដោយគឺទាមទារឱ្យមានការស្វែងយល់បន្ថែមទៀតដើម្បីទទួលបាននូវការចេះដឹងបន្ថែមទៀត។

### ខ. លទ្ធភាព

មនុស្សសម័យនេះ គប្បីមានលទ្ធភាពដែលយើងសំដៅលើកត្តាសេដ្ឋកិច្ច។ លទ្ធភាព បានន័យថាភាពដែលអាចធ្វើបាន ភាពដែលអាចសម្រេចបានក្នុងផ្លូវជីវភាពរបស់ខ្លួន។ មនុស្សដែលមានលទ្ធភាពក្នុងការធ្វើអ្វីមួយត្រូវមានធនធានគ្រប់គ្រាន់ ឬជាការសន្សំធនធានទុកបម្រុងក្នុងការធ្វើអ្វីមួយ។ ត្រង់ន័យនេះផងដែរ យើងអាចឃើញថា ដើម្បីអាចមានលទ្ធភាពបាន លុះត្រាតែមនុស្សមានសមត្ថភាពជាក់លាក់ជំនាញច្បាស់លាស់ ។ ស្របដូចពាក្យមួយឃ្លាបានពោលថា«មនុស្សដែលមានចំណេះ អាចចិញ្ចឹមជីវិតបានដោយស្រួល»។ ដូចនេះការមានលទ្ធភាពជាចំណុចមួយដែលជួយឱ្យជីវិតយើងកាន់តែសក្តានុពល។ នាយុគសម័យឌីជីថល យុវជនក្តី ពលរដ្ឋក្តីគប្បីស្វែងយល់ឱ្យបានល្អប្រសើរស្តីពីការរស់នៅក្នុងបរិបទថ្មីនាសម័យវិទ្យាសាស្ត្រទំនើប។

### គ. សម្ពន្ធភាព

នៅក្នុងសង្គមដើម្បីឱ្យមានភាពលេចធ្លោទៅបានអាស្រ័យទៅលើការមានទំនាក់ទំនងល្អជាមួយនឹងមនុស្សជុំវិញ។ ជាក់ស្តែងនៅក្នុងសង្គមការងារ មនុស្សគប្បីមានទំនាក់ទំនងល្អជាមួយមិត្តរួមការងារ ហើយអាចជំរុញឱ្យការងាររលូន ធ្វើអ្វីមួយបានឆាប់រហ័ស។ ប្រការនេះយើងឃើញថា សម្ពន្ធភាពពិតជាមានសារៈសំខាន់ក្រៃលែងពីព្រោះវាបានជួយឱ្យមនុស្សមានចំណងសាមគ្គីភាពជាមួយនឹងមនុស្សទាំងឡាយនៅក្នុងសង្គមជាក់ស្តែង។ ជាក់ស្តែងនៅក្នុងស្ថាប័នការងារ មិនថារដ្ឋ ឬឯកជននោះទេ កាលណាមានចំណងទាក់ទងល្អជាមួយនឹងមនុស្សជុំវិញ ជាមួយថ្នាក់ដឹកនាំ ជាមួយមិត្តរួមការងារ នោះគេអាចជួយយើងបានច្រើនណាស់ មានកិច្ចការអ្វីមួយគឺយើងអាចពឹងពាក់គ្នាទៅវិញទៅមក។ ដូចនេះនាសម័យនេះហើយយើងត្រូវមានសម្ពន្ធភាពឱ្យបានល្អជាមួយនឹងមិត្តរួមការងារ ឬទំនាក់ទំនងជាប្រព័ន្ធនៅក្នុងជីវភាពរស់នៅ។

**ឃ. អត្តចរិត**

ត្រង់ចំណុចនេះបានដល់ការចេះរក្សាតម្លៃអត្តចរិតរបស់ខ្លួនឱ្យបានល្អ។ មនុស្សដែលមានសីលធម៌ល្អ មានអត្តចរិតមិនឡេះឡោះ ធ្វើឱ្យគេស្រឡាញ់ចូលចិត្តច្រើន គេនឹងលើកមុខមាត់ឱ្យមានកិត្តិយសនៅក្នុងអង្គភាព ឬចង្កោមការងារ។ ផ្ទុយមកវិញ ប្រសិនបើគេមិនចេះបត់បែន មានអត្តចរិតខ្ជិលច្រអូស ឡេះឡោះ នាំឱ្យគេវាយតម្លៃ ប្រមាថមើលងាយជាក់ជាមិនខានឡើយ។ ជាការកត់សម្គាល់ អត្តចរិតយើងកត់សម្គាល់លើ អត្តចរិតការងារ និងអត្តចរិតក្នុងជីវភាពប្រចាំថ្ងៃ។ ដើម្បីជាទីគោរពស្រឡាញ់ និងជាទីពេញចិត្តសម្រាប់មនុស្សផងគ្នា គេអាចប្រកាន់យកចរិតដូចជា ពិតប្រាកដ ទៀងទាត់ គ្រប់គ្រាន់ និងទាន់ពេលវេលា។ នេះជាអត្តចរិតមួយសម្រាប់បុគ្គលដែលមានគោលបំណងជាបុគ្គលិកឆ្នើមនៅក្នុងអង្គភាពក៏ដូចជាស្ថាប័នរបស់ខ្លួន។ លើសពីនោះមានកត្តាជាច្រើនទៀតដូចជាមានទំនាក់ទំនងក្នុងសង្គម ការលើកទឹកចិត្ត មានវិធីសាស្ត្រ មានការតាំងចិត្ត មានសេចក្តីព្យាយាម រក្សាតម្លៃគុណធម៌ជាប្រចាំ និងមានភាពជាអ្នកដឹកនាំជាដើម។ ត្រង់នេះហើយជាលក្ខណសម្បត្តិរបស់មនុស្សនាយុគសម័យឌីជីថល។

ដូចនេះ លក្ខណសម្បត្តិទាំងអស់នេះក៏ជាផ្នែកមួយនៃជោគជ័យជីវិតរបស់បុគ្គលផងដែរ។ ដើម្បីសម្រេចបាននូវភាពជោគជ័យដ៏ត្រចង់នាសម័យសង្គមសេដ្ឋកិច្ចឌីជីថល មនុស្សគ្រប់ស្រទាប់វណ្ណៈគប្បីប្រឹងប្រែងសិក្សារៀនសូត្រ ក្រេបជញ្ជក់នូវចំណេះដឹងសព្វសារពើតាមរយៈការស្រាវជ្រាវ អភិវឌ្ឍចំណេះដឹងរបស់ខ្លួនគ្រប់កាលៈទេសៈ។

## II.៣.៥- តើតម្លៃមនុស្សដែលប្រកបដោយមនសិការវិជ្ជាជីវៈមានអ្វីខ្លះ?

### II.៣.៥.១. មានសមត្ថភាពលើជំនាញវិជ្ជាជីវៈរបស់ខ្លួន

បុគ្គលិក មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ គប្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនទៅតាមវិស័យរបស់ខ្លួន។ គ្រូបង្រៀនដែលអាចបង្រៀនសិស្សទៅបានគឺអាស្រ័យលើទីតាំងបណ្តុះបណ្តាលមានគុណភាព ប្រកបទៅដោយទំនុកចិត្តខ្ពស់។ ពោលគឺគេបានបង្កើតសាលាគរុកោសល្យដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈគ្រូបង្រៀនតាំងពីកម្រិតមត្តេយ្យសិក្សា រហូតដល់ថ្នាក់គ្រូកម្រិតឧត្តម។ រីឯមន្ត្រីរាជការស៊ីវិលដទៃទៀតដែលធ្វើការនៅតាមសាលាខេត្ត រដ្ឋបាលខេត្ត ឬស្ថិតក្រោមចំណុះអង្គភាព មន្ទីរ ក្រសួងមហាផ្ទៃ គេមកសិក្សានៅសលាភូមិន្ទរដ្ឋបាលដែលជាកន្លែងមួយបណ្តុះបណ្តាលជំនាញវិជ្ជាជិវៈដ៏សំខាន់សម្រាប់បណ្តាមន្ត្រីទាំងអស់នោះ

មុនពេលចេញទៅបំពេញបេសកកម្ម។ ត្រង់នេះជាគុណតម្លៃមួយសម្រាប់មន្ត្រីរាជការដែលត្រូវសិក្សារៀនសូត្រ និងដុសខាត់លើជំនាញរបស់ខ្លួន។

### II.៣.៥.២. អភិវឌ្ឍបំណិនសមត្ថភាពជំនាញវិជ្ជាជីវៈរបស់ខ្លួនជាប្រចាំ

ការរៀនសូត្រជាប្រចាំ ការសិក្សាពីអ្វីៗដែលថ្មីៗ និងពោរពេញដោយសក្តានុពលជាអ្វីដែលយើងគប្បីគិតគូរពិចារណា។ ប្រសិនបើយងអាងថាខ្លួនចេះហើយ មិនរៀនសូត្របន្ថែម នោះជាការខុសឆ្គងមួយជាក់ជាមិនខានឡើយ។ ត្រង់នេះហើយ ទើបយើងគប្បីសិក្សាបន្ថែម រៀនសូត្របន្ថែម ដើម្បីឱ្យការងាររបស់យើងកាន់តែរលូន និងពោរពេញដោយនវានុវត្តន៍។ មែនទែនទៅ ការបើកវគ្គសិក្ខាសាលា កម្មសិក្សាទស្សនកិច្ចសិក្សាដោយផ្សារភ្ជាប់នឹងការអនុវត្តជាក់ស្តែងជួយច្រើនណាស់ដល់ការរីកលូតលាស់ផ្នែកប្រាជ្ញាស្មារតី ចំណេះដឹងរបស់មនុស្ស។ ដូចនេះគ្រប់ស្ថាប័ន អង្គភាព បុគ្គលិកមន្ត្រីរាជការទាំងអស់ គប្បីទទួលបានវគ្គបណ្តុះបណ្តាលសមស្របតាមជំនាញរបស់ខ្លួនស្របតាមសង្គមសេដ្ឋកិច្ចឌីជីថល។ ស្ថិតក្នុងបរិបទនៃជំងឺកូវីដ១៩ គេអាចប្រជុំតាមអនឡាញ អានឯកសារសំខាន់ៗ ចុះហត្ថលេខា ឬកិច្ចព្រមព្រៀងតាមប្រព័ន្ធអនឡាញ។ ដោយឡែកនៅសាលារៀនក្តី ការគ្រប់គ្រងបុគ្គលិកក្តី វត្តមានក្តី គេអាចប្រើប្រាស់ការគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាដែលក្តាប់បាននូវវត្តមាន របាយការណ៍ ចំណូលចំណាយជាដើម។ នេះហើយជាគុណតម្លៃនៃបច្ចេកវិទ្យាព័ត៌មានដែលបុគ្គលិក មន្ត្រីរាជការគប្បីសិក្សារៀនសូត្របណ្តុះបណ្តាលបន្ថែមឱ្យកាន់តែមានភាពរលូនជានិច្ច។

### II.៣.៥.៣. មានជំនាញទន់

ជាគុណតម្លៃរបស់មនុស្សដែលគប្បីមានជំនាញទន់ សិក្សារៀនសូត្រស្វែងយល់ពីជំនាញទន់បន្ថែមទៀត។ ពីព្រោះថាក្រៅពីសមត្ថភាពរបស់ខ្លួន គេគប្បីស្វែងយល់ពីជំនាញទន់ដែលសំដៅទៅលើភាពរួសរាយរាក់ទាក់ ទំនាក់ទំនងល្អនៅក្នុងសង្គម ហើយជួយជំរុញឱ្យមនុស្សកាន់តែមានសក្តានុពល។

ត្រង់នេះបានន័យថា បុគ្គលគ្រប់រូបនាសម័យឌីជីថលគប្បីហ្វឹកហាត់ស្វែងយល់លើជំនាញនេះឱ្យបានកាន់តែប្រសើរ មានការសិក្សាស្វែងយល់បន្ថែមទៀតដើម្បីឱ្យខ្លួនកាន់តែប្រសើរឡើង។ ពិសេសទៀតនោះ ជំនាញទន់បានជួយហ្វឹកហាត់ដុសខាត់រាល់ការងាររបស់ខ្លួន ធ្វើខ្លួនពេញជាទីទុកចិត្តរបស់អ្នកដទៃ។ សកម្មភាពទាំងឡាយដែលនាំឱ្យខ្លួនយល់ដឹងបានច្រើនជាងមុន សិក្សាស្វែងយល់បានកាន់តែប្រសើរជាងមុន ហើយពោរពេញដោយឥទ្ធិពលទាក់ទាញនៅក្នុងសង្គមមនុស្ស។ ជំនាញទន់ជាអ្វីដែលយើងមិនអាច

មើលរំលងបាន។ កត្តាមួយចំនួននៅក្នុងជីវិត ភាពជោគជ័យជាដើមក៏អាស្រ័យលើជំនាញទន់នេះផងដែរ។ ការចេះដាក់ខ្លួន ការចេះគោរព និងឱ្យតម្លៃអ្នកដទៃ ការមានប្រាស្រ័យទាក់ទងល្អជាមួយនឹងមនុស្សដែលនៅជុំវិញខ្លួនជាប្រការមួយមិនអាចខ្វះបាន ជួយយើងឱ្យមានកិត្យានុភាពកាន់តែប្រសើរនៅក្នុងចង្កោមការងាររបស់ខ្លួន។ ដូចនេះមនុស្សគ្រប់រូបគប្បីសិក្សាស្វែងយល់បន្ថែមទៀត ហើយពង្រីកការយល់ដឹង និងចេះស្គាល់ពេលវេលា។ ការស្គាលទីតាំងការងារជាក់ស្តែង ការស្គាល់ទីតាំងបុគ្គលជាក់ស្តែង ការស្គាល់អ្វីៗដែលនៅជុំវិញយើងជាចំណុចចាប់ផ្តើមនៃភាពជោគជ័យបុគ្គល។ ឧទាហរណ៍ប្រសិនបើយើងជាអ្នករកស៊ីជាអាជីវករ ឬជាអ្នកអ្នកជំនួញ យើងត្រូវមានជំនាញទន់ជាចាំបាច់ដើម្បីរកស៊ីទាក់ទាញអតិថិជនគ្រប់ទិសទីឱ្យមករកស៊ីជាមួយនឹងយើង សហការការងាររកស៊ីជាមួយនឹងយើងជាដើម។ ជំនាញទន់អាចថាជាឧបនិស្ស័យមួយដែលមានសារៈសំខាន់ជាទីបំផុតសម្រាប់ជីវិតរបស់បុគ្គលគ្រប់រូប។ មនុស្សដែលមានជំនាញទន់ពោរពេញដោយភាពឆ្លាតវាងវៃ មានភាពបត់បែន មានស្មារតី និងឆន្ទៈច្បាស់លាស់ដុសខាត់រាល់ភាពមន្ទិលសៅហ្មងទាំងឡាយ។ ប្រការមួយទៀត ជំនាញទន់នាំឱ្យមនុស្សមានសាមគ្គីភាពល្អនៅក្នុងចង្កោមការងារ សហការបានល្អ កិច្ចការងារកាន់តែប្រសើរ និងពោរពេញដោយមនសិការវិជ្ជាជីវៈ។ អាស្រ័យហេតុនេះហើយ ទើបនៅតាមស្ថាប័នរដ្ឋក្តី ឯកជនក្តី សាលារៀន ក្រុមហ៊ុន អង្គការ បានជួលគ្រូបង្គោលជំនាញបណ្តុះបណ្តាលផ្នែកជំនាញទន់ឱ្យមកជួយដុសខាត់ព្រលឹងស្មារតីការងារដល់បុគ្គលិកផ្តល់វិធីសាស្ត្រល្អៗ និងលើកទឹកចិត្តដល់បុគ្គលិកជាដើម។

ដូចនេះ ជំនាញទន់ក៏ជាផ្នែកមួយនៃភាពជោគជ័យជីវិតការងារ គ្រួសារ និងសង្គមជាតិផងដែរ។ ជំនាញទន់បានរួមចំណែកដល់ការកសាងធនធានមនុស្សដ៏មានសក្តានុពលនៅតាមស្ថាប័នការងារក៏ដូចជាបណ្តុះបណ្តាលបុគ្គលិកលក្ខណៈឱ្យមានស្មារតីសាមគ្គីភាពជាក្រុម។

### II.៣.៥.៤. មានជំនាញរឹង

បុគ្គលគ្រប់រូបដែលកើតមកនៅក្នុងលោកសន្និវាសទាំងមូលមិនមាននរណាកើតមកចេះឯងៗឡើយរមែងត្រូវការសិក្សារៀនសូត្រនូវជំនាញណាមួយជាក់លាក់។ ពោលគឺកើតឡើងដោយការសិក្សារៀនសូត្រទាំងអស់គ្នា។ អាស្រ័យហេតុនេះហើយ ទើបមនុស្សនាយុគសម័យថ្មីនេះគប្បីស្វែងរកជំនាញណាមួយឱ្យបានជាក់លាក់ដើម្បីចិញ្ចឹមផ្ទាំងរបស់ខ្លួនដែលគេហៅថា ជំនាញរឹងនោះឯង។

ជំនាញរឹងបានដល់ជំនាញវិជ្ជាជីវៈណាមួយដែលសមស្របទៅនឹងឧបនិស្ស័យណាមួយដូចជា វិទ្យាសាស្ត្រពិត ឬវិទ្យាសាស្ត្រសង្គមជាដើម។ វិទ្យាសាស្ត្រពិតរួមមានម គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ធម្មជាតិវិទ្យា វិជ្ជាពេទ្យ មេកានិក ជំនាញអគ្គិសនី ជំនាញបរមាណូវិទ្យាជាដើម។ វិជ្ជាទាំងអស់នេះបម្រើដល់ជីវិតនាសម័យទំនើបជាក់ស្តែង។ ប្រសិនបើគេបានសិក្សាស៊ីជម្រៅ គេអាចដោះស្រាយបញ្ហាជីវិតបានយ៉ាងងាយស្រួល និងរស់នៅប្រកបដោយសុភមង្គលទៅតាមភាពមានបានរបស់គេម្នាក់ៗ។ ប្រការមួយទៀតវិទ្យាសាស្ត្រពិត ត្រង់នេះជាការបែងចែកដោយប្រព័ន្ធនៃការសិក្សាសាលាទំនើប។ វិទ្យាសាស្ត្រសង្គមបានដល់ អក្សរសាស្ត្រខ្មែរ ភាសាវិទ្យា ប្រវត្តិវិទ្យា សង្គមវិទ្យា ទស្សនវិទ្យា ចិត្តវិទ្យា នីតិសាស្ត្រ រដ្ឋបាល នយោបាយ វិទ្យាសាស្ត្រនយោបាយ ការទូត ទីផ្សារជាដើមដែលសុទ្ធសឹងតែបម្រើដល់សង្គមមនុស្សដូចគ្នាទាំងអស់។ បានសេចក្តីថា ទាំងវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គមរមែងបំពេញឱ្យគ្នាទៅវិញទៅមក និងតម្រូវឱ្យមានការសិក្សាស្វែងយល់ឱ្យបានទូលំទូលាយ។ នៅត្រង់ចំណុចនេះ យើងបានដឹងហើយថា ការសិក្សាជួយមនុស្សច្រើនណាស់។ ដូចនេះ មនុស្សនាសម័យនេះគប្បីជ្រើសរើសយកជំនាញណាមួយដែលខ្លួនគិតថា សមស្របទៅនឹងនិស្ស័យរបស់ខ្លួន និងព្យាយាមអភិវឌ្ឍវាបន្តិចម្តងៗដើម្បីឈានឆ្ពោះទៅរកភាពរីកចម្រើននៅក្នុងសង្គម។ ក្រៅពីវិទ្យាសាស្ត្រពិត និងសង្គមដែលមាននៅក្នុងកម្មវិធីសិក្សាជាតិ យើងមានជំនាញដទៃទៀតបានដល់ជំនាញបច្ចេកទេស ជំនាញជួសជុលម៉ូតូ ឡាន យានយន្តគ្រប់ប្រភេទដែលជាទីត្រូវការក្នុងជីវភាពប្រចាំថ្ងៃ។ ជំនាញជួសជុលម៉ាស៊ីនត្រជាក់ ជំនាញខាងសំណង់ និងការបម្រើខាងសេវាដទៃទៀតដែលជាជំនាញរឹងជួយជំរុញឱ្យមនុស្សមានភាពជឿនលឿននៅក្នុងផ្លូវជីវិត។ សម័យនេះប្រសិនបើយើងមិនរិះរកជំនាញណាមួយឱ្យបានច្បាស់លាស់នោះទេ នោះជីវិតច្បាស់ជាប្រឈមនឹងបញ្ហាជាច្រើន។ ជីវិតមានកត្តាជាច្រើន។ កាលណាដែលយើងមានជំនាញរឹងច្បាស់លាស់ យើងអាចចិញ្ចឹមជីវិតបានយ៉ាងងាយស្រួល សម្បូរទីផ្សារ ទៅណាក៏មានបណ្តាញទំនាក់ទំនងហើយងាយស្រួលក្រៃលែងក្នុងការរស់នៅ។ ដូចនេះហើយទើបលោកតាក្រមង៉ុយ បានពោលថា « បើចេះប្រាកដ ប្រាក់រត់តាមហៅ» ឬពុំនោះសោតលោកពោលថា «កុំដេកតែខ្លៅ ក្រក្រៅសណ្តាប់»ជាដើម។ ត្រង់នេះលោកចង់ដាស់តឿនដល់កូនខ្មែរឱ្យប្រឹងប្រែងតស៊ូកុំឱ្យក្លាយខ្លួនជាកញ្ជះគេ ពោលគឺកញ្ជះចិន យួន និងបារាំងសែស នាសម័យនោះជាដើម។ ពាក្យពេចន៍លោកតាង៉ុយពោរពេញដោយអត្ថន័យក្រៃលែង។

ដូចនេះ មនុស្សគ្រប់រូបគប្បីមានជំនាញរឹងច្បាស់លាស់ដើម្បីចិញ្ចឹមជីវិតបានរស់ស្រួលស្របតាមសង្គមសេដ្ឋកិច្ចឌីជីថល។

### II.៣.៥.៥. ជំនាញភាសាអន្តរជាតិណាមួយច្បាស់លាស់

ជាការពិត នាសម័យនេះការចេះភាសាអន្តរជាតិណាមួយច្បាស់លាស់ជួយយើងច្រើនណាស់។ តើនរណាមួយដែលថា ខ្លួនមិនចេះភាសាបរទេស? កាលណាដែលយើងមិនចេះភាសាអន្តរជាតិណាមួយ ជាក់លាក់ធ្វើឱ្យយើងបាត់បង់ឱកាស ឬឱ្យយើងមុជមិនជ្រៅទៅមិនឆ្ងាយ។ អ្នកសិក្សាគ្រប់រូប អ្នកជំនាញទាំងឡាយដែលអាចស្រាវជ្រាវបានច្រើន ឬសិក្សាបានវែងឆ្ងាយត្រូវចេះភាសាអន្តរជាតិជាចាំបាច់។

ជាក់ស្តែងសម្តេច ជួន ណាត ដែលជាអ្នកប្រាជ្ញអក្សរសាស្រ្តខ្មែរដ៏ឆ្នើមទាំងផ្លូវលោក និងផ្លូវធម៌ សម្តេចចេះភាសាបរទេសច្រើនណាស់។ តាមការសិក្សាស្រាវជ្រាវ យើងបានដឹងថាភាសានៅអាស៊ីអាគ្នេយ៍ទាំងមូល លោកអាចប្រើប្រាស់ប្រាស្រ័យទាក់ទងបានយ៉ាងស្ទាត់ជំនាញ ហើយមានរាជបន្ទូលប្រកបដោយសូរស័ព្ទស្រដៀងនឹងជាតិសាសន៍ដើមរបស់គេផង។ ក្រៅពីនោះក្រៅពីភាសាបាលី សំស្ក្រឹត លោកអាចប្រើប្រាស់ភាសាបារាំង អង់គ្លេស និងមគធភាសាឥណ្ឌាបានយ៉ាងល្អប្រសើរ។ ត្រង់នេះហើយដែលអ្នកសម័យនេះគប្បីចេះភាសាបរទេសឱ្យបានច្រើនកាលណា ល្អកាលហ្នឹង។ ប្រសិនបើយើងមិនរៀនភាសាបរទេសនោះទេ យើងនឹងបាត់បង់ឱកាសល្អៗជាក់ជាមិនខានឡើយ។ សម័យនេះទៀតសោត បើនិយាយពីកម្ពុជាវិញ ជាសមាជិកអាស៊ាន និងជាសមាជិកនៃអង្គការសហប្រជាជាតិ ការចេះភាសាអន្តរជាតិណាមួយច្បាស់លាស់នោះជួយសម្រួលដល់បណ្តូរសេដ្ឋកិច្ចសាកល។ ការចេះភាសាអន្តរជាតិណាមួយច្បាស់លាស់ជួយឱ្យយើងអាចតាមដានស្ថានការណ៍ស្រុកទេស ស្ថានការណ៍ពិភពលោកដែលបាននិងកំពុងវិវត្តទៅយ៉ាងលឿងស្លេវជាទីបំផុត។ យើងអាចស្រាវជ្រាវ អាន និងវិភាគពីស្ថានការណ៍ពិភពលោកបានយ៉ាងងាយស្រួល និងប្រកបដោយភាពគត់មត់ផងដែរ។ ពុំនោះសោតជួយឱ្យយើងក្លាយជាពលរដ្ឋសាកលពេញលក្ខណៈពិតប្រាកដ។

ដូចនេះ មនុស្សគ្រប់រូបត្រូវមានជំនាញរឹង ជំនាញទន់ និងចេះភាសាអន្តរជាតិណាមួយច្បាស់លាស់ពិតប្រាកដដើម្បីចិញ្ចឹមជីវិតដោយស្រួល។ ស្របដូចពាក្យកវីម៉ុយពោលថា «បើចេះប្រាកដប្រាក់រត់តាមហៅ»។ ទន្ទឹមនឹងមានជំនាញហើយ បុគ្គលគប្បីមានសីលធម៌ សុជីវធម៌ និងគុណធម៌ផងដែរ ទើបមានកិត្យានុភាព កេរ្តិ៍ឈ្មោះក្រអូបផ្ទរផង់គួរជាទីស្រឡាញ់ពីមនុស្សជុំវិញ។

## ៦. ជំនាញបច្ចេកវិទ្យា កុំព្យូទ័រ ទូរស័ព្ទឆ្លាតវៃ ។ល។

ជាគុណតម្លៃ ការចេះជំនាញបច្ចេកវិទ្យារួមមានបច្ចេកវិទ្យាទំនើបៗ ឌីជីថល ទូរស័ព្ទដៃ កុំព្យូទ័រជាដើមជួយសម្រួលការងារយើងសម្បើមណាស់។ នាសម័យនេះ ប្រសិនបើយើងមិនចេះប្រើប្រាស់នូវអ្វីដែលបានលើកឡើងនេះ នោះយើងមានឈ្មោះថាដូចពិការដៃជូច្នោះដែរ។ ការចេះប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ទូរស័ព្ទដៃ កុំព្យូទ័រ ជួយសម្រួលការងាររបស់យើងបានរលូន។ ជាពិសេសធ្វើឱ្យការងារនោះមានភាពរលូនជឿនលឿនឆាប់រហ័ស ហើយទទួលបាននូវលទ្ធផលបានយ៉ាងល្អប្រសើរផងដែរ។ ដូចនេះសិស្ស និស្សិតបុគ្គលិកគ្រប់អង្គភាពគប្បីរៀនសូត្របន្ថែមទៀតនូវជំនាញកុំព្យូទ័រឱ្យចេះប្រើប្រាស់កម្មវិធីណាមួយចាំបាច់ដែលអាចជួយសម្រួលការងារប្រចាំថ្ងៃរបស់យើងបានយ៉ាងរលូន។

## II.៣.៦-តើមនុស្សនាយុគសម័យឌីជីថលមានគោលការណ៍ប្រចាំជីវិតអ្វីខ្លះ?

### II.៣.៦.១- តាមទ្រឹស្ដីទស្សនវិជ្ជា-សីលធម៌វិទ្យា

ជាការពិតណាស់ តាមទ្រឹស្តីសីលធម៌ដែលជាការរៀបរៀងរបស់ លោកសាស្ត្រាចារ្យ ញឹម បាក់ងនស្តីពីមេរៀនសម្រាប់និស្សិតទស្សនវិជ្ជាបានចែកតម្លៃរបស់មនុស្សជាប្រាំបីដែលក្នុងចំណោមតម្លៃទាំងប្រាំបីនោះមានបួនជាតម្លៃបញ្ជាក់ពីកម្រិតខ្ពង់ខ្ពស់របស់មនុស្ស។ នៅសម័យឌីជីថល មនុស្សត្រូវមានសីលធម៌ខ្ពស់ណាស់ដែលជាតម្លៃមួយដ៏ថ្លៃថ្លា។ យើងធ្លាប់បានដឹង និងបានឮគេនិយាយមកថា យើងចេះយ៉ាងណាក៏ដោយ តែបើយើងគ្មានសីលធម៌នោះទេ អ្វីៗគឺស្មើសូន្យ។ ពុំនោះសោត មានពាក្យស្លោកមួយបានពោលថា«មនុស្សដែលគ្មានសីលធម៌ ប្រៀបបាននឹងមនុស្សដែលគ្មានក្បាល»។ ដូចនេះតម្លៃសីលធម៌គឺពិតជាសំខាន់ណាស់សម្រាប់មនុស្សនាយុគសម័យទំនើបនេះ។ តាមទ្រឹស្តីទស្សនវិជ្ជាដដែលបានលើកឡើងពីសីលតម្លៃ គឺជាគោលដៅរបស់សីលញាណ ហើយទាក់ទងផ្ទាល់ទៅនឹងអំពើ សកម្មភាព ឬចរិយារបស់មនុស្ស។ សីលតម្លៃនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសុជីវធម៌ សីលធម៌ គុណធម៌ ឧត្តមគតិ និងគតិវិញ្ញូ។ ដើម្បីឱ្យមានសីលតម្លៃសម្រាប់ខ្លួនឯង មនុស្សគ្រប់រូបត្រូវតែស្គាល់ថាអ្វីទៅជាតម្លៃរបស់ខ្លួនជាមុនសិនដែលខាងក្រោមនេះជាតម្លៃដែលយើងគប្បីដឹង៖

**១. តម្លៃជីវសាស្រ្ត៖** តម្លៃនេះគឺមានជាប់ខ្លួនមនុស្សតាំងពីកំណើត មានន័យថាមនុស្សមានតម្លៃខាងរូបរាងពណ៌សម្បុរសាច់ឈាមកម្លាំងសុខភាព។

**២. តម្លៃសេដ្ឋកិច្ច៖** មានន័យថា ជាតម្លៃខាងសម្ភារៈ ទ្រព្យសម្បត្តិ។ ទ្រព្យសម្បត្តិក៏ជាកត្តាដែលបានកំណត់តម្លៃរបស់មនុស្សដែរ។ ទោះបីជារបស់ក្រៅខ្លួន ប៉ុន្តែអ្នកដែលអាចធ្វើឱ្យខ្លួនឯងមានសេដ្ឋកិច្ចល្អទ្រព្យសម្បត្តិច្រើននោះចាត់ទុកថាបុគ្គលនោះមានតម្លៃបានដែរ។

**៣.តម្លៃអារម្មណ៍៖** មានន័យថាជាតម្លៃខាងសតិស្មារតី និងចិត្តសុខស្ងប់ជាដើម។ បុគ្គលណាដែលអាចធ្វើឱ្យខ្លួនឯងមានអារម្មណ៍ស្ងប់សុខមានចិត្តមិនរវើរវាយចាត់ទុកថាជាបុគ្គលដែលមានតម្លៃបាន។

**៤.តម្លៃសង្គម៖** បានន័យថាជាតម្លៃនៃការចូលរួមចំណែក និងតម្លៃទទួលបានពីសង្គមនូវមុខងារ តួនាទីភារកិច្ច កាតព្វកិច្ច សិទ្ធិអំណាច សេរីភាព ក្នុងវិស័យនយោបាយ អរិយធម៌ របៀបរៀបរយសន្តិសុខ យុត្តិធម៌ និងវឌ្ឍនធម៌សង្គមជាដើម។

**៥.តម្លៃបញ្ញា៖** មានន័យថា ជាតម្លៃដែលកើតចេញពីគំនិតប្រាជ្ញាក្នុងការប្រើប្រាស់ចំណេះដឹងទូទៅនិងការសម្រេចចិត្តធ្វើអំពើ សកម្មភាព ដើម្បីដោះស្រាយបញ្ហានានា ដើម្បីឈានទៅដល់កំរិតពុទ្ធិសច្ចៈពុទ្ធិត្រឹមត្រូវ។

**៦.តម្លៃសោភណវិជ្ជា៖** មានន័យថាជាតម្លៃខាងសិល្បៈតុបតែងច្នៃប្រឌិត និងសោភណភាព។ តម្លៃនៃសោភណវិជ្ជា កន្លែងនេះមិនមែនសំដៅទៅលើភាពស្រស់ស្អាតនៃរាងកាយនោះទេ ប៉ុន្តែជាតម្លៃបង្ហាញពីគុណភាពបញ្ជាក់ន័យឱ្យគុណភាពនៃវត្ថុ ឥរិយាបថ អាកប្បកិរិយារបស់មនុស្ស។ តម្លៃនេះគឺសំដៅទៅលើគុណភាពផ្នែកខាងក្នុងរបស់បុគ្គល។

**៧.សីលតម្លៃ៖** មានន័យថាជាតម្លៃទទួលបានពីការស្គាល់ និងប្រតិបត្តិអំពើល្អ បុណ្យ កុសល

**៨. តម្លៃសាសនា៖** មានន័យថា ជាតម្លៃនៃចិត្តស្នេហាមោះមុតទៅលើស្មារតីនៃគោលគំនិត ទស្សនៈទ្រឹស្តីអប់រំទូន្មានត្រឹមត្រូវ។

តម្លៃទាំងប្រាំបីនេះ គឺបុគ្គលគ្រប់រូបគួរណាស់ត្រូវសិក្សាស្វែងយល់ពីលក្ខណសម្បត្តិរបស់ខ្លួនឯងថាមានគ្រប់គ្រាន់ហើយឬនៅ? ហើយត្រូវសិក្សាពីខ្លួនវិញថា តើខ្លួនឯងមានតម្លៃមួយណា ជាប់ខ្លួនប្រចាំថ្ងៃ ហើយនៅខ្វះតម្លៃមួយណា? ប៉ុន្តែក្នុងចំណោមតម្លៃទាំងប្រាំបីនេះ បុគ្គលត្រូវដឹងថាតម្លៃផ្នែកបញ្ញា តម្លៃសោភណវិជ្ជា សីលតម្លៃ និងតម្លៃសាសនាគឺជាតម្លៃបញ្ជាក់ពីកម្រិតខ្ពង់ខ្ពស់របស់មនុស្ស។

## II.៣.៦.២- គុណតម្លៃជារួម

ត្រង់ចំណុចដែលបានលើកនេះ ជាអ្វីដែលទស្សនវិជ្ជាបានលើកឡើងស្តីអំពីគុណតម្លៃមនុស្សតាមបែបសីលធម៌និយម និងមនុស្សនិយម។ យ៉ាងណាមិញ នៅក្នុងន័យនេះផងដែរ យើងបានសង្កេត និងសរុបខ្លឹមសារគោលធំៗចំនួន៥ចំណុចដូចជា៖

### II.៣.៦.២.១- គុណតម្លៃមនុស្សក្នុងមោទនភាពបុគ្គល

ត្រង់ប្រការនេះបានន័យថា មនុស្សគ្រប់រូបប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីជួយស្រោចស្រង់អាត្មាខ្លួនឯងឱ្យបានប្រសើរជាមុនសិន ទើបយើងអាចសណ្តោងជនដទៃបាន។ យ៉ាងណាមិញ ប្រសិនបើយើង

មិនទាន់បានក្លាយជាបុគ្គលជោគជ័យផង តើយើងអាចជួយមនុស្សជុំវិញ និងសង្គមជាតិយ៉ាងដូចម្តេចបាន? ត្រង់ប្រការនេះហើយ ទើបយើងនិយាយថាគុណតម្លៃមនុស្សក្នុងមោទនភាពបុគ្គលនោះ។

មោទនភាពបុគ្គល បានដល់ភាពជាទីត្រេកអរនឹងខ្លួនឯង ភាពជាទីពេញចិត្តនឹងខ្លួនឯង ជ័យជម្នះ ឬការសម្រេចបានលទ្ធផលពេញជាទីគាប់ចិត្តនៃបុគ្គលម្នាក់ៗ។ ជាការពិតណាស់ថា នៅពេលដែលយើងធ្វើអ្វីមួយបានជោគជ័យ យើងច្បាស់ជាមានក្តីសង្ឃឹម រំពឹងខ្ពស់ណាស់ ពីព្រោះយើងអាចធ្វើវាបាន។ ត្រង់ប្រការនេះផងដែរ ដើម្បីឱ្យយើងក្លាយជាបុគ្គលជោគជ័យឆ្នើមពេញជាទីមោទនៈលុះត្រាតែយើងប្រឹងប្រែងព្យាយាមធ្វើខ្លួនឱ្យក្លាយជាមនុស្សមានសមត្ថភាពខ្ពស់ រស់នៅប្រកបដោយប្រជាប្រិយភាព និងគួរជាទីពេញចិត្តសម្រាប់បុគ្គលនៅជុំវិញ។ ត្រង់ប្រការនេះហើយ ទើបយើងសង្កេតឃើញថា មនុស្សយើងម្នាក់ៗប្រឹងប្រែងណាស់ទម្រាំសម្រេចបាននូវជោគជ័យដ៏ត្រចះត្រចង់។ សិស្ស និស្សិតប្រឹងប្រែងរៀនសូត្រប្រឡងជាប់មានការងារធ្វើគឺដើម្បីកសាងជីវិត កសាងជីវភាពឱ្យកាន់តែប្រសើរឡើង ចាកផុតពីរណ្តៅទុក្ខពោលគឺអវិជ្ជានោះឯង។ ម្នាក់ៗប្រឹងប្រែងស្របទៅតាមមុខការរបស់ខ្លួន មិនថាជាសិស្ស និស្សិត បុគ្គលិកសាស្រ្តាចារ្យ ឬមន្ត្រីរាជការណានោះទេ ត្រូវតែប្រឹងដើម្បីសម្រេចបាននូវគោលដៅជាអតិបរមា។ លើសពីនេះ គេមានស្មារតីពុះពារអំណត់មិនរាថយឡើយ។ ម្យ៉ាងវិញទៀត បើគេមិនប្រឹងប្រែងនោះទេ តើបានអ្វីជាទីពឹងសម្រាប់ខ្លួនឯង? ន័យត្រង់នេះជាអ្វីដែលយើងបានដឹងហើយថា គេត្រូវតែបន្តការសិក្សា ទើបអាចស្រោចស្រង់វាសនារបស់ខ្លួនបាន។ បើយើងខ្ជិលច្រអូសមិនមានស្មារតីខ្នះខ្នែង តើបាននរណាជួយយើងបានទៅ? ដូចនេះស្របតាមបរិបទនៃសម័យថ្មីនេះ យើងត្រូវរៀនសូត្រគ្រប់ពេលវេលា បណ្តុះស្មារតីនៃការសិក្សាពេញមួយជីវិត ស្របទៅតាមបរិបទថ្មីនៃសង្គមសេដ្ឋកិច្ចឌីជីថល។

### II.៣.៦.២.២- គុណតម្លៃមនុស្សក្នុងសង្គមគ្រួសារ

ជាការពិតណាស់ ជីវិតរមែងផ្សារភ្ជាប់នឹងគ្រួសារជាក់ជាមិនខាន។ មនុស្សម្នាក់មានការជាប់ពាក់ព័ន្ធច្រើនណាស់ ពោលគឺទាក់ទងនឹងសាច់ញាតិ ក្រុមគ្រួសារ ឪពុកម្តាយ បងប្អូន កូន ក្មួយ ចៅ និងមិត្តភក្តិជាដើម។ ដូចនេះការកសាងគុណតម្លៃសម្រាប់គ្រួសារគឺពិតជាមានសារៈសំខាន់ណាស់។ សុភមង្គលពិតរបស់មនុស្សគឺស្ថិតនៅត្រង់មានមនុស្សជាទីស្រឡាញ់នៅក្បែរ។ បើយើងមានប្រជាប្រិយភាពជោគជ័យហើយ ប៉ុន្តែមនុស្សជាទីស្រឡាញ់មិននៅក្បែរ តើឱ្យយើងមានមោទនភាពដូចម្តេចបាន?

គុណតម្លៃក្នុងគ្រួសារដែលយើងចង់និយាយនេះបានដល់កត្តាសេដ្ឋកិច្ច និងការផ្តល់សេចក្តីសុខមកឱ្យក្រុមគ្រួសារ។ ក្នុងនាមជាមេគ្រួសារ ឬសមាជិកគ្រួសារគប្បីចេះសាងសេចក្តីសុខដល់គ្រួសារ។ ជាមេគ្រួសារគប្បីមានស្មារតីទទួលខុសត្រូវសម្រាប់គ្រួសារដោយមិនអាចគេចវេះមិនខ្វះខ្វែងរកប្រាក់ចិញ្ចឹមគ្រួសារនោះឡើយ។ ជាមេគ្រួសារត្រូវដើរជួរមុខគ្រប់បែបយ៉ាង។ ជាពិសេសនាសម័យវិទ្យាសាស្ត្រសេដ្ឋកិច្ចផងមិនអាចមើលរំលងប្រការនេះបានឡើយ។ ត្រង់ន័យនេះជាអ្វីដែលយើងគប្បីពិចារណា។ ប្រសិនបើយើងមិនគិតគូរដល់ប្រពន្ធកូនចៅយើង ប្តីសីរបស់យើង តើបាននរណាគិតគូរជំនួសទៅ? ដូចនេះក្នុងន័យថា មេគ្រួសារត្រូវតែជាជំហរយ៉ាងជាក់លាក់ ដើរមុនគេ មានជំនាញណាមួយច្បាស់លាស់ក្នុងការដោះស្រាយបញ្ហាប្រឈមប្រចាំជីវិត។ កាលណាយើងអាចដោះស្រាយបានឈ្មោះថា យើងមានតម្លៃសីលញាណក្នុងការទទួលខុសត្រូវលើវាសនាគ្រួសារ។ ដូចនេះដើម្បីសម្រេចបាននូវគុណតម្លៃទាំងអស់នោះលុះត្រាតែយើងប្រឹងប្រែងឡើង។ យើងគប្បីចាប់យកជំនាញបច្ចេកទេសណាមួយស្របតាមបរិបទទីផ្សារសង្គមសេដ្ឋកិច្ច ឬធ្វើការប្រកបទៅដោយឧបនិស្ស័យ នោះយើងនឹងទទួលបាននូវមនុញ្ញផលពេញជាទីគាប់ចិត្តជាក់ជាមិនខាន។ ជាពិសេក្នុងយុគសម័យឌីជីថលផង យើងអាចលៃលកដោះស្រាយយ៉ាងណាឱ្យទាន់សភាពការណ៍ជាក់ស្តែងក្នុងការរស់នៅប្រកបទៅដោយសេចក្តីថ្លៃថ្នូរក្នុងនាមជាពលរដ្ឋល្អក្នុងសង្គម។ នៅក្នុងសង្គមគ្រួសារ បុគ្គលដែលជាមេគ្រួសារគប្បីមានស្មារតីទទួលខុសត្រូវបំពេញតួនាទីជាបុគ្គលគំរូជើងជាស្មារឹងសម្រាប់គ្រួសារ។ ជាពិសេសមានគំនិតច្នៃប្រឌិត វាងវៃក្នុងការរកស៊ី រកប្រាក់ចំណូលជួយគ្រួសារទប់ទល់ទៅនឹងស្ថានភាពសេដ្ឋកិច្ចនាសម័យឌីជីថល។ នាសម័យនេះជាសម័យវិទ្យាសាស្ត្រសេដ្ឋកិច្ច ដូចនេះគេអាចច្នៃប្រឌិតបន្ថែមដើម្បីរកកម្រៃបានងាយស្រួល ជួយសម្រួលបន្ទុកចំណូលចំណាយប្រចាំថ្ងៃ និងចេះគិតគូរដល់អនាគតគ្រួសារទាំងមូលរួមមានការសិក្សារបស់កូន និងកញ្ចប់ថវិកាសម្រាប់ទប់ទល់នឹងហានិភ័យណាមួយដែលកើតឡើងជាយថាហេតុ។

ដូចនេះគុណតម្លៃក្នុងគ្រួសារកើតឡើងទៅបាន លុះត្រាតែបុគ្គលមានការប្តេជ្ញាចិត្តខ្ពស់ កសាងសង្គមគ្រួសារប្រកបទៅដោយសុខដុមរមនា។ យុវជនទាំងឡាយមុនពេលកសាងគ្រួសារគប្បីដឹងច្បាស់ថាខ្លួនមានជំនាញណាមួយច្បាស់លាស់ អាជីពណាមួយត្រឹមត្រូវដែលអាចចិញ្ចឹមគ្រួសារបានងាយស្រួលនិងមិនពិបាកផង។ កាលណាដែលយើងធ្វើបាន នោះសង្គមជាតិរបស់យើងក៏នឹងរីកចម្រើនជឿនលឿនទៅតាមនោះផងដែរពីព្រោះគ្រួសារនេះហើយជាកោសិការបស់សង្គម។

### II.៣.៦.២.៣- គុណតម្លៃមនុស្សក្នុងសង្គមជាតិ

នៅក្នុងសង្គមជាតិមិនថាប្រទេសណាឬប្រទេសណាទេរមែងត្រូវការធនធានមនុស្សកម្លាំងយុវជន ពលរដ្ឋសកម្មដើម្បីចូលរួមកសាងសង្គមជាតិឆ្ពោះទៅរកភាពរីកចម្រើនជឿនលឿនលើគ្រប់វិស័យ។ ក្នុងន័យនេះ ពលរដ្ឋគ្រប់រូបមានតួនាទីកសាងតម្លៃរបស់ខ្លួន និងចូលរួមឱ្យបានសកម្មជាងមុនក្នុងកិច្ចការរបស់ប្រទេសជាតិរបស់ខ្លួន។ កាលណាពលរដ្ឋមានស្មារតីចូលរួមបានយ៉ាងសកម្មបែបនេះ នោះសង្គមជាតិទាំងមូលនឹងមានការរីកចម្រើនបានយ៉ាងឆាប់រហ័ស។

ដើម្បីក្លាយខ្លួនជាធនធានមួយដែលសង្គមជាតិត្រូវការ លុះត្រាតែពលរដ្ឋខ្លួនឯងប្រឹងអភិវឌ្ឍខ្លួនប្រែក្លាយខ្លួនជាពលរដ្ឋសកម្មចេះត្រងត្រាប់តាមដានព័ត៌មានទាន់ហេតុការណ៍ នយោបាយ សេដ្ឋកិច្ច ការទូត វប្បធម៌ ប្រវត្តិសាស្ត្រ ស្របតាមសង្គមសេដ្ឋកិច្ចតាមបែបឌីជីថល។ ដូចអ្វីដែលយើងបានលើករួចមកហើយថា សង្គមនាសម័យនេះដើរលឿនណាស់។ ដូចនេះពលរដ្ឋគ្រប់រូប យុវជនគ្រប់រូបគប្បីប្រឹងប្រែងសិក្សារៀនសូត្រ ដកស្រង់បទពិសោធ ស្វែងយល់ពីបច្ចេកវិទ្យា ចូលរួមគ្រប់ផ្នែកតាមដែលអាចធ្វើទៅបានដើម្បីដឹកនាំនាវាជាតិឆ្ពោះទៅរកត្រើយសុភមង្គល។ តម្លៃមនុស្សនៅក្នុងសង្គមជាតិគឺជាការចេះជួយគ្នាទៅវិញទៅមកនៅក្នុងគ្រាមានអាសន្ន។ ជាក់ស្តែងកាលពី៣ឆ្នាំមុនមានការផ្ទុះនូវជំងឺកូវីដ១៩ គ្រានោះមានសប្បុរសជនជាច្រើនបានចូលរួមបរិច្ចាគប្រាក់ខែ ថវិកា ធនធានទៅតាមលទ្ធភាពជួយរាជរដ្ឋាភិបាលក្នុងការទិញវ៉ាក់សាំងចាក់ជូនប្រជាជនគ្រប់ៗគ្នា។ គ្រានោះយើងបានឃើញថាមានចលនាជាតិដ៏ធំមួយបានកៀរគរមនុស្សគ្រប់ស្រទាប់វណ្ណៈបានថវិកាយ៉ាងច្រើនទុកទិញវ៉ាក់សាំងផង និងកសាងមន្ទីរពេទ្យព្យាបាលអ្នកជំងឺផងដែរ។ ជាមួយគ្នានេះ នៅពេលមានគ្រោះទឹកជំនន់ជន់លិចលង់ក៏មានចលនាជាតិរបស់ប្រមុខដឹកនាំប្រទេសប្រមែប្រមូលថវិកាជួយប្រជាជនដែលរងផលប៉ះពាល់ផងដែរ។ ន័យត្រង់នេះជាកាយវិការដ៏ប្រពៃដែលខ្មែរតូចពិត តែបេះដូងខ្មែរទូលាយណាស់ព្រោះបានជួយសង្គ្រោះគ្នាទាន់ពេលវេលា។ ពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈគប្បីមានស្មារតីចេះជួយគ្នាទៅតាមលទ្ធភាពជាក់ស្តែង កុំចាំដល់ទឹកចូលច្រមុះ ទើបស្រវេស្រវា នោះមិនកើតឡើយ។ តាមធម៌ព្រះក៏បាននិយាយដែរថា ការធ្វើបុណ្យជាមួយមនុស្សដែលលំបាកកម្សត់អត់ឃ្លាន ប្រសើរជាងធ្វើបុណ្យវត្តទៅទៀត។ ហើយដើម្បីអាចដឹងព័ត៌មាន ឬព្រឹត្តិការណ៍ណាមួយបាន លុះត្រាតែប្រជាជនចេះតាមដានព័ត៌មាន និងមានការចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលទើបប្រសើរ។

ឆ្លងតាមការស្រាយបំភ្លឺ តម្លៃមនុស្សក្នុងសង្គមជាតិពិតជាមានសារៈសំខាន់ណាស់ដែលជួយយើងឱ្យបានសេចក្តីសុខគ្រប់ប្រការ។ ជាពិសេសបានបណ្តុះយើងឱ្យមានមនោសញ្ចេតនា ចេះជួយគ្នាទៅវិញទៅមក មិនមែនរស់នៅតែម្នាក់ឯងនោះឡើយ។ ការចេះជួយគ្នានេះហើយជាអ្វីដែលខ្មែរបានធ្វើតាំងពីដើមរៀងមក ហើយទទួលបាននូវផ្លែផ្កាជាអតិបរមា។ ការចេះជួយគ្នាទៅវិញទៅមកជាកាយវិការសប្បុរសធម៌មនុស្សធម៌មិនអាចខ្វះបានក្នុងនាមជាមនុស្សដូចគ្នា។

## II.៣.៦.២.៤- គុណតម្លៃមនុស្សក្នុងមនុស្សជាតិ

ក្នុងនាមជាមនុស្សជាតិគប្បីមានស្មារតីលើកកម្ពស់សិទ្ធិមនុស្សដែលជាគុណតម្លៃមួយដ៏ថ្លៃថ្លាសម្រាប់សង្គមជាតិនៅលើពិភពលោក។

យើងបានដឹងថា តាមឯកសារកំពូលមនុស្ស គេបានរៀបរាប់ពីស្នាដៃ និងសមិទ្ធិដ៏អស្ចារ្យរបស់មនុស្សនៅក្នុងពិភពលោកយើងនេះ។ ក្នុងនោះបុគ្គលជាមេដឹកនាំពិភពលោកសុទ្ធតែបានបន្សល់ទុកនូវកេរ្តិ៍ឈ្មោះដ៏ត្រកាលដល់ជាតិ និងប្រជាជាតិនានាលើសាកលលោកយកគំរូតាម។ ជាការកត់សម្គាល់ ការលើកកម្ពស់សិទ្ធិមនុស្សជាអ្វីដែលយើងប្រាថ្នាចង់បាន។ នៅលើសាកលលោកនេះ ការមិនរើសអើងជាតិសាសន៍ ការជួយមនុស្សផងគ្នា ការធ្វើអំពើសប្បុរសធម៌ដូចជាកាកបាទក្រហមជាដើមសុទ្ធតែបានរួមចំណែកដល់ស្មារតីនៃការជួយមនុស្សឱ្យចាកផុតពីទុក្ខលំបាក។

ឧទាហរណ៍គឺលោកវេជ្ជបណ្ឌិតជនជាតិស្វីស បឺតរីជនើ ដែលលោកបានជួយសង្គ្រោះមនុស្សពោលគឺកុមារកម្ពុជារាប់សិបម៉ឺនសែនលាននាក់ឱ្យបានរួចរស់មានជីវិត។ ជាការពិតណាស់ នេះជាទង្វើប្រកដោយសប្បុរសធម៌ក្រៃលែងជាទីបំផុតដែលប្រជាជនកម្ពុជារមែងដឹងគុណលោកជាដរាប។ ថ្វីបើលោកបានទទួលមរណភាពទៅហើយក្តី ប៉ុន្តែប្រជាជនកម្ពុជាគ្រប់ស្រទាប់វណ្ណៈបានចងចាំ និងចារឹកជាប់នៅក្នុងក្រអៅបេះដូងរបស់កូនខ្មែរ មនុស្សខ្មែរគ្រប់ស្រទាប់វណ្ណៈ។ ជាការពិតណាស់ ទង្វើសប្បុរសធម៌ និងមនុស្សដែលជាសេចក្តីស្រឡាញ់ មិនមែនកើតឡើងតែមួយថ្ងៃនោះឡើយ។ យើងត្រូវចងចាំ និងចេះស្រង់យកស្មារតីវិជ្ជមានទាំងអស់នោះដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ ឧទាហរណ៍មួយទៀត ទាហានកម្ពុជាបានចូលរួមនៅក្នុងបេសកកម្មអង្គការសហប្រជាជាតិ ជួយរំដោះប្រទេសក្រីក្រ ឬជួយថែរក្សាសន្តិសុខបណ្តាប្រទេសដែលរងគ្រោះដោយសង្គ្រាមស៊ីវិល ឬស្ថិតនៅក្រោមឆ័ត្រនៃអង្គការសហប្រជាជាតិ។ អ្វីជាការលើកឡើងនោះ ប្រជាជនខ្មែរយើងក្តី បណ្តាប្រទេសនានាក្តីបានជួយយឹតយោង ជួយគ្នានៅក្នុងបេសកកម្មនោះប្រកបដោយស្មារតីទទួលខុសត្រូវដើម្បីឱ្យមានភាពស្ងប់សុខសាន្តត្រាណទៅបាន។ ពោលគឺឱ្យប្រជាជាតិទាំងនោះមានសន្តិភាព និងសន្តិភាពពិតប្រាកដ។ គ្រាមួយនោះ មានក្រុមអ៊ីស្លាមជ្រុលនិយមបានសម្លាប់ទាហានកម្ពុជាដែលបានឈរជើងនៅបណ្តាប្រទេសអាហ្វ្រិចដែលការស្លាប់នេះរាប់ថា ជាពលិកម្មដើម្បីមនុស្សជាតិ។ ថ្វីបើរូបកាយរបស់គាត់ស្លាប់ទៅពិត ប៉ុន្តែវីរភាពជាប្រវត្តិសាស្ត្រសម្រាប់មនុស្សជាតិត្រូវបានចារឹកជាប់ក្រអៅបេះដូងមនុស្សខ្មែរ និងអន្តរជាតិនៅលើពិភពលោកជារៀងរហូត។ នៅមានវីរជនដទៃទៀតដែលទទួលបាននូវមេដាយអន្តរជាតិ ពានរង្វាន់ណូប៊ែលសន្តិភាពជូនពិភពលោកជាដើម។ តួយ៉ាងដូចជាប្រធានាធិបតីអាហ្វ្រិកខាងត្បូង លោកណែលសុន ម៉ាន់ដែលឡា (Nelson Mandela) ដែលបានជួយរំដោះប្រទេសជាតិពីការរើសអើងជាតិសាសន៍ និងនាំមកនូវសិទ្ធិសេរីភាពជូនជាតិ និងមាតុភូមិរបស់ខ្លួនដោយរំដោះប្រទេសបានពីរបបទាសភាព។

គុណតម្លៃដ៏ថ្លៃថ្លាទាំងអស់នេះជាឧត្តមភាពដ៏ប្រសើរដែលបុគ្គលជាមនុស្សមានសម្រាប់មនុស្សជាតិទាំងអស់នៅលើពិភពលោកទាំងមូល។ នៅមានវីរជនឆ្នើមៗដទៃទៀតដែលបានរួមចំណែកដល់គំរូវីរភាពរបស់មនុស្សជាតិទាំងមូល។ ជាពិសេសនៅមានវិស័យជាច្រើនដែលយើងបានដឹងដូចជា វេជ្ជសាស្ត្រ រូបវិទ្យា គីមីវិទ្យា អក្សរសាស្ត្រ និងសកម្មភាពមនុស្សធម៌ជាដើម។ អ្នកជំនាញទាំងអស់សុទ្ធតែមានបេសកកម្មសម្រាប់បុគ្គលភាពរបស់ខ្លួនជូនជាតិមាតុភូមិរួមមានសន្តិភាពពិភពលោកផងដែរ។ ត្រង់ន័យនេះជាវិភាគទានសម្រាប់មនុស្សជាតិទូទៅដោយមិនប្រកាន់ព័ណ៌សម្បុរ ឬពូជសាសន៍ណាឡើយ។ ដូចនេះក្នុងនាមជាមនុស្សខ្មែរ ជាយុវជនជំនាន់ក្រោយក្តីគប្បីសាងគុណតម្លៃ និងកិត្យានុភាព ឧត្តមភាពសម្រាប់ខ្លួនឯង ទើបមានកេរ្តិ៍ឈ្មោះប្រសើរថ្លៃថ្លាដល់អនុជនជំនាន់ក្រោយចងចាំ និងយកតម្រាប់តាម។

ប្រសិនបើយើងក្រឡេកមកមើលព្រឹត្តិការណ៍មួយដែលកើតឡើងក្នុងប្រទេសកម្ពុជា យើងក៏បានដឹងដែរថា នាថ្ងៃទី១៤ កុម្ភៈ ឆ្នាំ២០២០ កម្ពុជាបានជួយសង្គ្រោះនាវាអន្តរជាតិមួយដែលជាភាសាអង់គ្លេសហៅថា នាវាវ៉េស្ទើដាម (Westerdam) ដែលនាវានោះត្រូវបានបណ្តាប្រទេសនានាមិនឱ្យចូលចតនៅលើដែនដីរបស់ខ្លួនឡើយ។ ប៉ុន្តែកម្ពុជាបានទទួលនាវានោះឱ្យចុះចតមកលើទឹកដីនៃប្រទេសយើងគឺខេត្តព្រះសីហនុ។ គ្រានោះជាគ្រាដ៏លំបាកជាទីបំផុតដោយសារការរីករាលដាលនៃជំងឺផ្លូវដង្ហើមកូវីដ១៩ ដែលកំពុងតែផ្ទុះយ៉ាងសាហាវជាទីបំផុត។ កាយវិការរបស់ប្រទេសកម្ពុជាគ្រានោះត្រូវបានពិភពលោកមានការកោតស្ញប់ស្ញែងជាទីបំផុត និងបានចារឹកជាប់បេះដូងមនុស្សជាតិពាសពេញពិភពលោក។ នេះហើយជាស្មារតីមនុស្សជាតិដែលកម្ពុជាបានបំពេញក្នុងនាមខ្លួនជាប្រទេសមានដែនសមុទ្រ។ កាយវិការមនុស្សធម៌នេះហើយជាគុណតម្លៃមិនអាចកាត់ថ្លៃបានក្នុងនាមជាមនុស្សជាតិដូចគ្នា។

តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរ យើងបានឃើញថា រឿងព្រះវេស្សន្តរជាតកដែលជាអក្សរសិល្ប៍បុរាណបែបពុទ្ធនិយមបានលាតត្រដាងត្រង់ប្រការនេះ។ ខ្សែជីវិតរបស់ព្រះវេស្សន្តរពោធិសត្វតាំងពីកុមារគ្រាន់តែប្រសូតមកភ្លាមក៏សុំព្រះមាតាដើម្បីដាក់ទានភ្លាម។ រាជកុមារចេះមានបន្ទូលភ្លាមៗដោយសុំព្រះមាតាគឺព្រះនាងសុបារសុប្បតីដើម្បីបំពេញជាទាន។ ព្រះមាតាក៏មានព្រះទ័យរីករាយ និងឱ្យបុត្របរិច្ចាគជាទានភ្លាម។ លុះដល់ព្រះវេស្សន្តរធំពេញវ័យ ទ្រង់រៀបអភិសេកជាមួយនឹងនាងមទ្រី ក៏ព្រះអង្គនៅតែបំពេញទានដដែល។ ជាក់ស្តែងព្រះអង្គបានបរិច្ចាគទានដំរីបច្ច័យនាគដល់ព្រាហ្មណ៍ទាំង៨នាក់មកពីដែនដី នគរកលិង្គរាស្ត្រដែលរាស្ត្រកំពុងតែរងទុក្ខលំបាក ពោលគឺគ្រោះរាំងស្ងួត ជំងឺជំកាត់ជាដើម។ ព្រះវេស្សន្តរមិនមានព្រះទ័យរារែកឡើយ ព្រះអង្គបានបរិច្ចាគដំរីមង្គលនោះដល់ព្រាហ្មណ៍ដែលមកពីនគរផ្សេងដោយមិនស្តាយស្រណោះឡើយ។ ត្រង់ន័យនេះហើយ ទើបប្រជារាស្ត្រទាំងមូលនៃដែនជេតុត្តរនគរកើតក្តីក្តៅក្រហាយក៏មកតតាំងនឹងព្រះវេស្សន្តរដោយស្នើដល់ព្រះបាទស្រីសញ្ជ័យឱ្យបំបរបង់ព្រះវេស្សន្តរចេញពីព្រះនគរភ្លាមទៅ។ គ្រានោះព្រះវេស្សន្តរបានសម្រេចព្រះទ័យធ្វើតាមបំណងរបស់អ្នកស្រុកដែនអាយដោយមិនជំនាស់អ្វីឡើយ។ ព្រះវេស្សន្តរបរិច្ចាគទាំងប្រពន្ធ កូន ទ្រព្យសម្បត្តិសព្វសារពើ ពីព្រោះព្រះ

អង្គមានគោលបំណងត្រាស់ដឹងជាព្រះពុទ្ធនាអនាគតកាល។ ពោលគឺព្រះវេស្សន្តរលោកចង់ជួយសង្គ្រោះមនុស្សពីសេចក្ដីអត់ឃ្លាន ពីទុក្ខលំបាក ពីព្រោះថាគ្មានសេចក្ដីទុក្ខអ្វីឱ្យខ្លាំងក្លាស្មើដោយគម្លានគឺគ្មានឡើយ។ កាលណាមនុស្សមានសេចក្ដីស្រេកឃ្លានហើយ មនុស្សមិនអាចអត់ទ្រាំបានឡើយ ជីវិតលំបាកវេទនាពន់ពេកក្រៃ។ ត្រង់នេះហើយជាការជួយគ្នាទៅវិញទៅមកនៅក្នុងសង្គម។

ឆ្លងតាមការស្រាយបំភ្លឺ តម្លៃមនុស្សជាតិ ការលើកកម្ពស់តម្លៃសិទ្ធិមនុស្សពិតជាតម្លៃថ្លៃថ្លាណាស់។ ពីព្រោះវាបានជួយសង្គ្រោះដែលជួបការលំបាក ឱ្យបានរស់នៅសុខស្រួល ចាកផុតពីក្ដីវេទនា។ ការចេះជួយគ្នាទៅវិញទៅមកជាកាយវិការដ៏ប្រពៃក្នុងនាមជាមនុស្សជាតិដែលរស់នៅក្រោមដំបូលផ្ទៃមេឃពណ៌ខៀវតែមួយ។

## II.៣.៦-៥. គុណតម្លៃមនុស្សក្នុងភាពជាអ្នកដឹកនាំគំរូ

អ្នកដឹកនាំគំរូបានដល់មនុស្សដែលជាគំរូគេទាំងផ្នែកវិធីសាស្ត្រ គ្រប់គ្រងដឹកនាំ និងតម្លៃសីលធម៌ផងដែរ។ តាមទ្រឹស្ដីព្រះពុទ្ធសាសនាក៏បានលើកឡើងពីភាពជាអ្នកដឹកនាំល្អដែលត្រូវមានគុណធម៌ជីវិត និងប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ ទសពិធរាជធម៌ជាដើម។ ព្រហ្មវិហារធម៌បានដល់៖

**១. មេត្តា៖** សេចក្ដីរាប់អាន សេចក្ដីសន្ដោសប្រណី បំណងចង់ឱ្យអ្នកដទៃបានសុខ។ ត្រង់ន័យនេះយើងអាចនិយាយបានថា អ្នកដឹកនាំត្រូវមានមេត្តាចំពោះកូនចៅ ឬមន្ត្រីក្រោមឱវាទរបស់ខ្លួន។ ដើម្បីក្លាយជាអ្នកដឹកនាំគេបានលុះត្រាតែខ្លួនមានសមត្ថភាពពេញលេញបរិបូណ៌ទៅដោយចំណេះដឹង។ ជាការកត់សម្គាល់នាសម័យទំនើបជឿនលឿននេះ សេចក្ដីស្រឡាញ់រាប់អានសន្ដោសប្រណីចំពោះកូនចៅរបស់ខ្លួននៅតែមានជានិច្ច។ ពីព្រោះវាបានផ្ដល់មកនូវសេចក្ដីសុខ សុភមង្គលគ្រប់ពេលវេលា និងភាពកក់ក្ដៅដល់មនុស្សគ្រប់ស្រទាប់វណ្ណៈ។ ស្របដូចពាក្យខ្មែរមួយឃ្លាបានពោលថា «ទឹកត្រជាក់ ត្រីកុំ» បានន័យថាកាលណាមេដឹកនាំមានសន្ដានចិត្តល្អ ចេះមេត្តា នាំឱ្យកូនចៅចេះរួមរស់នៅជាមួយនឹងគ្នាបានសេចក្ដីសុខយូរអង្វែងរៀងរាបតទៅ។

**២. ករុណា៖** សេចក្ដីអាណិតអាសូរប្រកបដោយទឹកចិត្តជ្រះថ្លាជាពន់ពេក។ ក្នុងនាមជាមនុស្សគប្បីមានទឹកចិត្តអាណិតមេត្តាករុណា ចេះជួយសង្គ្រោះគ្នាដោយសេចក្ដីអំណរជាពន់ពេក នោះនឹងនាំឱ្យមនុស្សរស់នៅប្រកបដោយសេចក្ដីសុខគ្រប់ប្រការ។ អ្នកដឹកនាំមិនខុសពីឪពុកម្ដាយឡើយ រមែងមាននូវការសន្ដោសប្រោសប្រណីដល់កូនចៅ។ ការមានទឹកចិត្តជួយសង្គ្រោះចេះអាណិតអាសូរដល់មនុស្សដូចគ្នាផ្ដល់គុណតម្លៃធំធេងណាស់សម្រាប់មនុស្សនៅជុំវិញ។ ត្រង់ន័យនេះមេដឹកនាំគប្បីប្រកាន់នូវទឹកចិត្តករុណាដែលជាគោលធម៌មួយយ៉ាងសំខាន់សម្រាប់មាគ៌ាដឹកនាំរបស់ខ្លួន។

**៣. មុទិតា៖** ដំណើរមានចិត្តរីករាយទៅរកសេចក្តីសុខរបស់អ្នកដទៃពុំរើសមុខ គឺដំណើរដែលដឹងថាអ្នកដទៃតាមតែអ្នកក៏ដោយ គេមានទ្រព្យសម្បត្តិធនធាន បុណ្យស័ក្តិបានប្រកដោយសេចក្តីសុខ ការមានចិត្តជួយអំណរត្រេកអរគេ មិនច្រណែនឈ្នានីសអ្នកដទៃ។ ជាក់ស្តែងនៅពេលណាដែលយើងបានឃើញជនដទៃបានសេចក្តីសុខ យើងក៏សប្បាយចិត្តទៅតាមនោះផងដែរ។ ជាក់ស្តែងមេដឹកនាំគប្បីមានចិត្តល្អ មានមេត្រីចិត្ត និងមោទនភាពនៅពេលដែលឃើញកូនចៅរបស់ខ្លួនសម្រេចបានជោគជ័យក្នុងការងាររបស់ខ្លួន។ អត្តចរិតអ្នកដឹកនាំត្រង់នេះជាអ្វីដែលយើងត្រូវប្រកាន់យក ត្បិតថានាំមកនូវសេចក្តីសុខស្រួលត្រេកអរពេញចិត្តនូវអ្វីដែលគេធ្វើបាន។ មនុស្សក្រោមបង្គាប់ពិតជាមិនអាចបំភ្លេចបានឡើយចំពោះមេដឹកនាំទាំងឡាយណាដែលតែងតែលើកទឹកចិត្តកូនចៅរបស់ខ្លួននូវរង្វាន់ជាទីគាប់ចិត្តនៅពេលដែលគេសម្រេចបានជោគជ័យរាល់ការងារណាមួយដែលគេធ្វើបាន។ ត្រង់នេះហើយជាគុណតម្លៃដែលបុគ្គលជាមេដឹកនាំគ្រប់សម័យកាលគប្បីប្រកាន់យកដើម្បីដឹកនាំសង្គមជាតិឆ្ពោះទៅរកភាពប្រសើរថ្លៃថ្លា។

**៤. ឧបេក្ខា ៖** ការតាំងចិត្តកណ្តាល ដំណើរមិនលម្អៀងទៅណា។ ជាការពិតណាស់ការប្រកាន់ចិត្តជាកណ្តាលប្រៀបបានដូចជាចៅក្រមដែលប្រកាន់ខ្ជាប់នឹងសច្ចៈ យុត្តិធម៌ ពោលគឺភាពមិនលម្អៀង។ អ្នកប្រាជ្ញកវីកម្សាភាសាអ៊ូហៅង៉ុយ ក៏ធ្លាប់បានពោលដែរថា «ចេះច្បាប់បារាំង កុំភ្លេចសច្ចំ កតញ្ញូខន្តី កុំឆ្មើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តី យកឧបេក្ខា។ កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហោ កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ខាងណា សច្ចាយកត្រង់»។ ន័យត្រង់ចំណុចនេះកវីង៉ុយមានគោលបំណងអប់រំដាស់តឿនឱ្យមនុស្សគ្រប់ស្រទាប់វណ្ណៈប្រកាន់យកតែអំពើល្អ អំពើជាកុសល និងប្រកាន់យកធម៌កណ្តាលជាគោល។ ជាពិសេសអ្នកកាន់ច្បាប់ដូចជាចៅក្រម តុលាការ មេធាវី ក្រឡាបញ្ជីជាដើមគប្បីប្រកាន់យកភាពត្រឹមត្រូវ សុចរិតទៀងត្រង់ជាគោលដោយមិនមានចិត្តលម្អៀងដោយអគតិនោះទេ។ កាលណាប្រកាន់បាន នោះមានឈ្មោះថាជាបុគ្គលពោរពេញដោយឧត្តមគតិពិតប្រាកដ។ ដូចនេះមនុស្សនាសម័យទំនើបនេះក្តីគប្បីប្រកាន់យកគោលការណ៍ឧបេក្ខានៅក្នុងផ្លូវជីវិតរបស់ខ្លួន កុំឱ្យប្រាសចាកពីអំពើល្អនោះទេវតាគង់តាមជួយថែរក្សាឱ្យបានសេចក្តីសុខជាក់ជាមិនខានឡើយ។

ទន្ទឹមនឹងនេះផងដែរ មានធម៌មួយទៀតដែលមេដឹកនាំគប្បីប្រកាន់ខ្ជាប់នោះគឺធម៌ទាំងដប់ប្រការ។ ធម៌ទាំងដប់ប្រការនេះរមែងនាំមនុស្សឱ្យបានតែសេចក្តីសុខ និងវិបុលសុខ។ តាមការដកស្រង់ចេញពីសៀវភៅព្រះបាទធម្មិកនិពន្ធដោយ ព្រះភិក្ខុឥន្ទបញ្ញោ ហេង មណីចិន្តា បោះពុម្ពឆ្នាំ១៩៩៥ បានលើកឡើងថា ទសពិធរាជធម៌គឺជាធម៌ទាំងដប់ប្រការដែលបុគ្គលក្តី មេដឹកនាំក្តីគប្បីបំពេញនោះរួមមានដូចជា៖

**១.ទាន៖** បានដល់ការឱ្យ ៣ប្រការធំៗគឺឱ្យវត្ថុចំណេះដឹង និងឱ្យការអភ័យទោស។

**២.សីលៈ** ការប្រព្រឹត្តល្អ ធ្វើខ្លួនស្ថិតក្នុងប្រក្រតីភាពមិនបង្កសេចក្តីក្តៅក្រហាយដល់អ្នកដទៃ គោរពច្បាប់វិន័យចិញ្ចឹម ជីវិតក្នុងសុចរិត និងប្រើរបស់ទ្រព្យប្រកបដោយការពិចារណា។

**៣.បរិច្ចាគៈ** ការបរិច្ចាគ លះបង់ដោយពុំគិតចង់បានអ្វីមកវិញដែលជាបច្ច័យឱ្យគេគោរពសរសើរ ជាគំរូ។ ការលះបង់ទ្រព្យដើម្បីអវៈយវៈ លះបង់ដើម្បីជិវិត លះបង់ជីវិតដើម្បីភាពត្រឹមត្រូវ។

**៤.អាជ្ជវៈ៖** ការស្មោះត្រង់ ត្រង់ក្នុងតួនាទីក្នុងការងារត្រង់ចំពោះវាចា ត្រង់ចំពោះបុគ្គល ត្រង់ចំពោះប្រជារាស្ត្រ និងត្រង់ចំពោះសេចក្តីល្អ។

**៥.មទ្ទវៈ** ៖ ការទន់ភ្លន់ មិនរឹងរូស មិនចចេស គោរពទៅតាមមតិរបស់រាស្ត្រ បត់បែនទៅតាមស្ថានការណ៍ធ្វើឱ្យសង្គមកើតសាមគ្គីភាព។

**៦. តបៈ** ៖ ការដុតកិលេស ការដុតកំដៅអំពីអាក្រក់ ដុតកម្ទេចជនអាក្រក់កុំឱ្យមានក្នុងសង្គម ធ្វើឱ្យជនអាក្រក់មិនហ៊ានធ្វើបាបបន្តទៅទៀតធ្វើឱ្យជនល្អមានចិត្តល្អជាប្រយោជន៍រួម។

**៧. អក្កោធនៈ ៖** ការមិនក្រោធ មិនក្រោធខឹងព្រោះសេដ្ឋកិច្ចក្តី នយោបាយក្តី ទាហានក្តី មិនអាចប្រើការខឹងបានទេ ព្រោះខឹងនាំឱ្យខុស។

**៨. អវិហិំសា ៖** ការមិនបៀតបៀន គោរពសិទ្ធិមនុស្ស សិទ្ធិកុមារ សិទ្ធិស្ត្រី និងសិទ្ធិទាំងឡាយដែលមានចែងទាំងក្នុងផ្លូវពុទ្ធចក្រ និងអាណាចក្រជាដើម។

**៩. ខន្តី** ៖ ការអត់ធន់ ទាស់តែអត់ធន់អត់ទ្រាំ អត់ធត់ទើបសមគួរធ្វើជាអ្នកដឹកនាំ។ អត់ធន់ចំពោះកិលេសខ្លួន អត់ធន់ចំពោះភាពល្ងង់ខ្លៅរបស់ខ្លួន អត់ធន់ចំពោះអ្នកតូច អត់ធន់ចំពោះការងាររបស់ខ្លួន អត់ធន់ចំពោះពាក្យប្រឹក្សា អត់ធន់ចំពោះសេចក្តីប្រមាទ ធ្វេសប្រហែស អត់ធន់ចំពោះពាក្យតិះដៀល អត់ធន់ចំពោះការបដិបត្តិធម៌ ។

**១០.អវិរោធនៈ**៖ ការមិនធ្វើខុស ភាវនាជាប់ជាប្រចាំថា អញនឹងមិនធ្វើខុស អញនឹងមិនខុស។

អ្វីដែលបានលើកឡើងនេះ កវីម៉ុយក៏បានលើកឡើងនៅក្នុងច្បាប់ពាក្យកាព្យប្រដៅជនប្រុសស្រីដែរថា«កុំភ្លើនឃើញប្រាក់ កុំភ្លើភ្លាត់ស័ក្តិ ធ្លាក់ទៅអវចី កាន់ធម៌ទសពិធ រឹតឡើងរាសី គាប់ពីលោកិយ ទៅបរលោកនាយ។ អ្នកក្តីជាភ្លើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ ចៅក្រមជាទឹក រំឭករំលាយ កុំដេរកុំវាយ បង្ខំនាំខុស»។ ប្រការនេះ កវីម៉ុយមានគោលបំណងអប់រំឱ្យមនុស្សគ្រប់ស្រទាប់វណ្ណៈ ពិសេសអ្នកដឹកនាំត្រូវប្រកាន់យកទសពិធរាជធម៌ដែលជាធម៌ដ៏ប្រសើរ នាំមនុស្សឆ្ពោះទៅរកសេចក្តីសុខគ្រប់ប្រការ។

កាលណាដែលយើងមានធម៌ក្នុងខ្លួនហើយ នោះការដឹកនាំចេះតែរលូនទៅមុខដោយសារតែយើងមានស្មារតី មានសុឆន្ទៈជាគោល។ អ្នកដឹកនាំទាំងឡាយណាដែលប្រកាន់យកធម៌ទាំងដប់ប្រការជាគោលត្រូវបានមនុស្សទាំងឡាយគោរពស្រឡាញ់ និងចារឈ្មោះក្រអូបផ្សរផង់នៅក្នុងប្រវត្តិសាស្ត្រ។ ឧទាហរណ៍ជាក់ស្តែង ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គជាព្រះមហាក្សត្រដ៏ល្បីល្បាញចារឹកឈ្មោះនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាថាជាស្តេចដែលមានព្រហ្មវិហារធម៌ និងទសពិធរាជធម៌។ ប្រវត្តិវិទូបានចារនូវទស្សនវិជ្ជារបស់ព្រះអង្គថា«សុខទុក្ខរបស់ប្រជារាស្ត្រ គឺជាសុខទុក្ខរបស់ព្រះមហាក្សត្រ»។ ពុំនោះសោតទស្សនវិជ្ជានៃការដឹកនាំរបស់ព្រះអង្គបានពោលថា«ប្រសិនបើអ្នកជាអ្នកដឹកនាំគេ អ្នកត្រូវដឹងថា អ្នកកំពុងមានទឹកធ្ងន់ពេញអម្រែកនៅលើស្មារបស់ខ្លួន»។ ន័យត្រង់នេះអាចបញ្ជាក់បានថា ព្រះអង្គជាព្រះមហាវីរក្សត្រដ៏ឧត្តមដែលបាននាំជាតិឆ្ពោះទៅរកភាពសម្បូររុងរឿងនាសម័យមហានគរ។

ជាយោបល់រួម យើងឃើញថាលក្ខណសម្បត្តិមេដឹកនាំបានដល់ការប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវតួនាទីរបស់ខ្លួនក្នុងការងារដោយមិនត្រូវឡូកឡំជាមួយនឹងមនោសញ្ចេតនាឡើយ។ ចរិតលក្ខណៈនៃភាពជាមេដឹកនាំនោះបានដល់ភាពពិតប្រាកដ ទៀងទាត់ គ្រប់គ្រាន់ និងទាន់ពេលវេលា។ បានន័យសេចក្តីថា មេដឹកនាំដែលល្អគប្បីប្រកាន់យកឥរិយាបថដែលផ្តល់ឱ្យមនុស្សជុំវិញនូវទំនុកចិត្ត ឯករាជ្យ មានស្មារតីម្ចាស់ការ អាចប្រឈមដោះស្រាយបញ្ហាប្រកបដោយការទទួលខុសត្រូវ។ ជាក់ស្តែង មេដឹកនាំធ្វើការអ្វីក៏ដោយគឺត្រូវធ្វើការឱ្យបានពិតប្រាកដ និយាយម៉ាត់ណាគឺធ្វើយ៉ាងនោះ មានគោលការណ៍ជាក់លាក់ ហើយមិនងាករេទៅតាមតែឥទ្ធិពលណាមួយឡើយ។ សម្រាប់យុវជនក្តី ពលរដ្ឋក្តី គប្បីមានស្មារតីចរិតលក្ខណៈជាមេដឹកនាំ។ ទាល់តែយើងខ្លាំង យើងពូកែ ជាមនុស្សជើងជាស្មារឹង បានសេចក្តីថាមានសមត្ថភាពខ្ពស់ មានធនធាន មានសុខភាព មានចំណេះដឹងច្បាស់លាស បានគេមកពឹងពាក់យើងឱ្យជួយដោះស្រាយបញ្ហាជីវិត។ ពោលគឺមិនថាជាបញ្ហាអ្វីក៏ដោយ បុគ្គលដែលមានភាពជាមេដឹកនាំរមែងស្គាល់ច្បាស់នូវតម្លៃរបស់ខ្លួន ហើយប្រើប្រាស់សក្តានុពលរបស់ខ្លួនឆ្ពោះទៅរកគោលដៅណាមួយ។ អ្វីទាំងអស់នោះគប្បីមានគុណធម៌ សច្ចធម៌មកជាមួយផង ទើបអាចឱ្យសង្គមជាតិទទួលស្គាល់បាន។

## II.៤- សរុបខ្លឹមសារគោលសំខាន់ៗ

សរុបមក គុណតម្លៃមនុស្សដែលពោរពេញដោយលក្ខណសម្បត្តិគ្រប់គ្រាន់នាសម័យឌីជីថលនោះ ដែលយើងបានសង្កេតឃើញរួមមាន៖

### ក. វិជ្ជាសម្បទា៖

បានន័យសេចក្តីថា ចំណេះវិជ្ជាពិតជាមានសារៈសំខាន់ណាស់មិនថាក្នុងការសិក្សារៀនសូត្រ ការងារ ក៏ដូចជាទំនាក់ទំនងក្នុងសង្គម មនុស្សចាំបាច់ត្រូវតែមានចំណេះដឹង។ ចំណេះដឹងទាំងនោះរួមមានចំណេះដឹងផ្នែកភាសាជាតិឱ្យបានច្បាស់លាស់។ ជាការពិតណាស់ កាលណាដែលយើងមានចំណេះ

ដឹងភាសាជាតិច្បាស់លាស់ នោះមានភាពងាយស្រួលក្នុងការសិក្សាស្វែងយល់ពីមូលដ្ឋាននៃមុខវិជ្ជាដទៃផ្សេងទៀតផងដែរ។ ជាក់ស្តែងដូចជានៅតាមសាលារដ្ឋ ឯកជន ឬសាលាលំដាប់អន្តរជាតិដែលនៅលើទឹកដីកម្ពុជា ក្រសួងអប់រំយុវជន និងកីឡា បានកំណត់ឱ្យបញ្ចូលកម្មវិធីសិក្សាភាសាខ្មែរ និងបញ្ជ្រាបចំណេះដឹងផ្នែកវប្បធម៌ អរិយធម៌ជាដើមដល់កូនខ្មែរជំនាន់ក្រោយឱ្យបានចេះដឹង ស្គាល់ពីភាសា អក្សរសាស្ត្រនៃជាតិខ្មែរយើង។ កាលណាមានចំណេះដឹងផ្នែកភាសាជាតិ នាំឱ្យកូនខ្មែរស្រឡាញ់សង្គមជាតិ ប្រទេសជាតិ តម្លៃវប្បធម៌ដ៏ផូរផង់របស់ជាតិ។ ជាពិសេសមុខវិជ្ជាមួយចំនួនដូចជា អក្សរសាស្ត្រខ្មែរ ភូមិវិទ្យា ប្រវត្តិវិទ្យា វេជ្ជសាស្ត្រជាដើមដែលធ្វើឱ្យយើងងាយស្រួលក្នុងការសិក្សាប្រើភាសាជាតិជាគោល។ យើងជាកូនខ្មែរ ប្រសិនបើយើងមិនស្គាល់គុណតម្លៃនៃភាសាជាតិរបស់ខ្លួន វប្បធម៌ជាតិរបស់ខ្លួន តើឱ្យនរណាមកស្គាល់ជាងកូនខ្មែរទៀតនោះ? ដូចនេះគុណតម្លៃដ៏ផូរផង់នៃមនុស្សខ្មែរគប្បីស្វែងយល់ភាសាជាតិរបស់ខ្លួនឱ្យបានច្បាស់លាស់ និងចេះផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ បច្ចេកវិទ្យាដើម្បីទាក់ទាញឱ្យគេបានស្គាល់ពីសង្គមជាតិខ្មែរ។ លើសពីនេះ មនុស្សនាសម័យជឿនលឿនគប្បីមានចំណេះដឹងភាសាបរទេសដូចជាភាសាបារាំង អង់គ្លេស ភាសាចិន ជប៉ុន ភាសាថៃ វៀតណាមជាដើម។ កាលណាកូនខ្មែរចេះដឹងភាសាអន្តរជាតិណាមួយច្បាស់លាស់នាំឱ្យសង្គមជាតិមានការរីកចម្រើនងាយស្រួលក្នុងការទាក់ទងគ្នាក្នុងវិស័យជំនួញ ការរកស៊ី ការអប់រំ និងការផ្លាស់ប្តូរបទពិសោធគ្នាទៅវិញទៅមក។ ដូចនេះកាលណាពលរដ្ឋយើងចេះភាសាបរទេសណាមួយច្បាស់លាស់ពិតជាមានគុណប្រយោជន៍យ៉ាងក្រៃលែងសម្រាប់ជីវិតរបស់ខ្លួនផង និងសម្រាប់សង្គមជាតិទាំងមូលផងដែរ។ ការចេះភាសាអន្តរជាតិណាមួយច្បាស់លាស់ធ្វើឱ្យគេស្គាល់ពិភពលោកបានវែងឆ្ងាយ។ ពលរដ្ឋគប្បីមានជំនាញរឹង និងជំនាញទន់ដែលជួយសម្រួលដល់ការរស់នៅមានភាពប្រសើរឡើង។

## ខ. បំណិនសម្បទា៖

ក្រោយពេលមនុស្សមានចំនេះដឹងហើយ មនុស្សត្រូវយកវាមកអនុវត្តតាមរយៈការអនុវត្តចំណេះដឹង ការច្នៃប្រឌិត សហការ ទំនាក់ទំនង ការដោះស្រាយបញ្ហាប្រឈមនានា។ ជាការពិតណាស់ ការសិក្សាមានមិនចេះចប់ឡើយ។ កាលណាកាន់តែសិក្សាគឺមានអារម្មណ៍ថាខ្លួនកាន់តែល្ងង់។ ពីព្រោះចំណេះដឹងមានថ្មីៗជានិច្ច។ យើងមិនអាចសិក្សារៀនសូត្រអស់ឡើយនៅចំណេះដឹងនៅក្នុងលោកនេះ។ ប្រការសំខាន់ កាលណាដែលយើងរៀនហើយ យើងអាចដោះស្រាយបញ្ហាប្រឈមនៅក្នុងជីវិត ឬអាចប្រើការបាន នោះហើយជាគុណតម្លៃដ៏ថ្លៃថ្លា។ មនុស្សនាសម័យឌីជីថល ត្រូវមានស្មារតីភ្ញាក់រឭកខ្ពស់ មានជំនាញណាមួយច្បាស់លាស់ ឱ្យស្របនឹងពាក្យអ្នកប្រាជ្ញភាសាអ៊ីហៅង៉ុយពោលថា «បើចេះប្រាកដ ប្រាក់រត់តាមហៅ»។ យើងត្រូវបន្តការសិក្សាពេញមួយជីវិតដើម្បីសម្រេចបានផ្លែផ្កាទាំងអស់នេះបាន។ ប្រសិនបើយើងមិនប្រឹងប្រែងសិក្សារៀនសូត្រនោះទេ តើយើងមានចំណេះដឹងមកពីណា? តើយើងអាចស្វែងរកលាភសក្ការៈយ៉ាងដូចម្តេចបាន? ត្រង់នេះជាប្រការមួយដែលយើងត្រូវយកចិត្តទុកដាក់ និងប្រឹង

ប្រែងសិក្សារៀនសូត្រជាដរាបដើម្បីក្លាយជាមនុស្សពេញលក្ខណៈ។ នៅសម័យទំនើបនេះដែលយើងហៅថាជាសម័យវិទ្យាសាស្ត្រសេដ្ឋកិច្ច ឬជាសម័យឌីជីថល មនុស្សទាមទារនូវជំនាញណាមួយច្បាស់លាស់ ហើយគប្បីជំឡើងគុណវុឌ្ឍិរបស់ខ្លួនឱ្យបានជាប្រចាំដើម្បីឈោងចាប់អនាគតដ៏ត្រកាល។ យើងធ្វើជាមនុស្សដែលមានតម្លៃដោយការពុះពារ ប្រឹងប្រែង សិក្សារៀនសូត្រ ស្រង់យកបទពិសោធអ្នកជំនាន់មុន ហើយអនុវត្តបន្តិចម្តងៗឱ្យបានលុះត្រាតែទទួលបានផលជាផ្លែផ្កា ។ ធ្វើជាមនុស្សមិនត្រូវអស់សង្ឃឹមនៅក្នុងឆាកជីវិតឡើយ។ មនុស្សយើងត្រូវមានស្មារតីជម្នះគ្រប់ឧបសគ្គដែលឧបសគ្គទាំងអស់នោះហើយជាមូលហេតុ ឬជាដើមចមឱ្យយើងបានរឹងមាំនៅក្នុងឆាកជីវិត។ ធ្វើជាមនុស្សក៏មិនត្រូវទន់ជ្រាយឡើយ។ ពីព្រោះកាលណាយើងទន់ជ្រាយហើយ តើនរណានឹងជួយយើងបាន។ ដូចនេះ យើងត្រូវតែរឹងមាំ ហើយរឹងមាំជានិច្ចដើម្បីអនាគតដត៏ត្រកាលរបស់យើង។ ជាក់ស្តែង បើយើងនិយាយពីយុវជនវិញនាសម័យឌីជីថលនេះ ពួកគេទាមទារនូវការសិក្សារៀនសូត្រ យុវជនត្រូវចេះសហការគ្នា និងមានទំនាក់ទំនងល្អក្នុងដំណើរការស្រាវជ្រាវជាក្រុមជាដើម។ ជាពិសេសនៅក្នុងគោលដៅលើកកម្ពស់ការសិក្សាឱ្យបានល្អប្រសើរ។ គេត្រូវស្រាវជ្រាវនៅសាលារៀន បណ្ណាល័យ អ៊ីនធឺណិតដែលមានភាពងាយស្រួល និងឆាប់ហ័សថែមទៀតផង។ ការសិក្សារៀនសូត្ររបស់យុវជនមិនត្រឹមតែនៅក្នុងថ្នាក់រៀនប៉ុណ្ណោះទេ ប៉ុន្តែគឺទាមទារឱ្យមានការសិក្សារៀនសូត្រនៅគ្រប់ទីកន្លែង ស្វែងយល់ពីបរិបទការងារនាសម័យថ្មី សង្កេតពីបាតុភូតសង្គម និងការប្រែប្រួលនៃសង្គមមនុស្សជាដើម។ យើងត្រូវដឹងថា តើសង្គមយើងដើរដល់ណា? វិវត្តដល់ណា? មានអ្វីកើតឡើងខ្លះ? ត្រង់នេះជាចំណុចសំខាន់នៃការសិក្សានាសតវត្សទី២១។

ដូចនេះក្នុងនាមជាពលរដ្ឋសាកលគប្បីមានបំណិនសម្បទាដោះស្រាយគ្រប់បញ្ហាដែលកើតមាននៅក្នុងឆាកជីវិត ពង្រឹងខ្លួនឯងក្លាយជាមេដឹកនាំពិតប្រាកដនាថ្ងៃអនាគតតរៀងទៅ។

**គ. ចរិយាសម្បទា៖**

ក្រោយពេលមនុស្សមានចំណេះដឹង បំណិនសម្បទា ការអនុវត្ត មនុស្សចាំបាច់ត្រូវមាននូវតម្លៃគុណធម៌ សីលធម៌ ចរិយាធម៌។ ជាការពិតណាស់ ថ្វីបើយើងមានចំណេះដឹងយ៉ាងណាក៏ដោយ ប៉ុន្តែប្រសិនបើយើងមិនមានចិត្តចេះឱនលំទោន មិនមានចរិតលក្ខណៈអាកប្បកិរិយាល្អ នោះអ្វីៗអាចនិយាយបានថាស្មើសូន្យ។ ពីព្រោះការចេះបន្ទន់ឥរិយាបថ ការចេះដាក់ខ្លួន និងការមានចិត្តចេះអធ្យាស្រ័យឱ្យគ្នានឹងគ្នាជាគុណតម្លៃដ៏ថ្លៃថ្លា។ មនុស្សគប្បីមានសីលធម៌ជាគោល។ បុគ្គលដែលគ្មានសីលធម៌ ប្រៀបបានជាបុគ្គលដែលគ្មានក្បាល។ ជាការពិតណាស់ សីលធម៌បានដល់សេចក្តីល្អទាំងឡាយមានសីលប្រាំ សីលប្រាំបី ឬប្រកាន់នូវសីលដប់ម្តងម្កាល។ កាលណាដែលមនុស្សប្រកាន់ខ្ជាប់នូវសេចក្តីល្អនៅក្នុងខ្លួន គេអាចរស់នៅបានយ៉ាងស្រួលក្នុងជីវិត។ គេមានចិត្តតស៊ូ គេចេះរស់នៅឱ្យចុះសម្រុងនៅក្នុងសង្គមមនុស្ស និងប្រកាន់ខ្ជាប់នូវគោលការណ៍របស់ខ្លួន។ ជាមេដឹកនាំក៏ដោយគប្បីប្រកាន់ខ្ជាប់នូវគុណធម៌ជាគោលពោលគឺការមិនប្រមាថទាំងកាយវាចាចិត្ត។ ប្រកាន់ខ្ជាប់នូវការប្រព្រឹត្តតែអំពើល្អ នោះនាំឱ្យយើងទទួល

បាននូវសេចក្តីល្អគ្រប់បែបយ៉ាង។ ការបណ្តុះឱ្យមនុស្សនាសម័យនេះប្រកាន់ខ្ជាប់នូវសីលធម៌ សុជីវធម៌ និងគុណធម៌ជាគោលបែបនេះ អាស្រ័យលើការអប់រំដែលអាចជំរុញមនុស្សឱ្យមានស្មារតីភ្ញាក់រឭកគ្រប់បែបយ៉ាង។ ក្រៅពីនេះផងដែរ យើងគប្បីប្រកាន់ខ្ជាប់នូវអំពើល្អ ប្រកាន់តែសេចក្តីល្អដោយយល់ថា មានតែសេចក្តីល្អប៉ុណ្ណោះដែលអាចជួយស្រោចស្រង់យើងចាកផុតពីអន្លង់ទុក្ខទាំងពួងបាន។ តួយ៉ាងដូចជាសង្គមកម្ពុជានេះហើយ ដោយសារតែការប្រកាន់ខ្ជាប់នូវសីលធម៌និយមតាមបែបព្រះពុទ្ធសាសនា ទើបធ្វើឱ្យសង្គមយើងបានសុខសាន្តជួបតែសុភមង្គល និងវិបុលសុខរៀងរាបមក។ លើសពីនេះផងដែរ មនុស្សនាសម័យថ្មីនេះគប្បីមានភាពម្ចាស់ការលើខ្លួនឯង ភាពជាអ្នកដឹកនាំល្អដោយប្រកាន់ខ្ជាប់តែនឹងសេចក្តីទៀងត្រង់ សុចរិតភាព ទន់ភ្លន់ប្រកបដោយសីលធម៌ ភាពគោរពគ្នាទៅវិញទៅមកដែលជាមាគ៌ាដ៏ប្រពៃអប់រំមនុស្សឱ្យជួបតែភាពសុខសាន្ត។ សីលធម៌ព្រះពុទ្ធសាសនាជាវិការៈដែលជួយមនុស្សឱ្យបានសុខសប្បាយចាកឆ្ងាយពីទុក្ខសោកគ្រប់ប្រការ។ ជាមួយគ្នានេះផងដែរ មនុស្សនៅយុគសម័យឌីជីថលគប្បីចូលរួមចំណែកគោរពច្បាប់សង្គម គោរពច្បាប់រដ្ឋធម្មនុញ្ញ និងធ្វើខ្លួនជាមនុស្សថ្លៃថ្នូរប្រកាន់ខ្ជាប់តែនឹងធម៌អហិង្សាជាដរាប។ ការប្រកាន់ខ្ជាប់នូវអំពើល្អជួយញ៉ាំងឱ្យខ្សែជីវិតរបស់យើងទទួលបាននូវមនុញ្ញផលពោលគឺផលដ៏ល្អប្រសើរគួរជាទីគាប់ចិត្ត។

សរុបសេចក្តីមក គុណតម្លៃមនុស្សក្នុងយុគសម័យឌីជីថលជាប្រការសំខាន់ដែលបុគ្គលគ្រប់រូបគប្បីយកចិត្តទុកដាក់។ នៅក្នុងយុគសម័យនៃសេដ្ឋកិច្ចឌីជីថល ជាមនុស្សក្នុងសតវត្សរ៍ទី២១ ត្រូវមានសមត្ថភាពពេញលេញ មានការច្នៃប្រឌិត នវានុវត្តន៍ និងទទួលការអប់រំតាមបែបបរិយាបន្ន ដោយការចេះរួមរស់ជាមួយគ្នាប្រកបទៅដោយសមធម៌ គុណធម៌ សីលធម៌ សុជីវធម៌ ស្របទៅតាមចំណេះជំនាញរបស់ខ្លួន។ ជាមួយគ្នានោះ យើងគប្បីដើរឱ្យទាន់សម័យកាល យល់ដឹងពីបច្ចេកវិទ្យាទំនើបដើម្បីសម្រេចឱ្យបាននូវលក្ខណសម្បត្តិជាមូលដ្ឋានគឺ វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាដែលសុទ្ធសឹងតែជាគុណតម្លៃដ៏ថ្លៃថ្លាក្នុងនាមជាមនុស្សនៅយុគសម័យឌីជីថល។

## III-បញ្ចប់សេចក្តី

ឆ្លងតាមការស្រាយបំភ្លឺខាងលើនេះ ប្រធានបទក្នុងឱកាសដ៏វិសេសវិសាលនៃទិវាជាតិអំណានលើកទី៨ នេះពិតជាមានខ្លឹមសារល្អជ្រាលជ្រៅក្រៃលែង។ ពីព្រោះវាបានបណ្តុះស្មារតីមនុស្សឱ្យមានសុឆន្ទៈក្នុងការអភិវឌ្ឍចំណេះដឹងរបស់ខ្លួនជាមូលដ្ឋាន និងបន្តការសិក្សាស្រាវជ្រាវពេញមួយជីវិត។ ក្នុងន័យនេះផងដែរ ទស្សនៈប្រធានបទបានលាតត្រដាងនូវខ្លឹមសារមិនអាចកាត់ថ្លៃបាននៅក្នុងបរិបទនៃការរស់នៅក្នុងសង្គមសេដ្ឋកិច្ចឌីជីថល។ សម័យកាលនេះជាសម័យកាលមួយដែលវិទ្យាសាស្ត្ររីកចម្រើនលឿនលឿនសម្បើមណាស់។ ថ្វីបើវិទ្យាសាស្ត្ររីកលូតលាស់យ៉ាងនេះក្តី យើងគប្បីរក្សាឱ្យបាននូវតម្លៃជាមនុស្សល្អសុចរិតត្រឹមត្រូវដែលប្រកបទៅដោយសីលធម៌ គុណធម៌ សុជីវធម៌ ចរិយាធម៌ និងភាពជាពលរដ្ឋ

សាកលប្រកបដោយបរិយាបន្នជាដើម។ ជាមួយគ្នានេះ យើងគប្បីយកចិត្តទុកដាក់ទៅលើកត្តាសេដ្ឋកិច្ច នយោបាយ ការទូត ដោយការចូលរួមសិក្សាស្វែងយល់ប្រកបដោយមនសិការខ្ពស់។ ជាក់ស្តែង ជាមនុស្ស នៅក្នុងសង្គមសេដ្ឋកិច្ចឌីជីថលមានកត្តាច្រើនណាស់ដែលត្រូវយកចិត្តទុកដាក់ ដើរឱ្យទាន់ការវិវត្តនៃសង្គម ការប្រែប្រួលនៃបរិការណ៍សាកលលោក និងការចេះរៀបចំខ្លួនឱ្យបានល្អប្រសើរត្រៀមទប់ទល់ទៅនឹងបញ្ហាប្រឈមនានានៅក្នុងជីវិត។ ការចេះរៀបចំខ្លួននាំឱ្យយើងក្លាយជាមនុស្សឈ្លាសវៃ មាននូវបំណិនប៉ិនប្រសប់ ច្នៃប្រឌិតខ្ពស់ ដោយសម្របសម្រួលទៅនឹងស្ថានការណ៍ជាក់ស្តែង។ ក្នុងន័យនេះ មនុស្សនៅសតវត្សរ៍ទី២១ គប្បីមានស្មារតីបន្តការសិក្សាពេញមួយជីវិតស្របដូចពាក្យមួយឃ្លាពោលថា«មានការសិក្សាធ្វើឱ្យយើងមានអនាគត មានការសិក្សាធ្វើឱ្យយើងមានក្តីសង្ឃឹម»។ ពោលគឺព្រោះតែវិជ្ជាធ្វើឱ្យយើងដើរបានឆ្ងាយ ស្គាល់ពិភពលោកកាន់តែប្រសើរជាងមុន និងមានការរីកចម្រើនទាំងប្រាជ្ញាស្មារតីគ្រប់សព្វសារពើ។ ដូចនេះក្នុងនាមជាមនុស្សជាតិគប្បីព្យាយាមសិក្សារៀនសូត្រ អភិវឌ្ឍចំណេះជំនាញរបស់ខ្លួនប្រកបទៅដោយមនសិការវិជ្ជាជីវៈខ្ពស់ក្នុងការរួមចំណែកកសាងសង្គមជាតិកម្ពុជាឱ្យបានលូតលាស់ និងចូលរួមថែរក្សាប្រពៃណីដ៏ល្អផូរផង់របស់ដូនតាខ្មែរជានិច្ចនិរន្តរ៍តរៀងទៅ។

## ឯកសារពិគ្រោះ

១. វចនានុក្រមខ្មែរ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ឆ្នាំព.ស.២៥១១ គ.ស. ១៩៦៧
២. កម្រងតែងសេចក្តីខ្មែរ សរ សារុន, ឆ្នាំ១៩៧២
៣. សង្គមវិជ្ជាខ្មែរ សរ សារុន, ឆ្នាំ១៩៧៣-១៩៧៤
៤. តែងសេចក្តី, ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨
៥. សិក្សាអត្ថបទអក្សរសិល្ប៍, ឆ្នាំ២០១៧
៦. https://education.ams.com.kh/life-education/news/lifelong-education-helps-improve
៧. https://education.ams.com.kh
៨. https://khmershareknowledge.wordpress.com/2013/06/12/%E1%9E%82%E1%9E
៩. https://thmeythmey.com/?page=detail&id=47104
១០. Dictionnaire français-Khmer La Rousse 2005